**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍជីវភាពគ្រួសារ តាមរយៈការចិញ្ចឹមទា

កម្មសិក្សាពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ឈ្មោះស្ថាប័ន៖ កសិដ្ឋានចិញ្ចឹមទា លោក ហុី បូរ៉ា ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ស៊ឹម សុខខា**

**ខន គឹមសៀង**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៤

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេររបាយការណ៍ ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ស៊ឹម សុខខា និងនាងខ្ញុំឈ្មោះ ងន គឹមសៀង ជានិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី ៤ ជំនាន់ទី ៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ តាមរយៈការណែនាំ និងផ្តល់យោបល់ជាច្រើន ដែលជួយឲ្យរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សារបស់ពួកយើងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅអស់ពីដួងចិត្តជូនចំពោះ៖

- លោកឪពុក អ្នកម្តាយ នូវគុណដ៏ធំធេងក្រៃលែងគ្មានអ្វីប្រៀបស្មើរបាន គឺលោកទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងទូន្មាន ព្រៀនប្រដៅដល់ពួកយើងខ្ញុំ។ ជាពិសេសនោះ គឺបានលះបង់សព្វគ្រប់បែបយ៉ាង ដោយមិនគិតពីពេលវេលា និងការលំបាកអ្វីឡើយដើម្បីអោយពួកយើងខ្ញុំបានសិក្សារៀនសូត្ររហូតមកដល់សព្វថ្ងៃនេះ។
- ឯកឧត្តមសាកលវិទ្យាធិការ លោក លោកស្រី សាកលវិទ្យាការរង ព្រឹទ្ធបុរស លោកគ្រូនិងអ្នកគ្រូ ព្រមទាំងសាស្រ្តាចារ្យទាំងអស់ក្នុងសាកលវិទ្យាភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែង យកចិត្តទុកដាក់ បង្ហាត់បង្រៀននូវចំណេះដឹង និងបទពិសោធន៍ល្អៗគ្រប់បែបយ៉ាងដល់ពួកយើងខ្ញុំ ។
- សូមថ្លែងអំណរអរគុណជាពិសេសដល់លោកគ្រូសាស្រ្តាចារ្យបណ្ឌិត ឈុន ពហុ ដែលបានខិតខំផ្តល់ជាមតិយោបល់ ជួយពន្យល់ណែនាំ ព្រមទាំងចំណាយពេលវេលាក្នុងការកែតម្រូវ និងបញ្ចេញគំនិតសម្រាប់ការច្នៃប្រឌិតបន្ថែមទៀតដើម្បីអោយការស្រាវជ្រាវរបស់ពួកយើងខ្ញុំកាន់តែប្រសើរឡើងរហូតដល់បញ្ចប់សារណានេះ។
- សូមថ្លែងអំណរគុណដល់លោកពូ ហ៊ឺ ប៉ូរ៉ា ដែលជាម្ចាស់កសិដ្ឋានចិញ្ចឹមទាស្ថិតនៅភូមិទ្រាសរ ឃុំ ខ្នាសរ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដែលបានចំណាយពេលវេលាសម្រាប់ពួកយើងខ្ញុំក្នុងការធ្វើបទសម្ភាសន៍ និងផ្តល់នូវកម្រងឯកសារជាច្រើនដែលទាក់ទងនឹងបច្ចេកទេសនៃការចិញ្ចឹមទាដើម្បីជាជំនួយសម្រាប់ពួកយើងខ្ញុំយកមកសិក្សាស្រាវជ្រាវបន្ថែម។

ជាចុងក្រោយយើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គលគ្រប់ប្រការ ជូនចំពោះអ្នកមានគុណទាំងអស់ឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យអស់រយៈពេល ៤ ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក យើងខ្ញុំត្រូវបានសាកលវិទ្យាល័យតម្រូវឲ្យជ្រើសរើសក្នុងការសរសេររបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាទៅតាមជំនាញឯកទេសដែលបានសិក្សា។ ការសរសេររបាយការណ៍នេះជាចំណែកមួយដ៏សំខាន់ របស់និស្សិតក្នុងការអនុវត្តន៍ផ្ទាល់ និងដលស្រង់បទពិសោធន៍ជាក់ស្តែង ដើម្បីឆ្លុះបញ្ចាំងពីទ្រឹស្តី ចំណេះដឹង ក្រោយពីការសិក្សាកន្លងមក។

ជាក់ស្តែងអំពីស្ថានការណ៍នាពេលបច្ចុប្បន្ន ប្រទេសជាច្រើនបានកំពុងស្ថិតក្នុងស្ថានភាពយ៉ាប់យ៉ឺនដោយសារតែបញ្ហានៃជម្ងឺឆ្លង ដែលធ្វើឲ្យវិស័យមួយចំនួនប្រឈមនឹងការខាតបង់ ព្រមទាំងបានទាញសេដ្ឋកិច្ចឲ្យថយចុះទៅតាមនោះដែរ។ រោងចក្រ សហគ្រាសខ្លះត្រូវបានបិទទ្វា ប្រជាពលករបាត់បង់ការងារ គ្មានចំណូល ចំណាយច្រើនដោយសារតែទំនិញចាំបាច់មួយចំនួនមានតម្លៃកើនឡើង។ ក្នុងកាលៈទេសៈបែបនេះយើងឃើញថាវិស័យកសិកម្មបានក្លាយជាវិស័យអាទិភាព ដែលមានការប្រឈមតិចតួចជាងគេ។ ស្របពេលគ្នានេះដែរក៏ឃើញមានការផ្សព្វផ្សាយដែលទាក់ទងនឹងការបង្កើនចំណូល និងការបន្ថយចំណាយតាមរយៈវិស័យកសិកម្ម ជាពិសេសសម្រាប់ប្រជាជននៅតាមទីជនបទ ដោយជំរុញ និងលើកកម្ពស់ការចិញ្ចឹមសត្វ។ ដោយហេតុនេះហើយទើបពួកយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទនេះឡើង ក្នុងការស្រាវជ្រាវដើម្បីចងក្រងជារបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា ក្នុងគោលបំណង ទុកជាឯកសារសម្រាប់មិត្តអ្នកអាន និងមិត្តនិស្សិតទាំងឡាយដែលមានបំណងចង់ស្វែងយល់ ស្រាវជ្រាវពីបច្ចេកទេស និងបទពិសោធន៍ដែលទាក់ទងទៅនឹងការចិញ្ចឹមទា ជាពិសេសសម្រាប់អ្នកដែលចង់ចាប់ផ្តើមចិញ្ចឹម។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំ និងជឿជាក់ថា បើទោះបីជាសារណានេះនៅមានភាពខ្វះខាត តែវាអាចក្លាយទៅជាឯកសារសម្រាប់ការសិក្សា និងការស្រាវជ្រាវសម្រាប់អ្នកអាននានាដែលនឹងក្លាយជាទុនមួយដ៏មានន័យសម្រាប់ពង្រីកចំណេះដឹង ព្រមទាំងអាចចងក្រងជាឯកសារយោងជាក់ជាពុំខាន។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រាល់មេរៀន និង ទ្រឹស្តីដែលបានសិក្សាកន្លងមក យើងខ្ញុំនឹងស្វែងរកឱកាសដើម្បីបង្ហាញចេញ និងអនុវត្តឲ្យមានប្រយោជន៍សម្រាប់ជាការរួមចំណែកអភិវឌ្ឍន៍ និងលើកស្ទួយវិស័យកសិកម្មនៅកម្ពុជា ជាពិសេសតំបន់ដែលមានការខ្វះខាត លើចំណេះដឹងបច្ចេកទេសឲ្យមានការរីកចម្រើន។

# មាតិកា

បញ្ជីអក្សរកាត់..........v
បញ្ជីតារាង..........vi
បញ្ជីក្រាភិក..........vii
បញ្ជីរូប..........vii

## សេចក្តីផ្តើម

១. លំនាំបញ្ហា..........១
២. ចំណោទបញ្ហា..........២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ..........២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ..........២
៥. វិធីសាស្រ្តនៃការស្រាវជ្រាវ..........៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ..........៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..........៤

## ជំពូកទី១
## ការសិក្សាអំពីទ្រឹស្តី

១.១. និយមន័យការអភិវឌ្ឍ..........៥
១.២. ទ្រឹស្តីការអភិវឌ្ឍ..........៦
១.២.១. ទ្រឹស្តីរបស់លោក Rostow..........៦
១.២.២. ទ្រឹស្តីរបស់លោក Michael P. Tadora..........៧
១.២.៣. គំរូរបស់លោក W. Arthhur Lewis (1950s)..........៨
១.៣. គោលបំណង និងគោលដៅនៃការអភិវឌ្ឍ..........៨
១.៣.១. គោលបំណងនៃការអភិវឌ្ឍ..........៨
១.៣.២. គោលដៅនៃកាអភិវឌ្ឍ..........៩
១.៤. កត្តាជំរុញការអភិវឌ្ឍ..........៩
១.៤.១. កត្តាធនធានមនុស្ស..........១០
១.៤.២. កត្តាធនធានធម្មជាតិ..........១០

១.៤.៣. កត្តាមូលធន ........ ១០
១.៤.៤. កត្តាបច្ចេកវិទ្យា ........ ១១
១.៥. កត្តារាំងស្ទះដល់ការអភិវឌ្ឍ ........ ១១
១.៥.១. កត្តាកំណើនប្រជាជន ........ ១១
១.៥.២. កត្តាកម្រិតការអប់រំទាប ........ ១៣
១.៥.៣. កត្តានិកម្មភាព ........ ១៣
១.៥.៤. កត្តានយោបាយ ........ ១៤
១.៦. តួនាទីរបស់កសិកម្មក្នុងសេដ្ឋកិច្ចគ្រួសារ ........ ១៥
១.៦.១ ប្រភពចំណូលយ៉ាងសំខាន់ ........ ១៥
១.៦.២ ផ្តល់ស្បៀងអាហារ ........ ១៦
១.៦.៣ ផ្តល់ការងារ ........ ១៧
១.៦.៤ បង្កើនកម្រិតជីវភាពនៃការរស់នៅ ........ ១៧
១.៧. បច្ចេកទេសចិញ្ចឹម និងគ្រប់គ្រងទានៅជនបទ ........ ១៨
១.៧.១. ប្រភេទពូជទា ........ ១៨
១.៧.១.១. ពូជទាក្នុងស្រុក ........ ១៨
១.៧.១.២. ពូជនាំចូល ........ ២១
១.៧.២. តម្រូវការនៃការចាប់ផ្តើមចិញ្ចឹមទា ........ ២២
១.៧.៣. ការផលិតកូនទា ........ ២៨
១.៧.៤. ការចិញ្ចឹមកូនទា ........ ២៩
១.៧.៥. ការគ្រប់គ្រងទាពេញវ័យ ........ ៣២
១.៨. ស្ថិតិផលិតកម្មសត្វនៅកម្ពុជា ........ ៣៨

## ជំពូកទី២

## ស្ថានភាពទូទៅនៃការចិញ្ចឹមទារបស់ លោក ហ៊ឺ ម៉ូរ៉ា

២.១ ទីតាំងភូមិសាស្រ្តកសិដ្ឋាន ........ ៤១
២.២. អំពីម្ចាស់កសិដ្ឋាន ........ ៤១
២.៣. គោលបំណងនៃការចិញ្ចឹមទា ........ ៤២

២.៤. ប្រវត្តិនៃការចាប់ផ្ដើមចិញ្ចឹមទា ........................................................ ៤២
២.៥. សក្តានុពល ........................................................ ៤៣
២.៦. ដំណើរការនៃការរៀបចំកសិដ្ឋាន ........................................................ ៤៣
២.៦.១. បរិស្ថានជុំវិញ ........................................................ ៤៣
២.៦.២. ការជ្រើសរើសពូជទា ........................................................ ៤៣
២.៦.៣. ដំណើរការរៀបចំទ្រុង ........................................................ ៤៤
២.៦.៤. ប្រព័ន្ធទឹក ........................................................ ៤៥
២.៦.៥. ស្រះទឹកសម្រាប់ទាលេង ........................................................ ៤៥
២.៧. សកម្មភាពក្នុងការចិញ្ចឹមទា ........................................................ ៤៦
២.៧.១. សកម្មភាពថែទាំ ........................................................ ៤៦
២.៧.២. សកម្មភាពសម្អាតទ្រុង ........................................................ ៤៧
២.៧.៣. ចំណី ........................................................ ៤៧

## ជំពូកទី៣

## ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

៣.១.បញ្ហាប្រឈម ........................................................ ៤៩
៣.១.១. បញ្ហាជម្ងឺ ........................................................ ៤៩
៣.១.២. បញ្ហាអគ្គិសនី ........................................................ ៤៩
៣.១.៣. បញ្ហាអាកាសធាតុ ........................................................ ៤៩
៣.១.៤. បញ្ហាទីផ្សារ ........................................................ ៥០
៣.១.៥. ការបង្វិលលុយ ........................................................ ៥០
៣.២. ដំណោះស្រាយ ........................................................ ៥០
៣.២.១. បញ្ហាជម្ងឺ ........................................................ ៥០
៣.២.២. បញ្ហាបំណុល ........................................................ ៥១
៣.២.៣. បញ្ហាទីផ្សារ ........................................................ ៥១
៣.២.៤. បញ្ហាអាកាសធាតុ ........................................................ ៥២
៣.២.៥. បញ្ហាអគ្គិសនី ........................................................ ៥២

៣.៣. ប្រវត្តិនៃចំណូល និងចំណាយចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៩ ........................................ ៥២
៣.៤. ការចំណាយទៅលើការចិញ្ចឹម ........................................ ៥៣
៣.៤.១. ការចំណាយលើការធ្វើរោង ឬទ្រុង ........................................ ៥៣
៣.៤.២. ចំណាយសម្រាប់ការទិញទា ........................................ ៥៤
៣.៤.៣. ការចំណាយទៅលើចំណី ........................................ ៥៤
៣.៤.៤. ចំណីគិតជាក្រាមសម្រាប់ទាមួយក្បាលក្នុងមួយថ្ងៃ ........................................ ៥៥
៣.៤.៥. ការចំណាយលើការថែទាំ ........................................ ៥៥
៣.៤.៦. ការចំណាយបន្ទាប់បន្សំ ........................................ ៥៦
៣.៥. ការទូទាត់ចំណាយសរុបក្នុងមួយថ្ងៃ ........................................ ៥៦
៣.៦. ប្រភពចំណូលពីការចិញ្ចឹមទា ........................................ ៥៧
៣.៦.១. ចំណូលពីការលក់អាចម៍ទា ........................................ ៥៧
៣.៦.២. ចំណូលពីការលក់ពងទា ........................................ ៥៨
៣.៦.៣. គណនាចំណូលសរុបក្នុងមួយថ្ងៃ ........................................ ៥៨
៣.៧. ចំណេញសរុបក្នុងមួយថ្ងៃ ........................................ ៥៩
៣.៨.ទិសដៅទៅថ្ងៃអនាគត ........................................ ៥៩

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

១. សេចក្តីសន្និដ្ឋាន ........................................ ៦១
២. ការផ្តល់អនុសាសន៍ ........................................ ៦២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| ពាក្យអក្សរកាត់ | | ការពន្យល់ |
|---|---|---|
| គ.ក្រ | ៖ | គីឡូក្រាម |
| គ.ម | ៖ | គីឡូម៉ែត្រ |
| ម | ៖ | ម៉ែត្រ |
| ម២ | ៖ | ម៉ែត្រការ៉េ |
| ស.ម | ៖ | សង់ទីម៉ែត្រ |
| % | ៖ | ភាគរយ |
| ADB | ៖ | Asian Development Bank<br>ធនាគារអភិវឌ្ឍន៍អាស៊ី |
| CEDAC | ៖ | Centre d´Etude et de Developpement Agricole Cambodgien<br>មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| IMF | ៖ | International Monetary Fund<br>មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Kg | ៖ | គីឡូក្រាម |
| USAID | ៖ | United States Agency for International Development<br>ទីភ្នាក់ងារជំនួយអាមេរិក |

# បញ្ជីតារាង


តារាងទី១ ប្រភពចំណីធម្មជាតិដែលទាអាចស៊ីបាន ....................................................................... ២៤

តារាងទី២ កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺទា ............................................................................ ៣៧

តារាងទី៣ ស្ថិតិសត្វតាមបែបផែនផលិតកម្មពីឆ្នាំ ២០១៤ដល់២០១៨ ............................................ ៤០

តារាងទី៤ ចំណូល និងចំណាយចន្លោះឆ្នាំ ២០១៣ - ២០១៩(គិតជារៀល) ..................................... ៥៣

តារាងទី៥ ការចំណាយលើការសាងសង់រោងចិញ្ចឹមទា និងការជីស្រះ ............................................ ៥៤

តារាងទី៦ ចំនួនទាដែលលោកពូបានទិញនៅឆ្នាំ២០១៩ ............................................................... ៥៤

តារាងទី៧ ការចំណាយលើចំណីសម្រាប់ទា ១០,០០០ក្បាល ....................................................... ៥៤

តារាងទី៨ ការចំណាយលើការថែទាំ ............................................................................................. ៥៥

តារាងទី៩ ចំណូលពីការលក់អាចម៍ទា ............................................................................................ ៥៨

តារាង១០ ចំណូលពីការលក់ពងទា ................................................................................................. ៥៨

# បញ្ជីក្រាភិក

ក្រាភិកទី១  ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម) ឆ្នាំ២០១៤ ដល់ ២០១៨ ............ ៣៩
ក្រាភិកទី២  ផលិតកម្មសត្វសរុបឆ្នាំ ២០១០ ដល់ ២០១៤ ............ ៣៩
ក្រាភិកទី៣  ចំណាយលើការចិញ្ចឹមទាក្នុងមួយថ្ងៃ ............ ៥៧

# បញ្ជីរូប

រូបភាពទី១  វដ្តនៃភាពក្រីក្រ ............ ១៥
រូបភាពទី២  ទាស្រុក ............ ១៩
រូបភាពទី៣  ទាអង្កាម ............ ២០
រូបភាពទី៤  ទាកាប៉ា ............ ២១
រូបភាពទី៥  វ៉ាក់សាំងការពារអាសន្នរោគ ............ ៣៦
រូបភាពទី៦  វ៉ាក់សាំងការពារប៉េស្តទា ............ ៣៧
រូបភាពទី៧  ប្រព័ន្ធទឹកសម្រាប់ទាផឹក ............ ៤៥

# សេចក្តីផ្តើម

សេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនគឺ ពឹងផ្អែកលើវិស័យកសិកម្មច្រើនជាជាងវិស័យផ្សេងទៀត។ ដោយភាពចាំបាច់នៃវិស័យកសិកម្មបែបនេះទើបរាជរដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍បានយកចិត្តទុក ដាក់យ៉ាងខ្លាំងលើវិស័យនេះ ឬហៅថាសេដ្ឋកិច្ចកសិកម្ម ( សំដៅលើការអភិវឌ្ឍសេដ្ឋកិច្ច ដោយប្រើប្រាស់វិស័យកសិកម្មជាឧបករណ៍)។[1] វិស័យកសិកម្មបានរកចំណូលយ៉ាងច្រើនក្នុងសេដ្ឋកិច្ចជាតិ ជាពិសេសក្នុងសេដ្ឋកិច្ចគ្រួសារ និងការចំណាយលើការរស់នៅប្រចាំថ្ងៃ។ សកម្មភាពកសិកម្មទ្រង់ទ្រាយតូច ការចិញ្ចឹមសត្វលក្ខណៈគ្រួសារ បានផ្តល់ជាសក្តានុពលដ៏សំខាន់សម្រាប់ប្រជាជននៅតាមទីជនបទ ស្រុកស្រែចំការ។ ការផ្តោតសំខាន់លើវិស័យកសិកម្មដែលមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងសេដ្ឋកិច្ចរបស់ប្រទេស ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ គឺជាគោលបំណងរួមទៅនឹងគោលបំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ុីដែលហៅកាត់ថា ( ADB ) គឺកាត់បន្ថយភាពក្រីក្រ[2]។ ក៏ដូចគ្នានេះដែររដ្ឋាភិបាលប្រទេសកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងបានជ្រើសវិស័យកសិកម្មជាមុំទីមួយក្នុងការអនុវត្តន៍។

ជាសមិទ្ធផល នៅក្នុងឆ្នាំ ២០១៨ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ២៣,៥% នៃផលិតផលក្នុងស្រុកសរុប ហើយតម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានបន្តកើនដល់ ២១,៩១៣ ប៊ីលានរៀល។ ក្នុងវិស័យនេះក៏មានការចូលរួមនៃអនុវិស័យដែលរួមមាន៖ ផ្នែកដំណាំបានចូលរួម ៥៨,១% ផ្នែកផលិតកម្មសត្វ ១១,២% ផ្នែកជលផល ២៤% និងផ្នែកព្រៃឈើ ៦,៧%។[3]

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា គឺជាប្រទេសតូចមួយ ហើយមានប្រជាជនតិច (ប្រហែលជា ១៧ លាននាក់)។ ប្រទេសនេះទើបតែងើបចេញពីវិបត្តិសង្គ្រាមស៊ីវិល អស្ថេរភាពនយោបាយរយៈពេល ៣ ទសវត្ស៍ ដែលធ្វើឲ្យប្រទេសនេះក្លាយជាប្រទេសក្រីក្រ និងទទួលការបំផ្លិចបំផ្លាញជាងគេនៅអាស៊ីអាគ្នេយ៍។ ប្រជាជនកម្ពុជាប្រហែល ៨០ ភាគរយ រស់នៅតាមតំបន់ជនបទ ហើយ ៧១ ភាគរយ ពឹងផ្អែកជាចម្បងលើវិស័យកសិកម្ម និងបសុសត្វសម្រាប់ជីវភាពរស់នៅ។ បសុសត្វ និងបសុបក្សី គឺជាសកម្មភាពទីពីរដែលធ្វើឡើងដោយគ្រួសារកសិករ បន្ទាប់ពីការងារដាំដុះ។ កសិកម្មចិញ្ចឹមសត្វ បានធ្វើឲ្យជីវិតប្រជាជននៅតាមទីជនបទ និងជួយបន្ធូរ

[1] សាស្ត្រាចារ្យ ឈុន ពហុ, «សេដ្ឋកិច្ចកសិកម្ម», ត្រង់មេរៀន ទ្រឹស្តីមូលដ្ឋានជុំវិញការអភិវឌ្ឍកសិកម្ម

[2] ASAIN DEVELOPMENT BANK (ADB), «វិស័យកសិកម្ម និងការអភិវឌ្ឍនៅកម្ពុជា» (ខែកញ្ញា ឆ្នាំ២០០៩)

[3] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, «ហិរញ្ញប្បទានក្នុងវិស័យកសិកម្ម និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មសម្រាប់កសិកម្មខ្នាតតូច» (ខែកញ្ញា ឆ្នាំ២០១០)

បន្ថយការចំណាយនៅក្នុងគ្រួសារ ដោយសារពួកគេបរិភោគច្រើននៃផលដែលពួកគេផលិតបាន។ បន្ថែមលើការកាត់បន្ថយចំណាយក្នុងគ្រួសារ ការចិញ្ចឹមសត្វបានដើរតួនាទីយ៉ាងសំខាន់ជាប្រភពចំណូលក្នុងគ្រួសារដែលប្រមាណជា ៧៥ ភាគរយ នៃគ្រួសារកាន់កាប់ការងារកសិកម្មក្នុងប្រទេសកម្ពុជា បានចិញ្ចឹមបសុសត្វ និងបសុបក្សីនៅក្នុងជំរឿនកសិកម្មតាមខេត្តក្នុងឆ្នាំ ២០១៣។ ដោយសង្កេតឃើញថា ផលិកម្មកសិកម្មពិសេសការចិញ្ចឹមសត្វនៅតាមទីជនបទនៅតែមានកម្រិតទាបជាងសក្តានុពលរបស់វានៅឡើយ ដោយសាតែផលិតភាពនៅទាប ភាពងាយរងគ្រោះពីជំងឺ ការប្រែប្រួលអាកាសធាតុ សមត្ថភាពរបស់កសិករក្នុងការប្រើប្រាស់បច្ចេកទេសចិញ្ចឹម ការថែទាំ ផ្តល់ចំណីនៅមានកម្រិត។

## ២. ចំណោទបញ្ហា

ការស្រាវជ្រាវនេះបានបង្ហាញឲ្យឃើញកាន់តែច្បាស់អំពីអត្ថប្រយោជន៍ ការចូលរួម ក៏ដូចជាតួនាទីនៃការចិញ្ចឹមសត្វក្នុងសេដ្ឋកិច្ចគ្រួសារ។ បន្ថែមលើសពីនេះទៅទៀត ការស្រាវជ្រាវមួយនេះអាចជាសំអាងមួយក្នុងការលើកបង្ហាញពីស្ថានភាពខ្លះៗនៃវិស័យកសិកម្មនៅកម្ពុជា ជាពិសេស គឺស្ថានភាពនៃការចិញ្ចឹមសត្វ។ យល់ដឹងបន្ថែមពី៖

តើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការចិញ្ចឹមទា?

តើគួរចិញ្ចឹមដោយប្រើវិធីសាស្ត្រ ទីកន្លែង ស្ថានភាព និងអាកាសធាតុបែបណា?

តើគួររកទីផ្សារលក់ទានៅកន្លែងណា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះគឺសំដៅយកការសិក្សាអោយស៊ីជម្រៅ នឹងរកវិធីសាស្ត្រអ្វីដែលធ្វើអោយការចិញ្ចឹមសត្វទារឹតតែមានប្រសិទ្ធភាពជាងមុន ក៏ជាការសិក្សាអំពីហានិភ័យដែលត្រូវជួបប្រទះក្នុងការចិញ្ចឹមសត្វទា ព្រមទាំងរកអោយឃើញនូវដំណោះស្រាយដែលល្អបំផុត ហើយនឹងបង្ហាញអោយឃើញពីផលចំណេញនៃការចិញ្ចឹមទា ដើម្បីធ្វើអោយសេដ្ឋកិច្ចគ្រួសារកាន់តែមានភាពល្អប្រសើរឡើងផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើដំណើរការនៃការចិញ្ចឹមសត្វទារបស់ម្ចាស់កសិដ្ឋានមួយឈ្មោះ ហ៊ី ប៉ូរ៉ា ស្ថិតក្នុងនៅភូមិទ្រាសរ ឃុំខ្នាសរ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដោយធ្វើការលំអិតអំពីបញ្ហាប្រឈម ដំណោះស្រាយ ការស្វែងរកទីផ្សារ និងផលចំណេញបានមកពីការចិញ្ចឹមទាពីឆ្នាំ ២០១៥ ដល់ ២០១៩។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការស្រាវជ្រាវទៅលើប្រធាននេះ យើងខ្ញុំពឹងផ្អែកទៅលើប្រភពទិន្នន័យពីរ គឺទិន្នន័យចម្បង ( Primary Data ) និងទិន្នន័យបន្ទាប់បន្សំ ( Secondary Data )។

- **ទិន្នន័យចម្បង៖** ជាទិន្នន័យដើមដែលបានមកពីការសម្ភាស៍ផ្ទាល់ជាមួយម្ចាស់កសិដ្ឋាន ដោយប្រើប្រភេទកម្រងសំណួរបែប និទានកថា ( Narrative ) និងប្រវិត្តផ្ទាល់មាត់ ( Oral Histories )។ ទិន្នន័យនេះ គឺផ្តោតចម្បងទៅលើរបៀបរបបនៃការចិញ្ចឹម កត្តាប្រឈម ដំណោះស្រាយ កត្តាទីផ្សារ និងប្រាក់ចំណេញដែលទទួលបានពីការចិញ្ចឹមទា ដើម្បីជួយអោយជីវភាពគ្រួសារកាន់តែប្រសើរឡើង នឹងរួចផុតពីជីវភាពក្រីក្រ។ ដោយសារតែពេលវេលាដែលត្រូវធ្វើការស្រាវជ្រាវមានរយៈពេលខ្លី គួបផ្សំនឹងធនធានថវិកាដែលត្រូវចំណាយនៅមានកម្រិត និងដោយហេតុថាទំហំនៃទីតាំងដែលនឹងធ្វើការសិក្សាសមល្មមនឹងទទួលយកបាន អាស្រ័យហេតុនេះហើយយើងខ្ញុំសម្រេចជ្រើសរើសយកតែមួយកសិដ្ឋានប៉ុណ្ណោះដើម្បីធ្វើការសិក្សា។ ការប្រមូលទិន្នន័យគិតចាប់ពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០២០។

ក្រោយពីទទួលបានទិន្នន័យ ពួកយើងធ្វើការបញ្ចូលទិន្នន័យទៅក្នុងកម្មវិធី Excel ដើម្បីធ្វើការវិភាគទៅតាមអ្វីដែលយើងបានគ្រោងទុក ។ ដើម្បីការវិភាគកាន់តែមានន័យខ្លឹមសារ និងធ្វើការអោយវិភាគអោយកាន់តែស៊ីជម្រៅបន្ថែមទៀត ។

- **ទិន្នន័យបន្ទាប់បន្សំ៖** ក្រៅពីទិន្នន័យចម្បង ដើម្បីឲ្យរបាយការណ៍កម្មសិក្សាមួយនេះកាន់តែមានភាពជាក់លាក់ យើងក៏បានធ្វើការស្រាវជ្រាវបន្ថែមលើទិន្នន័យដែលមានស្រាប់ដូចជា សៀវភៅ ឯកសារបច្ចេកទេស និងរបាយការណ៍ចេញផ្សាយនានាដែលអាចស្វែងរកបាន តាមរយៈគេហទំព័ររបស់ធនាគារពិភពលោកប្រចាំនៅកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងឯកសារតាមរយៈគេហទំព័រ (Website) ដែលមានប្រភពច្បាស់លាស់ សេចក្តីប្រកាស ការចុះស្រាវជ្រាវផ្ទាល់ ដើម្បីជាជំនួយ និងធ្វើជាឯកសារយោងផងដែរ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានផ្តល់ចំណេះដឹងទាក់ទងទៅនឹងការអភិវឌ្ឍជីវភាពសេដ្ឋកិច្ចគ្រួសារ តាមរយៈការចិញ្ចឹមទា ព្រមទាំងបានយល់ដឹងអំពីបញ្ហាប្រឈមនានា ដំណោះស្រាយល្អៗ និងផលប្រយោជន៍សេដ្ឋកិច្ចគ្រួសារ។ ក្រោយបញ្ចប់ការស្រាវជ្រាវនេះ យើងសង្ឃឹមថារាល់បណ្តាស្ថាប័ននានា មិនថារដ្ឋ ឬឯកជន លើកកម្ពស់គាំទ្រនូវផលិតផលក្នុងស្រុក និងបង្កើនការចិញ្ចឹមសត្វនៅក្នុងតំបន់របស់យើងអោយកាន់តែប្រសើរឡើង។ មួយវិញទៀត សមទ្ធិផលនៃការស្រាវជ្រាវមួយនេះ នឹងក្លាយជាប្រយោជន៍សម្រាប់អ្នកសិក្សា

គ្រប់ៗរូប ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមពីការចិញ្ចឹមទាដែលប្រកបដោយការការពារ និងទទួលបានផលខ្ពស់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានចែកចេញជា ៣ ជំពូកៈ

- សេចក្តីផ្តើមៈ លំនាំបញ្ហា, ចំណោទបញ្ហា និងចំណូលបញ្ហា
- ជំពូកទី ១ រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ និងបច្ចេកទេសនៃការចិញ្ចឹមទានៅជនបទៈ រៀបរាប់ពន្យល់អំពីនិយមន័យនៃពាក្យអភិវឌ្ឍន៍ ទ្រឹស្តីមួយចំនួនរបស់សេដ្ឋវិទូ និងទស្សនៈវិទូអំពីការអភិវឌ្ឍសេដ្ឋកិច្ច កត្តាដែលជំរុញ និងកត្តារាំងស្ទះដល់ការអភិវឌ្ឍ តួនាទីរបស់កសិកម្ម និងសមទ្ធិផលនៃផលិតកម្មសត្វនៅកម្ពុជាចាប់តាំងពីឆ្នាំ២០១០ ដល់ ២០១៨។ លើសពីនេះទៀតនោះ យើងក៏បានធ្វើការសិក្សាស្វែងយល់អំពីបច្ចេកទេសសំខាន់ៗដែលចាំបាច់ទាក់ទងនឹងការចិញ្ចឹមទានៅជនបទ។
- ជំពូកទី២ ស្ថានភាពទូទៅ និងដំណើរការចិញ្ចឹមទានៅកសិដ្ឋានៈ សិក្សាលើលក្ខណៈទូទៅដូចជាប្រវិត្តនៃការបង្កើតកសិដ្ឋាន ទីតាំង បរិស្ថាន វិធីសាស្ត្រ និងបច្ចេកទេសនៃការចិញ្ចឹមទា ( ការជ្រើសរើសពូជ ការធ្វើទ្រុង ការថែទាំ ការផ្តល់ចំណី...)។ បន្ថែមពីលើនេះទៀតនឹងមានបង្ហាញពីសក្តានុពលរបស់កសិដ្ឋានដែលបានលើកមកធ្វើការសិក្សា។
- ជំពូកទី៣ វិភាគលើលទ្ធផលនៃការស្រាវជ្រាវៈ ក្នុងជំពូកចុងក្រោយនេះនឹងបង្ហាញពីការសិក្សាដោយធ្វើការរបកស្រាយពីបញ្ហាប្រឈមដែលបានកើតមានឡើងក្នុងដំណើរការនៃការចិញ្ចឹមសត្វទា និងបកស្រាយបន្ថែមទាក់ទងទៅនឹងចំណូលចំណាយរបស់កសិដ្ឋានទាំងមូល។
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍ៈ ជាចំណុចចុងក្រោយបង្អស់ក្នុងសារណាមួយនេះដែលនឹងធ្វើការសន្និដ្ឋាន សង្ខេបប្រធានបទឡើងវិញ ព្រមទាំងភ្ជាប់ជាមួយនឹងមតិយោបល់មួយចំនួនដើម្បីកែតម្រូវសម្រាប់ចំណុចខ្វះខាត និងជាយោបល់បន្ថែមក្នុងន័យជាជំនួយក្នុងការអភិវឌ្ឍឲ្យបានកាន់តែប្រសើរឡើង។
- ឯកសារយោង

# ជំពូកទី១

# ការសិក្សាអំពីទ្រឹស្តី

## ១.១. និយមន័យការអភិវឌ្ឍ

ការអភិវឌ្ឍ គឺជាដំណើរការនៃការពង្រីកជម្រើសរបស់មនុស្ស។[4]

ការអភិវឌ្ឍ គឺមានន័យថាជាសេចក្តីរីកចម្រើនក្រៃលែង។[5]

ការអភិវឌ្ឍ គឺជាដំណើរការដែលនរណាម្នាក់ ឬអ្វីមួយលូតលាស់ ផ្លាស់ប្តូរទៅជាកាន់តែជឿនលឿនប្រសើរឡើង។[6]

ការអភិវឌ្ឍ គឺជាដំណើរការនៃការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ និងស្ថាប័ន ដែលបង្កលក្ខណៈងាយស្រួល ឬអំណោយផលដល់ការធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន និងធ្វើឲ្យកំណើនសេដ្ឋកិច្ចបន្តបានយូរ ឬអាចនិយាយបានម្យ៉ាងទៀតថា ការអភិវឌ្ឍ ជាការបង្កលក្ខខណ្ឌឲ្យសេដ្ឋកិច្ចមានចីរភាព។

ក្នុងន័យសេដ្ឋកិច្ច ការអភិវឌ្ឍ គឺទាក់ទងទៅនឹងការកែរលំអនៅក្នុងស្ថានភាពសេដ្ឋកិច្ចរបស់មនុស្ស គុណភាពរស់នៅល្អប្រសើរជាងមុន អត្រាកំណើនចំណូលក្នុងពលរដ្ឋម្នាក់ៗ ឬ ផលិតផលជាតិក្នុងពលរដ្ឋម្នាក់ៗ ក៏ដូចជានៅក្នុងប្រទេសទាំងមូល។ ការអភិវឌ្ឍត្រូវបានលើកឡើងក្នុងទម្រង់នៃការកាត់បន្ថយនិងលុបបំបាត់នូវភាពក្រីក្រ វិសាលភាពនិងនិកម្មភាពជាដើម។

ការអភិវឌ្ឍអាចស្តែងចេញតាមមាត្រដ្ឋានចំនួន ៥ គឺ៖

**១. មាត្រដ្ឋានសេដ្ឋកិច្ច៖** ការអភិវឌ្ឍ គឺជាកំណើនសេដ្ឋកិច្ចដែលត្រូវផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកែលំអនិងពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធថាមពល ប្រព័ន្ធផ្គត់ផ្គង់ទឹក ការពង្រីកវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងសេវាកម្មផ្សេងៗទៀត។

**២. មាត្រដ្ឋានសង្គម៖** ការអភិវឌ្ឍ គឺជាការផ្លាស់ប្តូរផ្នែកសង្គមកិច្ចដូចជា សមធម៌ និងយុត្តិធម៌តាមរយៈការកាត់បន្ថយភាពក្រីក្រដោយធ្វើឲ្យគម្លាតរវាងអ្នកមាន និងអ្នកក្រសមល្មមអាចទទួលយកបាន លើកតម្កើននារីភេទជាពិសេសនោះបានធានានូវសមភាពយេនឌ័ររវាងបុរស និងស្ត្រីក្នុងសង្គម។

**៣. មាត្រដ្ឋាននយោបាយ៖** ការអភិវឌ្ឍត្រូវស្ថិតនៅក្នុងបទដ្ឋាននយោបាយសមស្របសម្រាប់ជំរុញវឌ្ឍនភាពតាមរយៈច្បាប់ និងធានានូវការគោរពសិទ្ធិមនុស្ស។

[4] United Nations Development Program, 1991, p 28

[5] វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, វចនានុក្រមខ្មែរ, ព.ស.២៥១១, គ.ស.១៩៦៧

[6] Cambridge Dictionary, https://dictionary.cambridge.org/dictionary/english/development

**៤. មាត្រដ្ឋានបរិស្ថាន៖** ការអភិវឌ្ឍត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃការយកចិត្តទុកដាក់ថែរក្សាគុណភាពបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឲ្យបានស្ថិតស្ថេរ។

**៥. មាត្រដ្ឋានធនធានមនុស្ស៖** ការអភិវឌ្ឍផ្សារភ្ជាប់ទៅនឹងការកើនឡើងនៃផលិតភាពពលកម្ម និងកម្រិតចេះដឹងនៃប្រជាជន ការផ្លាស់ប្តូរបទពិសោធន៍និងបច្ចេកវិទ្យា ការផ្តល់សេវាសុខភាពសាធារណៈ និងការអប់រំសម្រាប់ប្រជាជនទូទៅ។[7]

## ១.២. ទ្រឹស្តីការអភិវឌ្ឍ

អភិវឌ្ឍន៍ គឺជាពាក្យមួយដែលមានន័យទូលំទូលាយ ហើយត្រូវបានឲ្យនិយមន័យខុសៗគ្នាទៅតាមសម័យកាលនីមួយៗ និងទស្សនៈរបស់មនុស្សម្នាក់ៗ។ ខាងក្រោមនេះជាទ្រឹស្តីការបកស្រាយរបស់អ្នកប្រាជ្ញមួយចំនួនដើម្បីអោយយល់បានកាន់តែច្បាស់ពីពាក្យ អភិវឌ្ឍន៍ នេះ ៖

### ១.២.១. ទ្រឹស្តីរបស់លោក Rostow

លោក Rostow បានឲ្យនិយមន័យថាគ្រប់ប្រជាជាតិទាំងអស់អាចនឹងឈានទៅរកកម្រិតនៃការអភិវឌ្ឍ ប្រសិនបើគេដើរតាមគន្លងប្រទេសអភិវឌ្ឍន៍ ហើយរក្សាលក្ខខណ្ឌក្នុងការធានាឲ្យមានសេដ្ឋកិច្ចបានយូរអង្វែង ម្យ៉ាងវិញទៀតលុះត្រាតែប្រទេសទាំងនោះត្រូវឆ្លងកាត់ ៥ ដំណាក់កាលជាចម្បង។[8]

#### ក. សង្គមប្រពៃណី

ប្រភពចំណូលតែមួយគត់ គឺកសិកម្ម ( កសិកម្មបែបគ្រួសារគ្រប់គ្រាន់តែចិញ្ចឹមជីវិត ) ហើយប្រជាជនមិនមានគំនិតផ្លាស់ប្តូរអ្វីៗទាំងអស់ គឺបណ្តោយទៅតាមយថាកម្ម។ ទំហំដើមទុនមានកំណត់ និងមានគុណភាពទាបបណ្តាលឲ្យផលិតភាពទាប ហើយទិន្នផលនៅសល់តិចតួចក្នុងការលក់នៅលើទីផ្សារក្នុង និងក្រៅប្រទេស។ លទ្ធភាពក្នុងការជំរុញឲ្យមានការកែប្រែសង្គម និងទំនាក់ទំនងផលិតកម្មស្ទើរសូន្យ មានការប្រកាន់ឋានានុក្រមខ្លាំងនៅក្នុងទំនាក់ទំនងសង្គម ពោលគឺជាប្រទេសដែលមានការរីកចម្រើនតិចតួចបំផុត។

#### ខ. សង្គមដែលស្ថិតក្នុងចំណុចរបត់នៅរកការអភិវឌ្ឍ

ការធ្វើបដិវត្តនៅក្នុងផ្នត់គំនិត ( កែប្រែទំនាក់ទំនងក្នុងការផលិត ) មានការកើនឡើងការវិនិយោគដែលធ្វើឲ្យមានផលចំណេញដល់សង្គម។ ការផ្លាស់ប្តូរនេះត្រូវបានដាក់ចេញដោយ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ ការធ្វើឲ្យប្រសើរឡើងផ្នែកបច្ចេកវិទ្យា និងការធ្វើឲ្យប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធលើអចលនវត្ថុ ព្រមទាំងធ្វើឲ្យកើនឡើង សន្សំ និងវិនិយោគ ជាប្រទេសដែលស្ថិតនៅចន្លោះអន្តរកាលនៃការអភិវឌ្ឍ។

[7] សារណាបញ្ចប់ការសិក្សា, កម្មវិធីអភិវឌ្ឍន៍របស់ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ, ២០០២-២០០៦

[8] Michael P. Todaro, Stephen C. Smith. (2007). Economic Development, pp111

**គ. ដំណាក់កាលនៃការចាប់ផ្តើមអភិវឌ្ឍន៍**

វិស័យចលករ ( Matric ) នៃសេដ្ឋកិច្ចបានលេចរូបរាងឡើង និងរីកចម្រើនធំធាត់ជាលំដាប់ បញ្ហានៃកំណើនសេដ្ឋកិច្ចដែលធ្លាប់តែជាបញ្ហាលំបាកពីមុនបានក្លាយទៅជាបញ្ហាសាមញ្ញ ហើយអាចរក្សាបាននូវស្ថេរ ភាពសេដ្ឋកិច្ចដោយស្វ័យប្រវត្តិ។

**ឃ. ដំណាក់កាលចាស់ទុំ**

ការអភិវឌ្ឍបានដំណើរការនៅគ្រប់ទិសទីពាសពេញផ្ទៃប្រទេស ការផ្ទេរការផលិតពីវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម។ ការអភិវឌ្ឍកាន់តែបន្តដំណើរទៅមុខ កាន់តែជឿនលឿន រាល់ឧស្សាហកម្មដែលមានវ័យចំណាស់ត្រូវបានផ្លាស់ប្តូរឲ្យកាន់តែទំនើបថែមទៀត ឬហៅថាឧស្សាហកម្មថ្មី។

**ង. ដំណាក់កាលនៃបម្រើបម្រាស់ទ្រង់ទ្រាយធំ**

ការអភិវឌ្ឍបានធ្វើឲ្យប្រទេសជាតិកាន់តែទំនើប សម្បូរបែប ផលិតកម្មទំនិញ និងសេវាកម្មបានកំពុងតែដំណើរការយ៉ាងរលូន។ ដោយសារតែចំណូលរបស់ប្រជាជនមានការកើនឡើង ជាហេតុធ្វើឲ្យប្រជាជនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់នូវទំនិញ និងសម្ភារៈតាមដែលពួកគេត្រូវការ ទាំងនេះបានសរបញ្ជាក់ពីការប្រើប្រាស់ជាលក្ខណៈទ្រង់ទ្រាយធំនៅក្នុងប្រទេស និងការកើនឡើងនៃកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។ ត្រង់ចំណុចនេះផងដែរក៏បានបញ្ជាក់ថា៖

- ការអភិវឌ្ឍកំពុងតែចាប់ផ្តើមដំណើរការខ្លាំង
- សេចក្តីត្រូវការជាមូលដ្ឋានត្រូវបានដោះស្រាយជាស្ថាពរ
- ការអភិវឌ្ឍវិស័យសុខុមាលភាពសង្គម ហើយអំណាចសេដ្ឋកិច្ចត្រូវបានពង្រីក។

**១.២.២. ទ្រឹស្តីរបស់លោក** Michael P. Tadora

ការអភិវឌ្ឍអាចសម្រេចទៅបាន និងប្រកបដោយចីរភាព គឺផ្តើមចេញពីការអភិវឌ្ឍនៃតំបន់ជនបទដែលផ្តោតជាពិសេសទៅលើវិស័យកសិកម្ម។ លោកក៏បានបន្ថែមទៀតថា ប្រជាជាតិមួយអាចឈានទៅដល់ការអភិវឌ្ឍយ៉ាងហោចណាស់ត្រូវមានកត្តាបីគឺ៖ ការពន្លឿន Output តាមរយៈការធ្វើកំណែទម្រង់ផ្នែកស្ថាប័ន និងបច្ចេកវិទ្យា ដែលត្រូវរៀបចំឡើងដើម្បីបង្កើតផលិតភាពសម្រាប់កសិកម្មតូចតាច បង្កើនតម្រូវការក្នុងស្រុកសម្រាប់ផលិតភាពកសិកម្មដែលមានប្រភពពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារជាយក្រុង សកម្មភាពអភិវឌ្ឍន៍ជនបទ ដើម្បីពង្រីកកម្លាំងពលកម្មមិនមែនកសិកម្ម និងវិស័យដ៏ទៃទៀតដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីសមាគមន៍កសិកម្ម។

**១.២.៣. គំរូររបស់លោក** W. Arthhur Lewis (1950s)

នៅក្នុងគំរូររបស់លោក Lewis ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច គឺជាទ្រឹស្តីនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ។ គំរូរនេះបានក្លាយជាទ្រឹស្តីទូទៅនៃដំណើរការអភិវឌ្ឍសម្រាប់ប្រទេសកំពុងអភិវឌ្ឍលើភាពលើសកម្លាំងពលកម្មនៅក្នុងកំឡុងទសវត្ស ១៩៦០ និងដើមទសវត្ស ១៩៧០។ លោក Lewis បានបែងចែកប្រទេសជាពីរវិស័យគឺៈ

**ក. វិស័យកសិកម្ម** ៖ វិស័យនេះគឺគ្រាន់តែតែចិញ្ចឹមជីវិតនៅជនបទដោយប្រើប្រាស់ពលកម្មលើសកម្រិតដែលធ្វើឲ្យផលិតភាពពលកម្មសូន្យ ( Zero Marginal Labor Productivity )។ ផលិតភាពនៃកម្លាំងពលកម្មទាប ដូច្នេះវាអាចទៅរួចដើម្បីដកកម្លាំងពលកម្មដែលលើស ពីវិស័យកសិកម្មទៅបម្រើការក្នុងវិស័យឧស្សាហកម្មដោយមិនមានការបាត់បង់នូវទិន្នផលកសិកម្មឡើយ។

**ខ. វិស័យឧស្សាហកម្ម** ៖ គឺជាវិស័យទំនើបនៅក្នុងទីក្រុង ដែលត្រូវបានបញ្ចូលនូវកម្លាំងពលកម្មដែលលើស និងត្រូវបានដកចេញពីវិស័យកសិកម្ម។ គំរូរនេះ គឺជាដំណើរការនៃការផ្ទេរពលកម្មពីវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម ក្នុងគោលបំណងនៃការបង្កើនផលិតភាពកសិកម្ម និងបង្កើនពលកម្មក្នុងវិស័យឧស្សាហកម្ម។ តាមរយៈការធ្វើបែបនេះផងដែរ បាននាំមកនូវអត្រាវិនិយោគ និងការកើនឡើងនូវមូលធននៅក្នុងវិស័យឧស្សាហកម្មយ៉ាងច្រើន។

## ១.៣. គោលបំណង និងគោលដៅនៃការអភិវឌ្ឍ

ប្រទេសនៅលើពិភពលោកនេះត្រូវបានបែងចែកជាពីរ គឺប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ឬក៏អាចហៅថាប្រទេសតតិយលោក។ ប្រទេសទាំងពីរនេះរមែងមានចរិកលក្ខណៈខុសគ្នាទាំងសេដ្ឋកិច្ច និងរចនាសម្ព័ន្ធនៃការរស់នៅរបស់ប្រជាជន ប៉ុន្តែអ្វីដែលដូចគ្នានោះ គឺការខិតខំដើម្បីទទួលបាននូវការអភិវឌ្ឍ។ ខាងក្រោមនេះគឺជាគោលដៅ និងគោលបំណងនៃការអភិវឌ្ឍៈ

### ១.៣.១. គោលបំណងនៃការអភិវឌ្ឍ

ការអភិវឌ្ឍមានគោលបំណង ៣ គឺៈ[9]

១. ដើម្បីឆ្ពោះទៅកាន់ការកាត់បន្ថយភាពក្រីក្រ ភាពមិនស្មើគ្នាក្នុងសង្គម និងភាពគ្មានការងារធ្វើ

២. ផ្តល់ជូនកម្រិតរស់នៅមួយខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន នូវលើវិស័យអប់រំ សុខភាព ទីជម្រក និងស្បៀងអាហារ

---

[9] មេរៀនសាស្ត្រាចារ្យ ឌុយ ចាន់ឌីណា«សេដ្ឋកិច្ចអភិវឌ្ឍ១»(២០១៩), slide ២៩

៣. ផ្តល់ជូននូវឱកាស ទាំងឱកាសសេដ្ឋកិច្ច ( Economic opportunity ) និងឱកាសសង្គម ( Social opportunity )

- ឱកាសសេដ្ឋកិច្ច គឺជាការផ្តល់ជូននូវឱកាសដើម្បីវិនិយោគ ដើម្បីបង្កើតលុយ ពង្រីកអាជីវកម្ម ( ដោយផ្តល់ឱកាសអោយអាយសហគ្រិនទទួលបាននូវកម្ចីដើម្បីបង្កើតជាអាជីវកម្មខ្នាតតូច ) និងឱកាសក្នុងការស្វែងរកការងារធ្វើ។

- ឱកាសសង្គម គឺជាការផ្តល់ឱកាសដើម្បីចូលរួមក្នុងសកម្មភាពនយោបាយ ឱកាសដើម្បីបញ្ចេញមតិជាសាធារណៈ និងចូលរួមក្នុងការអភិវឌ្ឍប្រទេស។

### ១.៣.២ គោលដៅនៃការអភិវឌ្ឍ

ការអភិវឌ្ឍក្នុងសង្គមមានគោលដៅ ៣ គឺ៖[10]

- ពង្រីក និងបង្កើននូវការបែងចែកសេចក្តីត្រូវជាមូលដ្ឋានដូចជា អាហារ ជំរក សម្លៀកបំពាក់ សុខភាព និងការគាំពារ
- លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ពង្រីក និងផ្តល់ឲ្យនូវជម្រើសសេដ្ឋកិច្ច និងសង្គមទៅដល់បុគ្គលម្នាក់ៗ និងជាតិទាំងមូល ។

## ១.៤. កត្តាជំរុញការអភិវឌ្ឍ

សេដ្ឋវិទូបានទទួលយល់ស្របលើកត្តា៤យ៉ាង គឺកត្តាធនធានមនុស្ស កត្តាធនធានធម្មជាតិ កត្តាមូលធន និងកត្តាបច្ចេកវិទ្យា ជាកត្តាសំខាន់ដែលជំរុញខ្លាំងដល់ការអភិវឌ្ឍ។ ប្រទេសដែលបានទទួលស្គាល់ពីសារៈសំខាន់នៃកត្តាទាំង ៤ ដែលជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ច និងមានអត្រាកំណើនខ្ពស់ជាងមុន និងកម្រិតជីវភាពរស់នៅប្រសើរសម្រាប់ប្រជាជនរបស់ពួកគេ។ ការច្នៃប្រឌិតបច្ចេកវិទ្យា និងការអប់រំបន្ថែមសម្រាប់កម្មករធ្វើឲ្យប្រសើរឡើងនូវលទ្ធផលសេដ្ឋកិច្ចនាំឲ្យមានការរស់នៅល្អប្រសើរសម្រាប់មនុស្សគ្រប់រូប។ តាមរយៈការកើនឡើងនៃផលិតភាពការងារបានបង្កភាពងាយស្រួលជាងមុនក្នុងការសំចៃបាននៅពេលវិនិយោគដោយការប្រើប្រាស់កម្លាំងពលកម្មតិច។ កត្តាទាំងនោះសម្តែងចេញក្រោមរូបរាងជាច្រើនដូចជាធនធានមនុស្ស ( កម្លាំងពលកម្ម ការអប់រំ វិន័យ ជំនាញ....) ធនធានធម្មជាតិ ( ដី រ៉ែ ទឹក.... ) មូលធន ( ម៉ាស៊ីន អគារ រោងចក្រ ដើមទុន....) និងបច្ចេកវិទ្យា ( ផ្នែកវិទ្យាសាស្ត្រ វិស្វកម្ម....)។

[10] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាសាស្ត្រាចារ្យណែនាំ បណ្ឌិត ឌុយ ចាន់ឌីណា,តាក់តែងដោយនិស្សិត សួន ស៊ីវហ៊ាន , « ការអភិវឌ្ឍវិស័យចិញ្ចឹមមាន់សាច់នៅក្នុងឃុំដំណាក់អំពិល» (ឆ្នាំ ២០១១)

### ១.៤.១. កត្តាធនធានមនុស្ស

ធនធានមនុស្សមានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍដែលស្ថិតក្នុងគោលបំណងដើម្បីមនុស្ស និងសង្គមមនុស្ស។ យ៉ាងណាមិញនាញ ការអប់រំ និងការបណ្តុះបណ្តាលកម្លាំងពលកម្មមានឥទ្ធិពលយ៉ាងសំខាន់ទៅលើកំណើននៃការអភិវឌ្ឍ។ ការប្រើប្រាស់កម្លាំងពលកម្មដែលមានជំនាញ និងមានការបណ្តុះបណ្តាលត្រឹមត្រូវគឺនាំឲ្យមានផលិតភាពការងារ និងគុណភាពខ្ពស់ជាងការប្រើប្រាស់កម្លាំងពលកម្មដែលខ្វះជំនាញ និងមិនមានការសិក្សាត្រឹមត្រូវ។ សេដ្ឋវិទូជាច្រើនជឿថា ការដែលមានជំនាញ មានចំណេះ គឺជា ធាតុចូល (Input) ដ៏សំខាន់ជាងគេបំផុតនៅក្នុងផលិតកម្ម ហើយគឺជាកត្តាសំខាន់មួយដើម្បីឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្នុងផលិតកម្មមួយគេអាចទិញ ឬដាក់បញ្ចូលនូវធាតុចូលសំខាន់ៗដូចជា មូលធន វត្ថុធាតុដើម បច្ចេកវិទ្យាដែលស្ថិតក្រោមរូបភាពជាច្រើនដូចជា អគារ គ្រឿងចក្រ ឧបករណ៍ប្រើប្រាស់។ល។ ប៉ុន្តែដើម្បីប្រើប្រាស់នូវធនធានទាំងនោះឲ្យមានប្រសិទ្ធភាព និងអស់ពីលទ្ធភាព គឺចាំបាច់ទាមទារឲ្យមានអ្នកប្រើដែលឆ្លាតវៃ មានចំណេះដឹង និងការបណ្តុះបណ្តាលត្រឹមត្រូវ នោះគឺធនធានមនុស្ស។

### ១.៤.២. កត្តាធនធានធម្មជាតិ

ធនធានធម្មជាតិ ជាធនធានដែលបង្កើតឡើងដោយធម្មជាតិ កើតឡើងដោយឯកឯង ហើយត្រូវបានយកមកប្រើជាប្រយោជន៍ក្នុងសេដ្ឋកិច្ច។ ធនធានទាំងនោះមាននៅគ្រប់ទីកន្លែងមិនថានៅ លើដី លើអាកាស ក្រោមដី និងក្រោមទឹក។ ធនធានទាំងអស់នេះត្រូវបានគេចាត់ទុកជាវត្ថុមានតម្លៃ និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រើប្រាស់ប្រកបទៅដោយប្រសិទ្ធភាព ដោយហេតុថាមានធនធានមួយចំនួនជាធនធានកម្រ និងមិនកើតឡើងវិញ។ ធនធានធម្មជាតិត្រូវបានគេយកមកប្រើជាវត្ថុធាតុដើមក្នុងដំណើរការផលិតកម្មដើម្បីផលិតផលិតផលសម្រេចដើម្បីផ្គត់ផ្គង់ដល់ការរស់នៅ និងដើម្បីអភិវឌ្ឍន៍លើគ្រប់វិស័យ និងស្ថាប័ននានា។ ធនធានធម្មជាតិ ជាធនធានដែលមានសារៈសំខាន់បំផុតក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងឧស្សាហកម្មដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូររបស់មនុស្ស និងសម្ភារៈ។ល។

### ១.៤.៣. កត្តាមូលធន

ហេតុអ្វីបានជាគេចាត់ថ្នាក់មូលធនជាកត្តាចូលរួមមួយដែលជំរុញកំណើននៃការអភិវឌ្ឍ?

ដំណើរការនៃការអភិវឌ្ឍត្រូវមានការវិនិយោគដែលជាធាតុផ្សំ។ ទន្ទឹមគ្នានេះដែរ ដើម្បីវិនិយោគទៅបានទាមទារឲ្យមានមូលធនគ្រប់គ្រាន់។ ប្រទេសដែលមានចំណូលខ្ពស់មានមូលធនច្រើន ជាហេតុធ្វើឲ្យពួកគេមានផលិតភាពខ្ពស់។ មូលធន គឺជាប្រភពដែលនាំឲ្យមានកត្តាផលិតកម្ម និងជាប្រភពនៃតម្រូវការចាំបាច់សម្រាប់មនុស្ស ហើយវាជួយឲ្យមានភាពប្រសើរឡើងនៃប្រាក់ចំណូល និងគុណភាពនៃការរស់នៅរបស់

មនុស្សដើម្បីអភិវឌ្ឍន៍។ មូលធនកើនឡើងនៅពេលដែលមានការសន្សំកើនឡើងពីចំណូលដែលរកបានពេលបច្ចុប្បន្ន ហើយវិនិយោគកើនឡើង ដែលធ្វើឲ្យមានការកើនឡើងនូវទិន្នផល និងចំណូលនៅពេលអនាគត។ នៅពេលដែលមានការវិនិយោគលើមូលធនកាន់តែច្រើន ទីផ្សារការងារក៏មានការកើនឡើងទៅតាមនោះដែរ។

### ១.៤.៤. កត្តាបច្ចេកវិទ្យា

ការកែលម្អផ្នែកបច្ចេកវិទ្យា គឺជាដំណើរការនៃការកែលំអរគុណភាពក្នុងទ្រង់ទ្រាយតូចទៅទ្រង់ទ្រាយធំជាបន្តបន្ទាប់។ ការរីកចម្រើនខាងវិទ្យាសាស្ត្រធ្វើឲ្យមានការរកឃើញថ្មីកាន់តែច្រើន ដែលបណ្តុះការស្រាវជ្រាវ និងរិះរកបន្ថែមដើម្បីបង្កើនភាពងាយស្រួល។ ការរីកចម្រើនផ្នែកបច្ចេកវិទ្យា គឺមានឥទ្ធិពលជាវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ បច្ចេកវិទ្យានាំឲ្យមានការប្រែប្រួលក្នុងកត្តាផលិតកម្ម ដែលជួយឲ្យការផលិតទទួលបាននូវបរិមាណផលិតផលច្រើន គុណភាពប្រសើរជាងមុន និងសន្សំបានច្រើន ( ប្រើប្រាស់កម្លាំងពលកម្មតិច ) ចំណាយមូលធនតិច ទទួលបានប្រាក់ចំណេញខ្ពស់ ទាំងនេះជាអ្វីដែលអ្នកវិនិយោគគ្រប់រូបប្រាថ្នាចង់បាន។

## ១.៥. កត្តារាំងស្ទះដល់ការអភិវឌ្ឍ

### ១.៥.១. កត្តាកំណើនប្រជាជន

កំណើនប្រជាជននៅតែជាបញ្ហាក្នុងការអភិវឌ្ឍ ដែលបញ្ហាទាំងនោះរួមមាន ការកើនឡើងនៃតម្រូវការក្នុងការប្រើប្រាស់ធនធាន ដូចជា តម្រូវការទីជម្រក តម្រូវការទឹក ស្បៀង និងអាហារូបត្ថម្ភ ។ ផលប៉ះពាល់ជាច្រើននឹងត្រូវបានកើតឡើងដែលបណ្តាលមកពីការកើនឡើងលឿននៃចំនួនប្រជាជន។ ផលប៉ះពាល់ទាំងអស់នោះរួមមាន៖[11]

**ក. ថយចុះចំណូលក្នុងពលរដ្ឋម្នាក់ ( Low Per Capita Income )** ៖ នៅពេលដែលចំនួនប្រជាជនកាន់តែច្រើនឡើងចំណូលក្នុងពលរដ្ឋម្នាក់ ( per capita income ) ក៏កាន់តែតិច ដោយសារតែចំណូលជាតិ ( national income ) ត្រូវបានបែងចែកកាន់តែធំទៅតាមទំហំនៃចំនួនប្រជាជន។

**ខ. អត្រាគ្មានការងារធ្វើ ( Unemployment )** ៖ វាជារឿងមួយដែលពិបាកធ្វើទៅរួចដែលអាចផ្តល់ការងារសម្រាប់ចំនួនយ៉ាងច្រើននៃប្រជាជនទាំងអស់។ ការប្រកួតប្រជែងកាន់តែខ្លាំងលើទីផ្សារការងារ មានតែអ្នកដែលមានសមត្ថភាពតែប៉ុណ្ណោះដែលអាចមានឱកាសទទួលបានការងារដែលខ្លួនប្រាថ្នា។ សម្រាប់អ្នកដែលមានសមត្ថភាពស្ទើរធ្វើការងារដែលខុសជំនាញ និងខ្លះទៀតមិនមានការងារធ្វើ។

[11] Nosheen Maan, Impact of population growth on national development, (2017)

**គ. កាត់បន្ថយការកើនឡើងនៃវិស័យកសិកម្ម** ៖ អត្រាកំណើនយ៉ាងលឿនរបស់ប្រជាជនគឺជាបន្ទុកទៅលើការប្រើប្រាស់ដីធ្លី។ ប្រជាជនកើនឡើងបណ្តាលឲ្យមានការប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុកកើន បង្កើនចំនួនអ្នកគ្មានដីធ្លី និងកង្វះស្បៀងអាហារ។

**ឃ. ថយចុះនូវការសន្សំ និងវិនិយោគ** ៖ កំណើនប្រជាជនលឿនបង្កការចំណាយរបស់រដ្ឋកាន់តែច្រើន។ ការថយចុះនៃសន្សំ និងវិនិយោគជាបញ្ហាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេស។

**ង. កើនឡើងនៃអត្រាអតិផរណា** ៖ ប្រជាជនកាន់តែច្រើន តម្រូវការក៏កាន់តែកើនឡើងបណ្តាលឲ្យមានភាពលើសនៃតម្រូវការ។ នៅពេលដែលតម្រូវការកើនឡើងលើសពីការផ្គត់ផ្គង់ ធ្វើឲ្យមានការកើនឡើងនូវថ្លៃទំនិញក្នុងប្រទេស។

**ច. ការបំពុលកំណើនប្រជាជនលឿន** ៖ ជាទូទៅតំបន់ដែលមានការកើនឡើងខ្លាំងនៃចំនួនប្រជាជនគឺភាគច្រើននៅតាមប្រទេសកំពុងអភិវឌ្ឍន៍។ ប្រទេសទាំងនោះមិនមានការបង្កើតជាប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យការបំពុលបានត្រឹមត្រូវនៅឡើយ។

**ឆ. វិបត្តិសម្ព័ន្ធសង្គម** ៖ ការកើនឡើងលឿននៃចំនួនប្រជាជនបង្កើតឲ្យមានបញ្ហាសេដ្ឋកិច្ចនិងសង្គមជាច្រើនដូចជា ៖

- ជម្រក ត្រូវការជម្រកច្រើនជាងមុន ( មនុស្សកើនតែដីមិនកើន )
- ការអប់រំ
- សុខភាព
- ការធ្វើដំណើរ
- ការប្រើប្រាស់ទឹក និងថាមពលផ្សេងៗ។

**ជ. ស្តង់ដារនៃការរស់នៅទាប** ៖ ការកើនឡើងលឿនពេកនៃចំនួនប្រជាជនមិនអាចផ្តល់ឲ្យប្រជាជនទាំងនូវជីវិតដែលមានភាពងាយស្រួល ជាពិសេសគឺនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ ការកើនឡើងបែបនេះធ្វើឲ្យមានប្រជាជនកាន់តែច្រើនឡើងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។

បើយោងទៅតាមទ្រឹស្តីរបស់លោក Thomas Robert Malthusian ( The Malthusian Theory of Population ) លោកបានលើកឡើងថាពីទស្សនៈផ្ទាល់របស់លោកថា ការកើនឡើងនៃចំនួនប្រជាជនគឺប៉ះពាល់ដល់ការកែលម្អសង្គមនាពេលអនាគត។ លោកបានលើកឡើងទៀតថា ការកើនឡើងយ៉ាងសន្ធឹកសន្ធាប់នៃចំនួនប្រជាជននេះនឹងបណ្តាលឲ្យមានការខ្វះខាតខាងការផ្គត់ផ្គង់ស្បៀងអាហារ។ ការកើនឡើងនៃផលិតកម្ម ការផ្គត់ផ្គង់ស្បៀងអាហារមានការកើនឡើងក្រោមរូបភាពជាស្វ៊ីតនពន្ត ( 1, 2, 3, 4, 5, 6, 7, 8

និង 9 )។ ផ្ទុយទៅវិញចំនួនប្រជាជននឹងកើនឡើងបន្តបន្ទាប់ជាស្វ៊ីតធរណីមាត្រ ( 1, 2, 4, 8, 16, 32, 128, 256,... ) បើសិនជាមិនមានការពិនិត្យឲ្យបានត្រឹមត្រូវ។

### ១.៥.២. កត្តាកម្រិតការអប់រំទាប

ការអប់រំត្រូវបានផ្សារភ្ជាប់ទៅនឹងសេដ្ឋកិច្ច ទាំងសេដ្ឋកិច្ចសង្គម និងសេដ្ឋកិច្ចគ្រួសារ។ ប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសតតិយលោកមានអត្រាអនក្ខរជនច្រើន ដោយសារតែប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅមិនទាន់មានលទ្ធភាពផ្តល់សេវាសាធារណៈដោយឥតគិតថ្លៃ និងមិនមានការផ្សព្វផ្សាយទូលំទូលាយអំពីកាតព្វកិច្ចដែលត្រូវចូលរៀនដល់កុមារ និងក្រុមគ្រួសារដែលមានកូនគ្រប់អាយុចូលរៀន។ ដូចដែលយើងបានដឹងហើយថាប្រជាជននៅប្រទេសកំពុងអភិវឌ្ឍន៍មានជីវភាពមិនសូវធូរធារដូចប្រទេសអភិវឌ្ឍន៍នោះទេ។ ដូច្នេះមានកុមារជាច្រើនមិនមានឱកាសដើម្បីក្រេបជញ្ជក់ និងទទួលបានចំណេះដឹងដោយសារតែគ្រួសារមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ដល់ការសិក្សា។ កុមារជាធនធានមនុស្សយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សដែលល្អត្រូវឆ្លងកាត់ការរៀនសូត្រ និងបណ្តុះបណ្តាលត្រឹមត្រូវ។

### ១.៥.៣. កត្តានិកម្មភាព

និកម្មភាព គឺជាបញ្ហាមួយដែលគួរឲ្យព្រួយបារម្ភខ្លាំងសម្រាប់សកលលោកទាំងមូល។ តាមការអង្កេតជាក់ស្តែងចំនួនអ្នកដែលមិនមានការងារធ្វើមានចំនួនច្រើនជាងគេ គឺនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសតតិយលោក។ ផ្ទុយមកវិញនៅតាមបណ្តាប្រទេសអភិវឌ្ឍមិនមានច្រើនដូចនោះទេ។ តាមរយៈការមើលឃើញដូចនេះ តើនិកម្មភាពគឺជាឧបសគ្គក្នុងការដឹកនាំប្រទេសទៅកាន់ការអភិវឌ្ឍ? ឆ្លងតាមការសង្កេត និងសិក្សាស្រាវជ្រាវ គឺបញ្ជាក់យ៉ាងច្បាស់ថានិកម្មភាពជាកត្តារាំងស្ទះដល់ដំណើរការនៃការអភិវឌ្ឍ។ និកម្មភាពបានផ្តល់នូវផលអវិជ្ជមានជាច្រើនដល់ការអភិវឌ្ឍ ទាំងមនុស្ស សេដ្ឋកិច្ច និងសង្គម។ ផលអវិជ្ជមានទាំងនោះរួមមាន៖[12]

- **បញ្ហាជីវភាព**៖ សំដៅដល់ការណ៍ដែលមិនមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ការរស់នៅ។ រាល់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃគឺត្រូវការប្រើប្រាស់លុយ។ និកម្មជន មិនមានចំណូលសម្រាប់ការចំណាយផ្សេងៗ ជាពិសេសគឺតម្រូវការចាំបាច់ដែលមិនអាចខ្វះបាន ( អាហារ ជម្រក និងសម្លៀកបំពាក់ )។ លើសពីនេះទៅទៀតនោះ ពួកគេគ្មានលទ្ធភាពក្នុងការចំណាយលើរបស់របរបន្ថែមដើម្បីសម្រួលដល់ការរស់នៅរបស់ពួកគេ។

[12] Michelle Seidel, The positive and negative effects of unemployment (October 26, 2018)

• **បញ្ហាសុខភាព៖** នេះជាបញ្ហាមួយទៀតសម្រាប់មនុស្សគ្រប់រូប និងពិតជាសំខាន់សម្រាប់ការរស់នៅដែលកើតឡើងដោយសារតែមិនមានការងារធ្វើ។ មនុស្សដែលមិនមានការងារធ្វើ មិនមានចំណូល អាចកើតមានជាបញ្ហាផ្លូវចិត្ត គិតច្រើនអំពីការរស់នៅ ( បញ្ហាខាងលើ )។ មនុស្សទាំងនោះអាចមានការបាក់ទឹកចិត្ត វាយតម្លៃខ្លួនឯងទាប ម្ហូរម៉ៅ និងកើតបញ្ហាខួរក្បាលផ្សេងទៀតដែលអាចប៉ះពាល់ដល់សុខភាពរាងកាយ។ បញ្ហានេះក៏មានឥទ្ធិពលមិនល្អសម្រាប់ប្រទេសផងដែរ ដោយយើងដឹងហើយមនុស្សជាធនធានយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ។

• **បញ្ហាសេដ្ឋកិច្ច៖** កំឡុងពេលដែលមិនមានការងារធ្វើ គឺមិនមានចំណូល។ ការដែលមិនមានចំណូលជាមូលហេតុដែលនឹងបណ្តាលឲ្យមានភាពក្រីក្រ។ ដោយសារតែភាពក្រីក្រ ខ្វះខាតក្នុងការរស់នៅ នោះបំណុលក៏កើតមានឡើង និងកើនឡើងជាបន្តបន្ទាប់ដែលនឹងក្លាយជាបញ្ហាសេដ្ឋកិច្ចធំមួយ។

• **បញ្ហាសង្គម៖** មានការបង្កគ្រោះថ្នាក់ អសន្តិសុខសង្គម ដែលភាគច្រើនកើតឡើងដោយសារតែអ្នកដែលមិនមានការងារធ្វើ និងអ្នកដែលរស់នៅក្នុងជីវភាពក្រីក្រ។ នៅពេលដែលអត្រានៃនិកម្មភាពកាន់តែមានការកើនឡើង អត្រានៃការបង្កគ្រោះថ្នាក់ អសន្តិសុខ ចោរកម្ម... ក៏នឹងកើនឡើងទៅតាមនោះផងដែរ។

### ១.៥.៤. កត្តានយោបាយ

នយោបាយ អាចថាជាចំណោទបញ្ហារសើបមួយក្នុងសង្គមជាតិ។ ការរក្សាឲ្យមានសន្តិសុខ សុវត្ថិភាព និងស្ថេរភាពនយោបាយគឺជារឿងសំខាន់ ដើម្បីបញ្ចៀសប្រទេសពីភាពអនាធិបតេយ្យ និងពង្រឹងច្បាប់ប្រទេស។ ប្រទេសដែលមានច្បាប់ស្ថិតក្នុងសភាពទន់ជ្រាយ វាពិបាកក្នុងការគ្រប់គ្រង និងមិនអាចធានាបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋបាននោះទេ ជាហេតុបណ្តាលឲ្យប្រជាជនគ្មានទំនុកចិត្តចំពោះរាជរដ្ឋាភិបាល នេះជាបញ្ហាដ៏ធំមួយរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងប្រទេសជាតិទាំងមូល។ លើសពីនេះទៅទៀត អាចនឹងបង្កើតឲ្យមានសង្គ្រាមដែលជាការខាតបង់យ៉ាងធំធេងសម្រាប់ប្រជាជាតិទាំងមូល។ បញ្ហាសង្គ្រាមនេះទៀតសោត បានធ្វើឲ្យបាត់បង់ឱកាសក្នុងដំណើរការនៃការដើរចូលទៅក្នុងទីផ្សារ និងការបង្ហាញមុខនៅលើឆាកអន្តរជាតិ។

ទន្ទឹមនឹងកត្តាខាងលើក៏មានកត្តាមួយទៀតដែលត្រូវបានទទួលស្គាល់ថាជារនាំងនៃការអភិវឌ្ឍគឺ វដ្តនៃភាពក្រីក្រ។ វដ្តនៃភាពក្រីក្រនេះត្រូវបានពន្យល់ដូចខាងក្រោម៖[13]

រូបភាពទី១៖ វដ្តនៃភាពក្រីក្រ




## ១.៦. តួនាទីរបស់កសិកម្មក្នុងសេដ្ឋកិច្ចគ្រួសារ

ចំពោះគ្រួសារប្រជាពលរដ្ឋដែលមានដើមទុនតិច កសិកម្មបានដើរតួនាទីយ៉ាងសំខាន់ជាពិសេសគ្រួសារកសិករដែលមានដីតូច តិច និងកម្រិតនៃចំណេះដឹងមិនខ្ពង់ខ្ពស់។ ពួកគេអាចបង្កើតជាកសិកម្មលក្ខណៈគ្រួសារ ដូចជាការដាំដំណាំតាមលទ្ធភាព និងតាមទំហំផ្ទៃដីដែលពួកគេមាន ជាពិសេសគឺការចិញ្ចឹមសត្វ ( គោ ក្របី មាន់ ទា... )។ ខាងក្រោមនេះជាចំណែករបស់វិស័យកសិកម្មដែលដើរតួជាជំនួយដល់ការរស់នៅ និងចិញ្ចឹមជីវិតរបស់គ្រួសារកសិករ។

### ១.៦.១. ប្រភពចំណូលយ៉ាងសំខាន់

ដោយសារតែប្រទេសកម្ពុជាជាប្រទេសដែលមានអាកាសធាតុ សណ្ឋានដី និងកត្តាអំណោយផ្សេងទៀតសមស្របទៅនឹងការធ្វើកសិកម្ម។ ម្យ៉ាងវិញទៀតក៏ជាប្រទេសដែលពឹងផ្អែកទៅលើវិស័យនេះតាំងពីបុរាណកាលមកម្ល៉េះ។ ជាប្រទេសកសិកម្ម ប្រជាជនជាកសិករ ដូច្នេះការធ្វើកសិកម្មជាមុខរបរស្នូល និងចំណូលមួយភាគធំ គឺបានមកពីវិស័យកសិកម្ម។ ទន្ទឹមនឹងស្ថានភាពការឆ្លងវីការាលដាលនៃជម្ងឺនាឆ្នាំ ២០២០នេះបានធ្វើឲ្យមានការខាតបង់យ៉ាងធំធេង។ តាមរយៈ IMF ក្នុងបញ្ហានេះបានបង្កើតឲ្យមានការព្យាករណ៍សេដ្ឋកិច្ចថា សេដ្ឋកិច្ចពិភពលោកអាចនឹងធ្លាក់ចុះរហូតដល់ ៥%។ រីឯសេដ្ឋកិច្ចប្រទេសកម្ពុជាវិញត្រូវបានគេព្យាករណ៍ថាអាចនឹងធ្លាក់ចុះប្រមាណ១.៩% នៅក្នុងឆ្នាំ២០២០ នេះ។[14] បើយោងតាមសេចក្តីថ្លែង

[13] សារណាបញ្ចប់ការសិក្សាណែនាំដោយ បណ្ឌិត ឈុន ពហុ, ស្រាវជ្រាវដោយនិស្សិត ទ្បេ ប៉ូរ៉ាពីន, «ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា» (ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧)

[14] IMF, Global economy will suffer worst year since Depression,( April 14, 2020)

ការណ៍របស់ប្រមុខរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានឲ្យដឹងថា កម្ពុជានឹងប្តូរទិសដៅថ្មីពីវិស័យកាត់ដេរសំលៀកបំពាក់ សេវាកម្ម វិស័យសំណង់ និងវិស័យទេសចរណ៍ មកជំរុញវិស័យកសិកម្មជាវិស័យអាទិភាព។[15] វិស័យកសិកម្មបានសម្រួលដល់ការរកចំណូលររបស់ពលករ កម្មករ កម្មការី ដែលបានបាត់បង់ឱកាសការងារពីវិស័យឧស្សាហកម្ម។

### ១.៦.២. ផ្តល់ស្បៀងអាហារ

ស្ថេរភាពនៃវិស័យកសិកម្មធានាបាននូវសន្តិសុខស្បៀងអាហារ ហើយសន្តិសុខស្បៀងនេះឯងដែលជាតម្រូវការចាំបាច់សំខាន់សម្រាប់ប្រទេសមួយ។ ហេតុអ្វីបានជាប្រទេសមួយចាំបាច់ត្រូវការឲ្យមាននូវសន្តិសុខស្បៀង? ការដែលមានស្ថេរភាពសន្តិសុខស្បៀង គឺជាកត្តាជះឥទ្ធិពលមួយក្នុងការទប់ស្កាត់នូវបញ្ហានៃការខ្វះអាហារូបត្ថម្ភដែលជាបញ្ហាធំមួយក្នុងការអភិវឌ្ឍមនុស្ស។ ការរៀបរាប់ខាងលើនេះ គឺយើងផ្តោតលើលក្ខខណ្ឌនៃប្រទេសទាំងមូល ប៉ុន្តែបើយើងងាកមកមើលលើលក្ខខណ្ឌនៃរង្វង់គ្រួសារវិញ ទិន្នផលកសិកម្មដែលទទួលបានពីការប្រមូលផលពីចំការ កសិដ្ឋាន គឺត្រូវបានបែងចែកយកទៅលក់នៅលើទីផ្សារដើម្បីជាចំណូល និងចំណែកផ្សេងទៀតត្រូវបានប្រជាកសិករប្រើប្រាស់ទិន្នផលទាំងនោះ ដូចជាអង្ករ បន្លែ សាច់ .... ជាស្បៀងអាហារសម្រាប់បរិភោគចិញ្ចឹមជីវិតប្រចាំថ្ងៃនៅក្នុងគ្រួសារ។ វិស័យកសិកម្មបានដើរតួនាទីកាន់តែសំខាន់នៅក្នុងវិស័យនៃការផ្គត់ផ្គង់ចំណីអាហារ គឺនៅពេលដែលមានការកើនឡើងតម្លៃម្ហូបអាហារ។ ចំពោះប្រទេសកម្ពុជា វិស័យកសិកម្មមានសក្តានុពលសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងសន្តិសុខស្បៀង។ ដោយមើលឃើញពីសារៈសំខាន់នៃវិស័យកសិកម្ម បានជំរុញឲ្យមានការបង្កើតឡើងនូវ"កម្មវិធីគំនិតផ្តួចផ្តើមសន្តិសុខស្បៀងសម្រាប់អនាគត" ឬ ( Feed the Future ) គាំទ្រដល់យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការជួយបង្កើនផលិតភាពកសិកម្មរបស់ប្រទេស ការធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជនក្រីក្រនៅតាមជនបទ ព្រមទាំងលើកកម្ពស់ការគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានធម្មជាតិដ៏សម្បូរបែបដែលមាននៅក្នុងប្រទេស។ គោលបំណងសំខាន់ គឺគាំទ្រការសម្រេចឲ្យបាននូវគោលការណ៍អភិវឌ្ឍន៍កម្ពុជា រួមទាំងការកាត់បន្ថយពាក់កណ្តាលនៃជនរងគ្រោះដោយកង្វះអាហារូបត្ថម្ភ និងការសម្រេចឲ្យបាននូវការប្រើប្រាស់ដោយចីរភាពនៃធនធានបរិស្ថាន។ កម្មវិធីនេះស្ថិតក្រោមការផ្តួចផ្តើមរបស់ទីភ្នាក់ងារជំនួយអាមេរិក ដែលហៅកាត់ថាUSAID ។[16] យោងតាមសេចក្តីថ្លែងការមួយរបស់ប្រមុខរាជរដ្ឋាភិបាលនៃ

[15] សេចក្តីថ្លែងការណ៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, ( ២៤ មិថុនា ២០២០)

[16] USAID, «កសិកម្ម និងសន្តិសុខស្បៀង» (២៣ សីហា ២០១៩)

ប្រទេសកម្ពុជាបានឲ្យដឹងថាកម្ពុជានឹងមិនមានបញ្ហាស្បៀងអាហារទេ ព្រោះកម្ពុជាជាប្រទេសផលិតស្បៀងប្រើប្រាស់គ្រប់គ្រាន់ក្នុងប្រទេស និងបាននាំចេញទៅកាន់ក្រៅប្រទេសផងដែរ។[17]

### **១.៦.៣. ផ្តល់ការងារ**

កសិកម្មបានផ្តល់ការងារយ៉ាងច្រើនសម្រាប់ប្រជាពលរដ្ឋ ជាពិសេសនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវបានគេស្គាល់ថាជាប្រទេសដែលយកវិស័យកសិកម្មជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ និងប្រជាជនប្រកបរបរកសិកម្ម។ នៅតាមកសិដ្ឋានធំៗដែលត្រូវការកម្លាំងពលកម្មច្រើនជាងកម្លាំងពលកម្មដែលម្ចាស់កសិដ្ឋានមាន បានផ្តល់ការងារដល់អ្នកដែលមិនមានការងារ ក្លាយជាចំណែកមួយក្នុងការកាត់បន្ថយនៃអត្រានិកម្មភាព។ ក្រៅពីនេះ វិស័យកសិកម្មក៏ក្លាយទៅជាវិស័យអាទិភាពមួយក្នុងការផ្តល់ការងារដល់ស្ត្រី និងមនុស្សដែលមានវ័យចំណាស់ តាមរយៈការធ្វើកសិកម្មជាលក្ខណៈគ្រួសារ ការដាំដុះ និងការចិញ្ចឹមសត្វ។ ការធ្វើបែបនេះបានជួយយ៉ាងច្រើន ព្រោះស្ត្រីមានការងារជាច្រើន ដូចជា ការងាររៀបចំផ្ទះសំបែង មើលថែរក្សាកូន ។ល។ ការងារទាំងនោះពិបាកក្នុងការដកដៃទៅធ្វើការងារផ្សេងទៀត វាផ្ទុយទៅនឹងបុរសដែលអាចចាកចេញពីផ្ទះដើម្បីស្វែងរកការងារធ្វើនៅក្នុងរោងចក្រ សហគ្រាស ដែលត្រូវចំណាយពេលពេញមួយថ្ងៃដើម្បីបំពេញការងារ។

### **១.៦.៤. បង្កើនកម្រិតជីវភាពនៃការរស់នៅ**

ការបង្កើនកម្រិតជីវភាពនៃការរស់នៅ ពិតជាមានសារៈសំខាន់ក្នុងន័យឆ្ពោះទៅកាន់ការរស់នៅក្នុងកម្រិតជីវភាពស្តង់ដាមួយ ( Standard of living ) និងប្រកបទៅដោយគុណភាព ( Quality of life )។[18] ដូចដែលបានបង្ហាញខាងលើ វិស័យកសិកម្មបានផ្តល់ឲ្យប្រជាជនយ៉ាងច្រើននូវអាហារសម្រាប់បរិភោគ ការងារ និងជាប្រភពចំណូលយ៉ាងសំខាន់។ ទាំងនេះជាសញ្ញាណនៃការកើនឡើងកម្រិតជីវភាពរបស់ប្រជាជន ជាពិសេសសម្រាប់គ្រួសារកសិករ និងជាស្ពានឆ្ពោះទៅកាន់ការអភិវឌ្ឍប្រទេសជាតិទាំងមូល។ នៅពេលដែលមានកំណើននៃវិស័យកសិកម្មធ្វើឲ្យអត្រានិកម្មភាពត្រូវបានកាត់បន្ថយ កម្រិតចំណូលរបស់គ្រួសារកសិករមានការកើនឡើង ចំណែកឯការរស់នៅ មានភាពងាយស្រួល និងទំនើបជាងមុន។

---

[17] សេចក្តីថ្លែងការណ៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, (២១ កក្កដា ២០២០)

[18] Amy Fontinelle, Standard of living and Quality of life, (April 11, 2019)

## ១.៧. បច្ចេកទេសចិញ្ចឹម និងគ្រប់គ្រងទានៅជនបទ

### ១.៧.១. ប្រភេទពូជទា

ក្នុងការចិញ្ចឹមទា ការជ្រើសរើសពូជជាកត្តាសំខាន់។ ជាដំបូងកសិករត្រូវស្គាល់ពីប្រភេទទាឲ្យបានច្បាស់ និងកំណត់ថាចិញ្ចឹមយកសាច់ ឬចិញ្ចឹមយកពង។ បន្ទាប់មកទើបធ្វើការជ្រើសរើសប្រភេទទាដែលសមស្រប នឹងអាកាសធាតុ ទីតាំង និងកត្តាផ្សេងទៀតដែលកសិករកំពុងមាន។ ពូជទាជាច្រើនមាននៅប្រទេសកម្ពុជា រួមបញ្ចូលទាំងទាពូជស្រុក និងទាពូជនាំចូល។ ពូជទាស្រុកមានដូចជា ទាសំពៅ អង្កាម និងកាប៉ា។ ចំណែកឯប្រភេទទានាំចូលមានដូចជា ទាកាគីកាំបែល ទាប៉េកាំង និងប្រភេទទាកូនកាត់។[19] ពូជទាំងនេះភាគច្រើនឃើញមានចិញ្ចឹមនៅកសិដ្ឋានធំៗ។ ទោះបីយ៉ាងណាក៏ដោយកសិករគួរបន្តការចិញ្ចឹមទាពូជក្នុងស្រុកដូចជា ទាសំពៅ អង្កាម កាប៉ា និងទាកូនកាត់ជាមួយទានាំចូល។ ប្រសិនបើការចិញ្ចឹមគ្រាន់ តែសម្រាប់ការផលិតសាច់នោះទាពូជក្នុងស្រុក និងទាកាប៉ា សមស្របបំផុត។ ប៉ុន្តែបើមានបំណងចង់បានទាដែលផលិតស៊ុតខ្ពស់ ក្នុងករណីនេះជម្រើសគួរតែយកពូជកាគីកាំបែល។ ទាប៉េកាំង ជាពូជល្អបំផុតសម្រាប់ផលិតសាច់ តែទាកូនកាត់រវាងពូជនាំចូល និងពូជក្នុងស្រុកសមស្រប សម្រាប់ការផលិតស៊ុត និងសាច់ផង។

#### ១.៧.១.១. ពូជទាក្នុងស្រុក

នៅតាមទីជនបទ កសិករភាគច្រើននៅប្រទេសកម្ពុជាជ្រើសរើសយកការចិញ្ចឹមទាពូជក្នុងស្រុក ដោយសារតែពួកគេច្រើនតែចិញ្ចឹមជាលក្ខណៈគ្រួសារ មិនទាមទារខ្ពស់ក្នុងការស្វែងរកនូវពូជថ្មីៗ ពោលគឺការចិញ្ចឹមតាមបែបប្រពៃណី។ ម្យ៉ាងវិញទៀត ដោយសារតែគុណភាពនៃសាច់របស់វាមានខ្លាញ់ទាប ហើយសមស្របសម្រាប់ការចិញ្ចឹមជាលក្ខណៈគ្រួសារ។ ពិសេសជាងនេះទៅទៀតនោះ ទាស្រុកសក្តិសមសម្រាប់អ្នកទើបចាប់ផ្តើមចិញ្ចឹមទាដោយសារវាអាចធន់នឹងអាកាសធាតុមិនល្អ និងរដូវកាលដែលខ្វះចំណី។ ទាស្រុកអំណោយផលច្រើន ព្រោះវាងាយស្រួលក្នុងការដើរកចំណីដោយខ្លួនឯង។ ប៉ុន្តែជាឧបសគ្គមួយ ពូជទាស្រុកលូតលាស់យឺតជាងពូជទានាំចូល។ តែគួរឲ្យសោកស្តាយដោយសារវាមានជើងខ្លីធ្វើឲ្យដងខ្លួនវាស្ទើរតែអូសដី ដែលនាំឲ្យវាមានការលំបាកក្នុងការដើរឆ្ងាយ។ ជាទូទៅ ទាស្រុកផលិតស៊ុតពី ៦០ ទៅ ៨០ គ្រាប់ក្នុងមួយឆ្នាំ តែផលិតកម្មស៊ុតអាចកើនឡើង ដោយការកែលំអការគ្រប់គ្រង និងចំណី។

[19] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, «ការចិញ្ចឹម និងគ្រប់គ្រងទានៅជនបទ» (ឆ្នាំ ២០០៦)

រូបភាពទី២៖ ទាស្រុក



**ក. ទាសំពៅ**

ទាសំពៅមានលក្ខណៈពិសេសមួយដែលធ្វើឲ្យមានការពេញនិយម និងសម្រេចជ្រើសរើសយកពូជនេះមកចិញ្ចឹមនៅជនបទនៃប្រទេសកម្ពុជា គឺដោយសារស៊ុតរបស់វាមានទំហំធំជាងពូជទាផ្សេង។ ទាសំពៅមានទំហំខ្លួនមធ្យម និងពូកែដើររកចំណីដោយខ្លួនឯង។ ទាសំពៅត្រូវបានសំគាល់តាមរយៈបង្កង់សរនៅត្រង់ករ និងរោមរបស់វាលឿងភ្លឺ ចំណែកឯចំពុះរបស់វាមានពណ៌ត្នោត និងមានជើងពណ៌លឿង។ ពួកវាចាប់ផ្តើមផលិតស៊ុតនៅអាយុចន្លោះពី ៥-៦ ខែ។

**ខ. ទាអង្គាម**

ទាអង្គាមក៏ជាប្រភេទទាស្រុកមួយប្រភេទដែលគេឃើញមានចិញ្ចឹមនៅតាមជនបទនៃប្រទេសកម្ពុជា។ ពូជទានេះមានជើងតូចហើយខ្លី ចំណែកឯករបស់វាក៏មានលក្ខណៈខ្លីផងដែរ។ ទាអង្គាមមានដងខ្លួនតូច និងមានរោមពណ៌ចាប់ពីពណ៌លឿងទុំ រហូតដល់ពណ៌ត្នោតដែលមានបន្ថែមដោយចំណុចខ្មៅតូចៗនៅលើរោមរបស់វា។ ពូជនេះមានលក្ខណៈសម្បត្តិសមស្រប ដែលសក្តិសមសម្រាប់ផលិតកម្មខ្នាតតូច ឬសម្រាប់អាជីវកម្មជាលក្ខណៈគ្រួសារ ដោយសារវាធន់នឹងភាពរាំងស្ងួត ជំងឺ រួមបញ្ចូលទាំងពពួកប៉ារ៉ាស៊ីតដែលជាហេតុឲ្យ

ទាឈើ និងរាំងស្ទះដល់ការលូតលាស់។ ក្រៅពីនេះទាប្រភេទនេះប៉ិនប្រសប់ក្នុងការដើររកចំណីដូចជា រុក្ខជាតិទឹកដែលមានបរិមាណទឹកខ្ពស់។ ពួកវាអាចស៊ីចំណីដូចជា ចកបាយទា ស្មើរនឹងទម្ងន់ខ្លួនវា។

រូបភាពទី៣៖ ទាអង្កាម



**គ. ទាកាប៉ា**

ទាកាប៉ាខុសគ្នាទាំងស្រុងពីពូជទាស្រុកដ៏ទៃទៀត ដោយសារវាអាចភ្ញាស់ស៊ុតរបស់វា មានទំហំខ្លួនធំ មានរោមពណ៌ខ្មៅ តែក៏មានពណ៌ស និងខ្មៅលាយផងដែរ។ ទាញីចាប់ផលិតស៊ុត នៅអាយុ ៥-៦ ខែដែលមានពង ១៥-២០គ្រាប់ សម្រាប់ការពងមួយលើកៗ។ ទាកាប៉ាមានការនិយម ចូលចិត្តណាស់ នៅប្រទេសកម្ពុជាដោយសារវាធន់នឹងជំងឺ ជាពិសេសជាមួយចំណីដែលមានគុណភាពទាប។ ទាប្រភេទនេះមាន ការបន្តពូជបានល្អដែលអាត្រាស៊ុតវាអាចមានរហូតដល់ ៨០-៩០% ។ ទាកាប៉ាឈ្មោលអាចមានទំងន់ដល់ទៅ ៤-៥ គ.ក្រ ហើយចំពោះទាញីវិញមានទម្ងន់ពី ១-១,៥គ.ក្រ។ ទាកាប៉ាញី ជាមេទាល្អអាចថែរក្សាកូនវាបានគង់វង្សច្រើន។ ពូជទានេះសមស្របណាស់សម្រាប់កសិករដោយសារវាពូកែរកចំណី និងភ្ញាស់កូនខ្លួនវាបាន។ ពងទាកាប៉ាត្រូវការ ៥ អាទិត្យដើម្បីញាស់ផ្ទុយពីទាធម្មតាដែលត្រូវការតែរយៈពេល ៤ អាទិត្យ។ ទាកាប៉ាឈ្មោលអាចបង្កាត់ពូជជាមួយទាញីផ្សេងទៀតហើយកូនកាត់របស់ពូជទាំងពីរ ជាទូទៅធំលឿននិងផលិតសាច់បានល្អសម្រាប់ទីផ្សារ។

រូបភាពទី៤៖ ទាកាប៉ា



**១.៧.១.២. ពូជនាំចូល**

ក្រៅពីពូជទាស្រុក មានពូជទានាំចូល ៣ ប្រភេទទៀត។ ពូជទានាំចូល គឺទាមទារការមើលថែរខ្ពស់ជាងប្រភេទទាក្នុងស្រុក ( ដូចជាការផ្តល់ចំណី និងថ្នាំជាដើម ) ដោយសារតែពូជទានេះវាមានកម្រិតស៊ាំនឹងជម្ងឺ និងអាកាសធាតុតិចចតួច។ ផ្ទុយមកវិញ ថ្វីត្បិតតែបែបនេះក្តី ប៉ុន្តែវាមានមាឌធំ និងការលូតលាស់លឿន ជាពិសេសទទួលបានផលចំណេញខ្ពស់បើធ្វើតាមបច្ចេកទេសត្រឹមត្រូវ។ ខាងក្រោមនេះជាលក្ខណៈរបស់ពូជទានាំចូល៖

**ក. កាគីកាំបែល**

ពូជទានេះ ជាពូជទាកាត់អង់គ្លេស និងឥណ្ឌា។ ទាពូជនេះត្រូវបានបង្កើតឡើងដោយអ្នកស្រី កាំបែល នៃប្រទេសអង់គ្លេស។ អ្នកស្រី កាំបែល បានបង្កាត់ពូជទាអង់គ្លេសជាមួយនឹងពូជទាឥណ្ឌា។ ទាពូជនេះមានពណ៌កាគី និងអាចមានពណ៌ប្រផេះ លឿងស្រាល ហើយមានទំហំប្រហាក់ប្រហែលទាស្រុកនៅកម្ពុជាដែរ តែវាមានដងខ្លួនទ្រវែង និងជើងរបស់វាវែង។ ចំណែកឯជើង និងក្រចករបស់វា គឺមានពណ៌ត្នោត។ ទានេះអាចពងពី ២៥០ ទៅ ៣០០ គ្រាប់ក្នុងមួយឆ្នាំ ឬក៏អាចនឹងច្រើនជាងនេះ។ ទំហំជាមធ្យមរបស់ទានេះ គឺ ១,៥ ទៅ ២ គ.ក្រ។ ពួកវាដើរងើបមុខបន្តិចដែលអាចឲ្យវាមានលទ្ធភាពរកចំណីឆ្ងាយបាន។

**ខ. ទាប៉េកាំង**

ទាពូជនេះមិនមានចិញ្ចឹមខ្នាតតូចជាលក្ខណៈគ្រួសារទេនៅកម្ពុជា ដោយសារតែពូជទាប្រភេទនេះទាមទារចំណីដែលមានគុណភាពពិសេស និងបរិមាណច្រើនដើម្បីការលូតលាស់បានល្អ។ ទាប៉េកាំងឃើញមានចិញ្ចឹមជាខ្នាតមធ្យម និងជាលក្ខណៈឧស្សាហកម្ម។ ទាពូជនេះមានទម្ងន់ពី ៣,៥ ទៅ ៤ គ.ក្រ នៅពេលពេញវ័យ។ ហើយវាអាចមានទម្ងន់ពី ២,៥ ទៅ ៣ គ.ក្រក្នុងរយៈពេល៣ខែបើសិនជាមានការផ្ដល់នូវចំណីគ្រប់គ្រាន់។ ចំពុះទានេះមានពណ៌ទឹកក្រូច និងមានជើងពណ៌លឿនទុំ ចំណែកឯស្បែករបស់វាមានពណ៌លឿង។ ទាប៉េកាំងមិនមែនជាពូជទាពងទេ តែវាអាចពងពី ១០០ ទៅ ១៥០គ្រាប់ក្នុងមួយឆ្នាំ។ ពូជទាប៉េកាំងជាជម្រើសល្អក្នុងការចិញ្ចឹមយកសាច់ ដោយសារតែវាមានខ្លួនធំ និងទម្ងន់ធ្ងន់ (មានសាច់ច្រើន)។

**គ. ទាកូនកាត់**

ជាទូទៅ ពូជទាកូនកាត់មានលក្ខណៈល្អប្រសើរចំពោះការចិញ្ចឹម ព្រោះតែពូជទាកូនកាត់ជាពូជទាដែលបានបង្កាត់ចេញពីពូជទាផ្សេងគ្នា។ ជម្រើសពូជទាកូនកាត់ដែលល្អជាងគេមួយក្នុងចំណោមពូជកូនកាត់ផ្សេងទៀត គឺទាដែលបង្កាត់រវាងទាកាគីកាំបែលឈ្មោល និងទាក្នុងញីស្រុកញី។ ពូជកូនកាត់ដែលទទួលបានពីការបង្កាត់បករភេទនេះ អាចមានលក្ខណៈសមស្របច្រើនទៅតាមលក្ខខណ្ឌក្នុងស្រុក និងមានពងច្រើន ឬធំធាត់លឿនជាងទាស្រុក។ ទាកូនកាត់នេះអាចពងពី ១០០ ទៅ ២០០ គ្រាប់ក្នុងមួយឆ្នាំ។

**១.៧.២. គម្រូវការនៃការចាប់ផ្ដើមចិញ្ចឹមទា**

នៅពេលកសិករមានផែនការក្នុងការចិញ្ចឹមទា ពួកគេត្រូវដឹងឲ្យច្បាស់អំពីបញ្ហាដែលអាចកើតមានឡើងចំពោះទា ជាពិសេសគឺទាក់ទងជាមួយនឹងសុខភាពរបស់ទា។

បញ្ហាទីមួយដែលត្រូវគិត គឺចំណីសម្រាប់ទា។ ពួកគេត្រូវគិតថា តើចំណីប្រភេទណាដែលសមស្របសម្រាប់ទាដើម្បីឲ្យទទួលបាននូវទិន្នផលទាខ្ពស់។ ពួកគេក៏គួរគិតគូរអំពីចំណាយផ្សេងៗជាមុន ដើម្បីបង្ការការខាតបង់។ ការចិញ្ចឹមទា គឺជាជម្រើសល្អប្រសើរមួយសម្រាប់កសិកររស់នៅក្បែរប្រភពទឹក ដូចជាដងទន្លេ បឹង និងតំបន់ទំនាបលិចទឹក ព្រោះនៅទីនោះមានប្រភពធនធានចំណីច្រើនដូចជា ខ្យង ក្ដាម សត្វល្អិតក្នុងទឹក ដែលនេះជាសក្ដានុពលមួយ ដោយសារតែពួកគេអាចប្រលែងទាឲ្យទៅរកចំណីដោយខ្លួនឯង។ ការធ្វើបែបនេះទីមួយ គឺអាចជួយសន្សំសន្ចៃការចំណាយលើចំណី ទីពីគឺជួយឲ្យទាមានភាពរឹងមាំ និងស៊ាំទៅនឹងជម្ងឺផ្សេងៗនៅបរិស្ថានខាងក្រៅ។

បញ្ហាទីពីរ គឺថ្នាំសម្រាប់ការពារ និងព្យាបាលទា។ ជម្ងឺសំខាន់ៗដែលត្រូវប្រឈមនៅពេលចិញ្ចឹមទាមាន អាសន្នរោគ និងប៉េស្តទា ជម្ងឺផ្តាសាយ និងរលោកថ្លើមដែលជាបញ្ហាចោទដ៏សំខាន់។ មានបទដ្ឋានមួយចំនួន ដើម្បីអនុវត្តក្នុងការចិញ្ចឹមទាប្រកបដោយជោគជ័យ៖

- ផ្តល់ចំណីដល់ទាឲ្យគ្រប់គ្រាន់ និងមានគុណភាពល្អ
- ជ្រើសរើសទាដែលមានសុខភាពល្អមុននឹងចាប់ផ្តើមចិញ្ចឹម
- ចាក់ថ្នាំបង្ការជម្ងឺនានា និង
- ថែទាំទាឲ្យល្អ។

ជាទូទៅកសិករត្រូវចាប់ផ្តើមដោយមានការសិក្សា និងយល់ឲ្យបានគ្រប់ជ្រុងជ្រោយលើការចិញ្ចឹមទាជាមុនដោយផ្អែកតាមបទដ្ឋានអនុវត្តបច្ចេកទេសរួចហើយចាំចាប់ផ្តើមគម្រោង។ កសិករអាចស្វែងរកព័ត៌មានទាំងអស់នេះបានតាមរយៈការសាកសួរទៅកាន់អ្នកស្ម័គ្រចិត្តដែលចុះចែករំលែកចំណេះដឹងស្តីពីបច្ចេកទេសចិញ្ចឹមសត្វនៅតាមមូលដ្ឋាន។ កសិករត្រូវយល់ពីតម្រូវការអាហាររូបត្ថម្ភសម្រាប់ទាប្រភេទនីមួយៗ និងធនធានដែលមានសក្តានុពល សម្រាប់ជាចំណីទា។ កូនទាមានតម្រូវការចំណីតិចតួច តែត្រូវមានគុណភាពល្អ និងមានប្រតេអ៊ីនខ្ពស់ (២០,២២% ក្នុងម៉ាសស្ងួត) ហើយទាត្រូវការចំណីច្រើននៅពេលវាកាន់តែធំ តែកម្រិតប្រូតេអ៊ីនថយចុះប្រៀបនឹងកូនទា (១៦-១៨%ក្នុងម៉ាសស្ងួត)។ មេទាពងត្រូវការចំណីមានប្រូតេអ៊ីន ៤-១៥% ក្នុងចំណីរបស់វាតែមានការបន្ថែមកាល់ស្យូម ពីម្សៅឆ្អឹង ឬសំបកស៊ុត។ ប្រសិនបើទាពងត្រូវបានផ្តល់កូនខ្យង និងក្តាមបន្ថែម ពួកវានឹងទទួលជាតិរ៉ែគ្រប់គ្រាន់តាមតម្រូវការរបស់វាហើយ។ ( តារាងទី១ )

### ១.៧.២.១. តម្រូវការចំណី

ការចិញ្ចឹមទាឲ្យទទួលបានជោគជ័យ អាស្រ័យយ៉ាងខ្លាំងលើទីតាំង។ ការចិញ្ចឹមទាគួរតែធ្វើនៅតំបន់ដែលមានប្រភពធនធានចំណីធម្មជាតិពេញមួយឆ្នាំ ហើយនៅលើទីតាំងដែលមានការគ្រប់គ្រងត្រឹមត្រូវ ព្រោះមិនសូវចំណាយច្រើនលើចំណី ហើយទទួលបាននូវប្រាក់ចំណេញច្រើន។ កសិករត្រូវមានផែនការជាមុន ថាតើគេត្រូវផ្តល់អ្វីឲ្យទាស៊ីមុននឹងចាប់ផ្តើមគំរោងចិញ្ចឹមទា។ ចំពោះទីតាំងសមស្របដែលលើកឡើងខាងលើជាទូទៅ មិនមានគ្រប់ទីកន្លែងនៅទូទាំងប្រទេសកម្ពុជាទេដូច្នេះ កសិករគួរចាប់ផ្តើមចិញ្ចឹមកូនទានៅដើមរដូវវស្សា ដែលធ្វើឲ្យកសិករអាចមានលទ្ធភាពទទួលផលពីធនធានធម្មជាតិនៅក្នុងទឹកក្បែរៗផ្ទះ ដូចជា ប្រឡាយ ស្រះ បឹង ។ល។

ខាងក្រោមនេះជាសំណួរមួយចំនួនដែលកសិករត្រូវសួរខ្លួនឯងមុនពេលដែលធ្វើកាចិញ្ចឹម៖

- តើមានប្រភពធនធានចំណីពេញមួយឆ្នាំដែរឬទេ?

- តើប្រភពធនធានចំណីអ្វីខ្លះដែលទាអាចស៊ីបាន? តើមួយណាជាចំណី ប្រូតេអ៊ីន ថាមពល ជីវជាតិ និងជាតិរ៉ែ?
- តើមានចំណីណាខ្លះដែលអាចផលិតបាននៅក្នុងកសិដ្ឋាន?
- តើចំណីប្រភេទណាដែលត្រូវទិញពីផ្សារ?
- តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីកាត់បន្ថយអត្រាងាប់របស់ទា?

តារាងទី១៖ ប្រភពចំណីធម្មជាតិដែលទាអាចស៊ីបានមានដូចជា៖

| ចំណី | ប្រតេអ៊ីន | ថាមពល | រ៉ែ | ជីវជាតិ |
|---|---|---|---|---|
| ខ្យង | **** | | ** | |
| ជន្លេន | ***** | | * | |
| សត្វល្អិត | **** | | * | |
| កូនក្តាម | ** | | * | |
| កូនត្រី | ***** | | * | |
| ចកបាយទា | **** | | * | * |
| ត្រកួន | *** | | * | * |
| ស្មៅខ្ចី | ** | | * | * |
| កន្ទក់ | * | *** | * | * |
| ចុងអង្ករ | * | **** | | * |
| ស្រូវ | * | ** | * | * |
| មើមដំឡូងឈើ | | **** | * | |

**ចំណាំ**៖ ចំពោះចំណុចដែលមានសញ្ញាផ្កាយប្រាំ មានន័យថាមានច្រើន និងចំណុចដែលមានសញ្ញាផ្កាយមួយ មានន័យថាមានតិចតួច ចំណែកឯចំណុចដែលមិនមានសញ្ញាផ្កាយសោះនោះ មានន័យថាមិនមានទាល់តែសោះ។

ចំណីធម្មជាតិមានគុណភាពល្អប្រសើរសម្រាប់ទា។ ប្រសិនអាចឲ្យទាជ្រើសរើសចំណីទាំងនោះដោយខ្លួនវាគឺជាការល្អ ព្រោះវាដឹងថាតើចំណីប្រភេទណាដែលវាត្រូវការសម្រាប់ការលូតលាស់។ ប៉ុន្តែដោយសារជ

ម្ងឺជាបញ្ហាធំ ដូចជា ផ្តាសាយ អាសន្នរោគ និងប៉េស្តទា ដូចនេះទាត្រូវដាក់ទ្រុង ឬបង្ខាំង ហើយឲ្យចំណីដែលផ្សំឲ្យវាស៊ី ដោយប្រើធនធានចំណីដែលមាននៅមូលដ្ឋាន ឬក៏ផលិតនៅកសិដ្ឋានរបស់ខ្លួនដូចជា ត្រកួន ជន្លេន បន្លែ។ល។

### ១.៧.២.២. ការរៀបចំទ្រុងទា

ជម្រក ឬទ្រុងគឺជាផ្នែកដ៏សំខាន់មួយក្នុងចំណោមផ្នែកសំខាន់ៗផ្សេងទៀតនៃដំណើរការនៃការចិញ្ចឹមទា។ ទ្រុងអាចជួយការពារទាពីអាកាសធាតុមិនល្អ សត្រូវបំផ្លាញ និងជម្ងឺនានាតាមរយៈការបង្ខាំងផ្តាច់ចេញពីប្រភពជម្ងឺទាំងឡាយ។ ការធ្វើទ្រង់ទាត្រូវបានចែកចេញជាពីរ គឺទ្រុងដេក និងទ្រុងលេង (ទីធ្លាលេង)។[20]

#### ក. ទ្រុងដេក

ចំពោះការសង់ទ្រុងទាត្រូវធ្វើឡើងបណ្ដោយថ្ងៃ។ ទ្រុងត្រូវមានបណ្ដោយ ១០ម និងទទឹង ៤ម សម្រាប់ទាពី ២៥០ ទៅ ៥០០ក្បាល។ សម្ភារៈសម្រាប់សាងសង់ទ្រុងទាគួរប្រើប្រាស់សម្ភារៈដែលងាយស្រួលរកនៅក្នុងភូមិ ឬជិតៗផ្ទះដូចជា៖ ដើមឫស្សី ដើមកន្ទំថេត ដើមប្រេងខ្យល់ ដើមដូង ។ល។ ចំណែកឯដំបូលនៃទ្រុងគួរតែប្រក់ស្លឹកធ្វើពីត្នោត ឬស្បូវ ដោយជៀសវាងការប្រក់ដោយស័ង្កសី ព្រោះវាអាចឡើងកំដៅនៅពេលថ្ងៃក្តៅខ្លាំង ឬក៏នៅរដូវក្តៅ។ រីឯកម្ពស់នៃរោងត្រូវធ្វើប្រមាណពី ១.៥ម ទៅ ២ម។ សម្រាប់កសិករចិញ្ចឹមជាលក្ខណៈគ្រួសារតែត្រូវឲ្យមានខ្យល់អាកាសចេញចូលបានគ្រប់គ្រាន់។

**ចំណាំ៖**

- ទ្រុងដេករបស់ទាត្រូវមានខ្យល់ចេញចូលគ្រប់គ្រាន់ ប៉ុន្តែមិនត្រូវឲ្យមានខ្យល់ខ្លាំងពេកទេព្រោះទាចាញ់ខ្យល់ខ្លាំងដែលអាចបណ្ដាលឲ្យវាងាប់ (កុំធ្វើទ្រុងខ្ពស់ពេក)
- ប្តូរកំរាលពីរដងក្នុងមួយសប្តាហ៍ដើម្បីការពារការកើតមេរោគដែលអាចបង្កឲ្យទាឈឺ
- ក្រោយពីប្រមូលកម្រាលនោះចេញរួចហើយ កសិករអាចយកកម្រាលទាំងនោះទៅដាក់ដំណាំ ធ្វើជាជីធម្មជាតិដ៏ល្អ ដោយសារវាមានទឹក និងលាមកទាលាយគ្នា
- ការក្រាលកម្រាលវាជួយបញ្ចៀសកុំឲ្យមានការពងផ្ទាល់លើដី ដែលអាចធ្វើឲ្យពងទាមានការបែកស្រាំ ហើយធ្វើឲ្យពងទាមានសភាពស្អាតមិនប្រលាក់។

[20] ចាវ ប៉េងណាំ, អង្គការអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជា, «វីដេអូបច្ចេកទេសរបៀបចិញ្ចឹមទា», (២០១៣)

ខ. ទ្រុងលេង (ទីធ្លាលេង)

ទីធ្លាលេងរបស់ទាគឺនៅជុំវិញទ្រុងដេក ដែលគួរតែយកស្បៃនីឡុង ឬសំណាញ់ ឬក៏អាចយកជាសំណាញ់ដែកព័ទ្ធជុំវិញជាការប្រសើរ។ ទីធ្លាលេងរបស់ទាមានពីរផ្នែក គឺកន្លែងដាក់ចំណី និងកន្លែងលេងទឹក។ ដោយសារតែទាចូលចិត្តលេងទឹក ជាការល្អនៅក្នុងកសិដ្ឋានអាចធ្វើស្រះតូចល្មមមួយដើម្បីឲ្យទាចុះលេង។ បន្ថែមពីការធ្វើស្រះ ឬដាក់ទឹកចានដែកដើម្បីឲ្យទាលេង ឃើញមានការធ្វើជាទួលដីដើម្បីឲ្យទាឡើងទៅហាលខ្លួនឲ្យស្ងួតពីទឹក។ ចំពោះការដាក់ព័ន្ធសំណាញ់ គឺវាមានអត្ថប្រយោជន៍ដល់ទាដូចជា៖

- ដើម្បីការពារកុំឲ្យមានសត្វផ្សេងៗមកយាយីដល់ទាដូចជា ឆ្កែ ឆ្មា ពស់ កណ្ដុរ ឬសត្វផ្សេងៗ
- កាត់បន្ថយការចម្លងមេរោគពីខាងក្រៅមកខាងក្នុង និងពីខាងក្នុងទៅខាងក្រៅ
- ងាយស្រួលក្នុងការផ្តល់ចំណី ទឹក វ៉ាក់សាំង និងត្រួតពិនិត្យសុខភាព
- ការពារកំឲ្យទាទៅស៊ីបំផ្លាញដំណាំរបស់ប្រជាជននៅក្បែរកសិដ្ឋាន។

ជាការសង្កេតនៅតាមជនបទតំបន់ខ្លះឃើញមានកសិករមួយចំនួនដែលមើលទាហ្វូងលើសពី ១០០ ក្បាល នៅរដូវច្រូតកាត់។ ពួកគេបណ្ដើរជាហ្វូងដើម្បីរកចំណីនៅតាមវាលស្រែ ដែលជាចំណីធម្មជាតិដូចជាស្រូវ សត្វល្អិតតាមវាល។ល។ ពួកគេតែងតែឲ្យហ្វូងទាឈប់សម្រាកនៅវាលស្រែកន្លែងដែលគេអាចទៅដល់នៅពេលរសៀល ហើយទាហ្វូងទាំងនោះដេកនៅទីវាលល្ហល្ហេវ។ ជួនកាលកសិករប្រើព្រួលសម្រាប់បិទបាំងទាទាំងនោះ ហើយក៏ជួនកាលគ្មានអ្វីបិទបាំងទាំងអស់តែម្ចាស់នៅសម្រាកក្បែរនោះ។ វិធីនេះកសិករដែលចិញ្ចឹមទាលើសពី ១០០ក្បាល តែងតែអនុវត្តហើយការចិញ្ចឹមទាហ្វូងនេះគឺសម្រាប់យកសាច់។ កសិករខ្លះបណ្ដើរទាហ្វូងរបស់គេចម្ងាយឆ្ងាយដើម្បីឲ្យទារកអាហារ ហើយពួកគេក៏ចំណាយពេលច្រើនអាទិត្យជាមួយហ្វូងទា។

**១.៧.២.៣. ការជ្រើសរើសទា**

ការចិញ្ចឹមទាជាទូទៅមានគោលបំណងពីរៗ ទីមួយគឺការចិញ្ចឹមទាយកពង និងទីពីរគឺការចិញ្ចឹមទាយកសាច់។ កសិករត្រូវកំណត់ឲ្យច្បាស់ថាតើចង់ចិញ្ចឹមយកពង ឬយកសាច់ដើម្បីងាយស្រួលធ្វើការជ្រើសរើសពូជដែលល្អ និងទទួលបាននូវទិន្នផលខ្ពស់។

ប្រសិនបើកសិករមានបំណងចិញ្ចឹមទាពង ត្រូវទិញមេទាក្រមុំដែលមានអាយុ១ឆ្នាំ ព្រោះអាយុនេះទាចាប់ពងល្អទោះបីជាវាមានអាយុរហូតដល់ ៣ ឆ្នាំក៏ដោយ ក៏នៅតែអាចបន្តពងបានល្អដែរ។ កសិករគួរយល់ដឹងពីលក្ខណៈមេទាដែលមានពងល្អ ក្នុងនោះរួមមាន៖

- រោមមានពណ៌ស្រអាប់ ហើយមានស្លាបខ្លះបាក់

- គ្មានរោមលើក្បាលខាងក្រោយដោយសារឈ្មោលចឹកទាញនៅពេលឡើងពាក់
- មេទាដែលពងល្អមានដងខ្លួនទ្រវែង ។

ចូរធ្វើការកត់ចំណាំថា៖

- មេទាខ្លះមានអាយុប្រហាក់ប្រហែលគ្នាទៅនឹងទាដែលផលិតពងល្អដែរ ប៉ុន្តែមិនសូវពងនោះ គឺទាដែលមានរោមភ្លឺស្អាត
- ទាឈ្មោលមួយអាចពាក់មេទាពី ៧ ទៅ ១០ក្បាល
- ប្រសិនត្រូវទិញមេទាកូនកាត់ ត្រូវសាកសួរឲ្យច្បាស់ថាទាឈ្មោលដែលបានពាក់នោះ ជាពូជនាំចូលសុទ្ធល្អឬទេ ដើម្បីធានាថា កូនទាដែលបង្កាត់បានមានឈាមជាទាផលិតស៊ុត។

ចំពោះការចិញ្ចឹមទាសាច់វិញគួរជ្រើសរើសពូជដូចខាងក្រោម៖

- ត្រូវជ្រើសរើសទាដែលមានប្រភពច្បាស់លាស់
- ត្រូវជ្រើសរើសពូជទានៅក្នុងតំបន់ ដែលមិនធ្លាប់មានប្រវត្តិមានផ្ទុកជម្ងឺ មិនត្រូវយកពូជពីតំបន់ផ្សេងដែលអាចបណ្តាលឲ្យមានជម្ងឺមកជាមួយ
- ជ្រើសរើសយកពូជដែលមានឆ្អឹងធំ និងមាឌធំធូន់ល្អ (ទាប៉េកាំង)
- ជាទាជំនាន់ អ៊ី អ៊ិក្ស អិម (EXM) ដែលបង្កើតឡើងដោយការភ្ញាស់ចេញពីពងទា អ៊ី អ៊ិក្ស អិម
- ជ្រើសរើសយកកូនទាដែលមានឆ្អឹងរឹងមាំ ដងខ្លួនមានរាងជាចតុកោណស្មើរ
- ឆ្អឹងគុម្ពកន្ទុយរន្ធគូទត្រូវឃ្លាតឆ្ងាយពីគ្នាចំពោះទាមេ ចំណែកឯទាបាវិញត្រូវអោយមានឆ្អឹងនៅជិតគ្នា។[21]

### ១.៧.២.៤. ការទិញកូនទា

កូនទាមានលក់ជាទូទៅនៅទីផ្សារនៅភ្នំពេញ និងតាមទីប្រជុំជន។ កូនទាមួយក្បាលមានតម្លៃចន្លោះពី ១៥០០ ទៅ ២០០០ រៀល។ កសិករត្រូវជ្រើសរើសកូនទាដែលមានឆ្អឹងរឹងមាំ ហើយដងខ្លួនកូនទាមានរាងចតុកោណស្មើរ ឆ្អឹងនៅគុម្ពកន្ទុយរន្ធគូថត្រូវឃ្លាតឆ្ងាយពីគ្នា ភ្នែកភ្លឺថ្លា និងរោមស្អួតល្អ ។ ជួនកាលកូនទាដែលញ៉ាស់មកមានសុខភាពខ្សោយ ហើយងាប់នៅក្នុងរយៈពេលខ្លី ។ កូនទាខ្លះញ៉ាស់មកមិនគ្រប់លក្ខណៈ ប៉ុន្តែយើងមិនអាចមើលឃើញពីភាពកង្វះខាតរបស់វាដោយងាយស្រួល ហើយអាចនឹងងាប់ក្នុងរយៈពេលខ្លីដែរ។ ដូច្នេះកសិករត្រូវពិនិត្យមើលពីស្ថានភាព និងលក្ខណៈកូនទាឲ្យបានល្អិតល្អន់។ ប្រសិនបើមើលទៅមានការ

[21] So Thoura, Business Cambodia, (December 01, 2019)

សង្ស័យថា កូនទាណាមួយមិនមានសុខភាពល្អទេ សូមកុំទិញឲ្យសោះ ព្រោះវាអាចនឹងធ្វើឲ្យមានការខាតបង់។ កូនទាដែលទើបនឹងញាស់ ទោះបីមានសុខភាពល្អយ៉ាងណាក៏ដោយ ក៏តម្រូវឲ្យចំណាយពេលវេលាច្រើនសម្រាប់ការថែទាំវាឲ្យបានគ្រប់គ្រាន់។ កសិករអាចទិញកូនទាដែលមានអាយុ ២-៣ ខែ។ ទាដែលមានអាយុនេះមានតម្លៃថ្លៃបន្តិច តែវាមានសារៈប្រយោជន៍ច្រើន គឺទានៅអាយុនេះមិនសូវត្រូវការការថែទាំច្រើន និងមមាញឹកពេកទេ បើប្រៀបធៀបជាមួយនឹងការថែទាំកូនទា។ ដូច្នេះកសិករត្រូវជ្រើសរើសទាដោយមាន៖

- ភ្នែកភ្លឺ និងមូល
- រោមរាបជាប់ស្បែក និងភ្លឺថ្លា
- ទ្រូងទូលាយ
- មានដងខ្លួនវើបត្រង់
- និងករវែងស្អូច។

**ចំណាំ៖** ទាមានដងខ្លួនខ្លី ធាត់ អាចជាពូជដែលផលិតស៊ុតក្នុងកម្រិតទាប។

### ១.៧.៣. ការផលិតកូនទា

ទាជាធម្មតាមិនក្រាបពងទេ លើកលែងតែទាកាប៉ាដែលក្រាបពង និងភ្ញាស់ដោយខ្លួនវា។ ក្នុងករណីនេះពងទាត្រូវបានឲ្យក្រាបដោយមេមាន់ ហើយក៏អាចឲ្យមេមាន់បណ្តើរនៅអាទិត្យទីមួយ និងទីពីរក្រោយពេលញាស់ ។ បន្ទាប់មកទៀត ប្រសិនបើកសិករមានធនធានល្មមអាចធ្វើបាន កូនទាត្រូវយកចេញពីមេមាន់ ហើយកូនទាទាំងនោះត្រូវថែទាំដោយម្ចាស់កសិដ្ឋានផ្ទាល់ ( ដោយសារតែបច្ចេកវិទ្យាជឿនលឿន នៅតាមកសិដ្ឋានមួយចំនួនធំនាពេលបច្ចុប្បន្ន ឃើញមានការប្រើប្រាស់ជាទូរសម្រាប់ភ្ញាស់ពងទាដែលដំណើរការដោយចរន្តអគ្គិសនី )។

**ចំណាំ៖**

- ពងទាជាទូទៅមានទំហំធំជាងពងមាន់ ដូច្នេះហើយកសិករអាចដាក់ពងទាឲ្យមេមាន់ក្រាបត្រឹមតែ ១៥ គ្រាប់ប៉ុណ្ណោះ ។
- ចំនួនពងទាដែលដាក់ឲ្យមាន់ក្រាបត្រូវមើលទៅលើទំហំខ្លួនរបស់មេមាន់
- រក្សាកន្លែងដែលមេមាន់ក្រាបឲ្យស្អាតល្អ និងផ្តល់សំបុកពងដែលមានចំបើងក្រាលត្រឹមត្រូវ
- ទីកន្លែងទាក្រាបត្រូវរៀបចំ ដោយផ្តល់លទ្ធភាពឲ្យមេមាន់ក្រាបពងអាចចុះរកចំណី និងទឹកបានងាយស្រួល ។

នៅពេលកំពុងក្រាបពងមានបញ្ហាមួយអាចកើតឡើង គឺការចុះចោលសំបុក។ ប្រសិនបើមេមាន់មិនត្រឡប់ចូលក្រាបពងវិញទេ កសិករត្រូវពិនិត្យមើលឲ្យបានច្បាស់អំពីមូលហេតុ។ បញ្ហាដំបូងដែលត្រូវគិតនោះគឺមានស្រមើរ (សត្វល្អិតតូចជញ្ជក់ឈាមមេមាន់) នៅក្នុងសំបុកដែលមាន់ក្រាប។ ក្នុងករណីនេះត្រូវយកពងទាទាំងអស់ចេញពីសំបុក ហើយរក្សាទុកកន្លែងដែលមានកម្តៅ។ បន្ទាប់មកទៀតត្រូវយកចំបើងដុតចោល ហើយយកប្រេងកាត ឬទឹកក្តៅស្រោចលើបង្គី ឬល្អីដែលជាសំបុកដែលមេមាន់ក្រាប។ ក្រោយពីអនុវត្តការងារនេះរួចត្រូវយកចំបើងថ្មីមកដាក់សារជាថ្មីទើបយកពងទាដាក់ចូលទៅក្នុងសំបុកវិញ។ កុំភ្លេចដាក់ថ្នាំជក់ ( ថ្នាំខ្លាំងដាក់នៅក្នុងសំបុកក្រាបពងដើម្បីជៀសវាងស្រមើរសារជាថ្មី ) ។ រយៈពេលនៃការក្រាបពងអាស្រ័យលើពូជទា ដែលរយៈពេលក្រាបរបស់វាខុសៗគ្នា៖

- ពងទានៃពូជទាទូទៅ ត្រូវការរយៈពេល ២៦ ទៅ ២៨ថ្ងៃដើម្បីញាស់បាន
- ពងទាកាប៉ាត្រូវការរយៈពេល ៣៥ថ្ងៃ ដើម្បីញាស់
- កូនទាពូជកូនកាត់ត្រូវការរយៈពេល ៣០ថ្ងៃ ដើម្បីញាស់ ។

**ត្រូវចងចាំថា៖**

- ជ្រើសរើសពងទាស្អាតមានទំហំធំ និងទម្រង់មូលទ្រវែងដែលមានសំបករលោង
- ប្រសិនបើពងប្រលាក់លាមក ឬកខ្វក់ត្រូវជូតសំអាតជាមួយទឹកក្តៅល្មមហើយដាក់សំដិលឲ្យស្ងួតភ្លាម
- កូនទាទាំងអស់មិនញាស់ក្នុងពេលជាមួយគ្នានោះទេ ។ ចំពោះកូនទាដែលញាស់មុនគេបង្អស់អាចយកចេញទៅដាក់ក្នុងកញ្ជេរក្រាលអង្កាម ឬចំបើង ហើយគ្របបាវពីលើរង់ចាំរហូតដល់កូនទាទាំងអស់ញាស់រួចរាល់។ ការធ្វើតាមវិធីនេះជៀសវាងមេមាន់ជាន់កូនទា ឬមួយចាកចេញពីសសំបុកក្រាបពង ។

### ១.៧.៤. ការចិញ្ចឹមកូនទា

ក្នុងការចិញ្ចឹមកូនទាត្រូវទាមទាឲ្យមានការយកចិត្តទុកដាក់ខ្ពស់ ព្រោះថាកូនទានៅតូច និងមិនទាន់ស៊ាំទៅនឹងបរិយាកាសខាងក្រៅ។ ពេលវេលាល្អសម្រាប់ចិញ្ចឹមកូនទា គឺនៅដើមរដូវវស្សា។ កូនទាត្រូវការការថែទាំបានល្អ ដូចជាកំដៅត្រឹមត្រូវ ការផ្តល់ចំណីដែលសមស្រប និងអនាម័យល្អ។ ការអនុវត្តការថែទាំ និងគ្រប់គ្រងបានល្អរួមបញ្ចូលទាំងការផ្តល់ចំណី ធ្វើឲ្យអត្រានៃការរស់រានរបស់កូនទាមានកម្រិតខ្ពស់ ។

### ១.៧.៤.១. កន្លែងដាក់កូនទា

កូនទាដែលមានអាយុពីញ៉ាស់ហួតដល់អាយុ ១៥ ថ្ងៃត្រូវរក្សាទុកក្នុងកញ្ជេរ ឬទ្រុងស្អាត ។ វិធានការដែលត្រូវអនុវត្តមានដូចខាងក្រោមះ

- នៅក្នុងកញ្ជេរ ឬទ្រុងត្រូវមានកម្រាលអង្កាម អាចម៍រណា ឬចំប៉ើង កំពស់ ២ ទៅ ៣ស.ម
- កំរាលត្រូវផ្លាស់ប្តូរជានិច្ចដើម្បីឲ្យកូនទាស្ងួតល្អ
- អាចបន្ថែមអង្កាម អាចម៍រណា ឬចំប៉ើង រៀងរាល់ថ្ងៃលើកំរាលចាស់
- កសិករមិនគួរដាក់កូនទាច្រើនពេកទេនៅក្នុងកញ្ជេរតែមួយ ដើម្បីឲ្យពួកវាមានលទ្ធភាពធ្វើចលនា ប៉ុន្តែបើទូលាយពេកធ្វើឲ្យកូនទាមិនមានកម្តៅគ្រប់គ្រាន់ធ្វើឲ្យពួកវាអាចនឹងងាប់ ។

**ចំណាំះ**

- អគ្គីសនីត្រូវបានប្រើប្រាស់សម្រាប់ការចិញ្ចឹមទាជាលក្ខណៈឧស្សាហកម្ម ហើយអ្នកដែលមានបណ្តាញអគ្គិសនី ក៏អាចប្រើប្រាស់បានដែរ ដើម្បីផ្តល់កម្តៅដល់កូនទាពី ១ ទៅ ៧ ថ្ងៃ
- នៅតំបន់ជនបទ និងសម្រាប់កសិករចិញ្ចឹមទាខ្នាតតូច អាចប្រើធ្យូងសម្រាប់ផ្តល់កម្តៅបាន
- ឆ្នាំងដី ឬក្អមដែលមានចោះរន្ធតូចៗនៅសងខាង និងគម្របពីលើ អាចប្រើសម្រាប់ដាក់ធ្យូងផ្តល់កម្តៅនេះដល់កូនទា
- ដើម្បីឲ្យមានកម្តៅនៅក្នុងទ្រុងល្អ ត្រូវមានបិទជញ្ជាំងជុំវិញ ដោយប្រើស្លឹកត្នោត ឬបាវចាស់ៗកុំឲ្យខ្យល់បកចូលខ្លាំង ។

កសិករម្ចាស់ទាត្រូវពិនិត្យមើលសញ្ញាសម្រាប់វិធានការណ៍ ចាំបាច់នានាធ្វើឲ្យកូនទាមានសុខភាពល្អ

- នៅពេលមានកម្តៅខ្លាំងនៅក្នុងទ្រុង ឬកញ្ជេរ កូនទាងើបក្បាលឡើងលើ និងដួនកាលស្រែក។ ប្រសិនបើពិនិត្យឃើញមានលក្ខណៈបែបនេះ កសិករត្រូវយកអ្វីដែលបាំងជុំវិញ និងខាងលើចេញដើម្បីឲ្យមានខ្យល់ចេញចូល ។
- ចាំបាច់ត្រូវពិនិត្យមើលកម្រាល ប្រសិនបើកខ្វក់ដោយទឹកលាមក និងចំណី វាក៏អាចបង្កឲ្យកម្តៅខុសធម្មតានៅក្នុងទ្រុងទាផងដែរ
- នៅពេលដែលត្រជាក់ខុសធម្មតា កូនទាប្រមូលផ្តុំ ដើម្បីឲ្យមានកម្តៅ។ នៅពេលនេះកសិករត្រូវផ្តល់កម្តៅឲ្យពួកវា តតាមវិធីដែលបានធ្វើកន្លងមក ។

- កូនទាត្រូវរក្សានៅក្នុងសីតុណ្ហភាពពី ២៦,៥ ទៅ ២៩,៥ អង្សារសេ នេះសម្រាប់កូនទាអាយុ ១ ថ្ងៃ ទៅ ១០ ទៅ ១៥ ថ្ងៃ ។

**១.៧.៤.២. ការផ្តល់ចំណី**

កូនទាចាប់ផ្តើមស៊ីចំណីក្រោយពេលញាស់ហើយ និងធំធាត់យ៉ាងឆាប់រហ័ស ហេតុដូច្នេះហើយត្រូវផ្តល់ចំណីដល់វាឲ្យបានត្រឹមត្រូវដើម្បីស្រូបយកសក្តានុពលនៃការលូតលាស់របស់វា និងមានសុខភាពល្អ។ ចំពោះប្រភេទចំណីគឺដូចដែលបានបង្ហាញនៅតារាងទី ១ ។

- ផ្តល់ចំណីដល់កូនទាត្រូវធ្វើពី ៤ ទៅ ៥ដង ក្នុងមួយថ្ងៃ
- លាយចំណីផ្សំឲ្យច្រើនមុខ
- កូនទាចូលចិត្តស៊ីចុងអង្ករ និងកន្ទក់ឆៅ ឬចំអិន ដែលជាប្រភពថាមពលសំខាន់
- បន្ថែមប្រូតេអ៊ីនដូចជា ត្រីតូចៗ ឬជន្លេនកាត់តូចៗ ជួយធ្វើឲ្យកូនទាឆាប់ធំធាត់លឿន
- បន្ថែមក្តាម ខ្យង ដែលជាប្រភពរ៉ែ
- ផ្តល់បន្លែបៃតងដូចជាត្រកួន ឬចកបាយទា ដែលជាប្រភពវីតាមីន ។

**១.៧.៤.៣. ការគ្រប់គ្រងកូនទា**

ទាជាទូទៅចូលចិត្តលេងទឹកដើម្បីហែល ក៏ដូចជាស្វែងរកចំណីនៅក្នុងទឹក ហេតុដូចនេះកសិករត្រូវៈ

- ឲ្យកូនទាលេងទឹកនៅក្នុងចានដែលមានទឹក ៣ ទៅ ៥ ស.ម ក្នុងរយៈពេលពី ៤ ទៅ ៥នាទី នៅពេលថ្ងៃត្រង់ ឬអាចបង្កើតជាស្រះតូចល្មមមួយ
- ត្រូវឲ្យកូនទាសំដិលខ្លួនឲ្យស្ងួត មុនដាក់ចូលទៅក្នុងទ្រុង ឬកញ្ជេរវិញ
- នៅរដូវវស្សា កូនទាក៏អាចឲ្យហែលទឹកនៅស្រះតូចៗ និងប្រឡាយនៅក្បែរផ្ទះ
- កសិករត្រូវប្រាកដថាមានពន្លឺថ្ងៃគ្រប់គ្រាន់ ដើម្បីឲ្យកូនទាលេងទឹកនៅពេលថ្ងៃត្រង់។

**១.៧.៤.៤. ការគ្រប់គ្រងកូនទាអាយុ ២ ទៅ ៤សប្តាហ៍**

\+ **នៅពេលដែលកូនទាមានអាយុ ២អាទិត្យ** មានន័យថាពេលវេលានៃការថែទាំថយចុះ មានសកម្មភាពមួយចំនួន ដែលត្រូវធ្វើរហូតដល់កូនទាមានអាយុ ៤អាទិត្យៈ

- ដាក់កម្រាលដូចជាអង្កាម អាចម៍រណា និងចំប៉ើងតែផ្នែកមួយនៃទ្រុងទា ព្រោះនៅអាយុនេះកូនទាត្រូវការខ្យល់អាកាសចេញចូលច្រើន និងពន្លឺថ្ងៃ
- នៅពេលថ្ងៃកូនទាដើរស្វែងរកចំណីដូចជា សត្វល្អិត និងរុក្ខជាតិនៅក្បែរទ្រុង ហើយទីកន្លែងនោះអាចជាវាលស្រែ និងថ្លុកដែលសំបូរចំណីធម្មជាតិដូចជា សត្វល្អិត កូនក្តាម ខ្យង និងរុក្ខជាតិក្នុងទឹក

- ទោះបីជាដើររកចំណីដោយខ្លួនវាក៏ដោយ ការផ្តល់ចំណីអាហារបន្ថែមដល់ទា និផ្តល់ទឹកផឹកពីរដង ក្នុងមួយថ្ងៃធ្វើឲ្យកូនទាមានការលូតលាស់ឆាប់
- ប្រសិនកសិករអាចមានលទ្ធភាពរកស្តុកចំណីធ្វើពីជ័រ ពួកគាត់អាចយកមកប្រើប្រាស់សម្រាប់ផ្តល់ចំណីដល់ទា។ ទន្ទឹមគ្នានេះដែរ កសិករក៏អាចធ្វើស្តុកចំណីពីបំពង់ឫស្សី ឬដបទឹកបរិសុទ្ធ។

**ចំណាំ៖**

- បញ្ចូលកូនទាក្នុងទ្រុងមានដំបូលនៅពេលភ្លៀង
- នៅពេលថ្ងៃត្រង់កូនទាត្រូវបញ្ចូលក្នុងម្លប់ក្រោមដើមឈើពេលពន្លឺថ្ងៃនៅពេលមានកម្តៅក្តៅខ្លាំង
- ក្រោយពេលនេះ កូនទាអាចបន្តឲ្យរកចំណីតែត្រូវបញ្ចូលទ្រុងមុនងងឹត
- ការផ្តល់ចំណីកូនទានៅពេលល្ងាចនឹងធ្វើឲ្យកូនទាត្រឡប់មកកន្លែងដើមយ៉ាងងាយស្រួល។

**+ នៅពេលកូនទាមានអាយុ ៤អាទិត្យ** តម្រូវការលក្ខខណ្ឌដូចមានខាងក្រោម៖

- ទីកន្លែងសម្រាប់ទាមួយក្បាល គឺ ០,០១ម២។ ប៉ុន្តែប្រសិនបើកសិករមានដីតូចយ៉ាងហោចណាស់ត្រូវផ្តល់ ០,០០៥ម២ សម្រាប់ទាក្នុងមួយក្បាល ហើយទ្រុងត្រូវមានខ្យល់ចេញចូលល្អ និងស្អាត
- នៅពេលព្រឹក ផ្តល់ឲ្យកូនទានូវចំណីដែលបានផ្សំ និងទឹក។ ប្រើប្រាស់ស្តុកស្អាតសម្រាប់ដាក់ទឹក និងចំណី ។
- ផ្តល់ចំណីដល់កូនទានៅក្រៅទ្រុងរបស់វា តែនៅកន្លែងដែលធ្លាប់ឲ្យស៊ីជាប្រចាំ
- ទាពេញវ័យចូលចិត្តទឹកភ្លៀងជាពិសេសនៅពេលភ្លៀងខ្យល់ខ្លាំង ។

**ចំណាំ៖**

- នៅពេលដែលទាមានអាយុចាប់ពី ៣-៤ ខែ ពួកវាអាចធន់នឹងអាកាសធាតុប្រែប្រួលខ្លាំងបានហើយ។ ដូច្នេះមិនត្រូវការការថែទាំជិតដល់ដូចពីមុនទៀតឡើយ។

## ១.៧.៥. ការគ្រប់គ្រងទាពេញវ័យ

### ១.៧.៥.១. ការចិញ្ចឹមទានៅក្នុងស្រែ

ទាគួរត្រូវចិញ្ចឹមនៅកន្លែងមួយមានការបិទបាំងល្អក្រោមការគ្រប់គ្រងផ្ទាល់ពីម្ចាស់។ ក្នុងករណីនេះកសិករត្រូវការថវិកាបន្ថែមសម្រាប់សាងសង់ទីធ្លាចិញ្ចឹមទា កំលាំងពលកម្ម និងចំណី។ បើមិនធ្វើទ្រុងទេ ទាអាចចូលស៊ីស្រូវនៅក្នុងស្រែ ហើយមិនអាចការពារមិនឲ្យសត្វផ្សេងទៀតមកក្បែរ។ កសិករមិនត្រូវឲ្យទាចុះស្រែនៅពេលដែលស្រូវទើបសាបព្រួស ឬទើបស្ទូងរួច និងនៅពេលស្រូវចាប់ផ្តើមផលិតគ្រាប់នោះទេ។ ចំណែកឯចំណីដែលផ្តល់ឲ្យទាត្រូវដាក់នៅធុងបិតជិត និងយកចេញនៅពេលវាឈប់ស៊ី។ កសិករខ្លះមិនឲ្យ

ទាចុះស៊ីក្នុងស្រែទាល់តែសោះដោយយល់ថា ទាអាចធ្វើឲ្យដីស្រែហាប់នៅពេលកំពុងតែធ្វើស្រែ។ វាជាការត្រឹមត្រូវមួយដែរ ដែលបញ្ចៀសមិនឲ្យទាចូលក្នុងស្រែ ព្រោះថា ទាអាចនឹងស៊ីសន្ទូងដែលទើបនឹងដុះ និងគ្រាប់ស្រូវដែលកំពុងតែដាក់គ្រាប់។ ប៉ុន្តែទន្ទឹមគ្នានេះក៏មានផលប្រយោជន៍មួយចំនួនដែលនឹងទទួលបានពីការប្រលែងទាចូលក្នុងស្រែ។ ផលទាំងនោះរួមមាន៖

- នៅពេលដែលទានៅក្នុងស្រែ វាអាចស៊ីសត្វល្អិតបំផ្លាញស្រូវដូចជាក្តាម ខ្យង កុំឲ្យមកស៊ីស្រូវ និងស៊ីស្មៅតូចៗដែលដុះយាយីរដល់ស្រូវ
- កាត់បន្ថយការចំណាយលើចំណីទា ព្រោះទាបានស៊ីនូវចំណីធម្មជាតិពីក្នុងស្រែ
- ទាចុះអាចម៍ក្នុងស្រែដែលផ្តល់ជាជីវជាតិដល់ដីស្រែ ផ្តល់នូវប្រភពអាសូត និងរ៉ែយ៉ាងល្អសម្រាប់ជំនួយដល់ការលូតលាស់របស់ស្រូវ។

**១.៧.៥.២. ការគ្រប់គ្រងទាចាស់ និងទាថ្មី**

ដើម្បីធានាបាននូវការផ្តល់ស៊ុតបានល្អ និងទៀងទាត់ព្រមទាំងទាន់ពេលវេលាដើម្បីផ្គត់ផ្គង់ទីផ្សារ ( មុំយ) កសិករត្រូវចាប់ផ្តើមចិញ្ចឹមទាថ្មីបន្ថែម នៅពេលដែលទាពងមាន អាយុ ២-៣ឆ្នាំ។ នៅពេលដែលទាថ្មីមានអាយុ ៣-៥ខែកូនទាហ្វូងថ្មីទាំងនោះអាចបញ្ចូលក្នុងហ្វូងទាចាស់បានហើយ។ ការដាក់ទាថ្មីឲ្យនៅជាមួយទាចាស់ ដើម្បីឲ្យទាចាស់ជួយបង្ហាត់បង្ហាញដល់ទាថ្មីដូចជាការដើររកចំណី កន្លែងដែលត្រូវទៅលេងឬកន្លែងរស់នៅ។ ប្រសិនបើគ្មានទាចាស់ ឬក៏មិនបានដាក់បញ្ចូលគ្នានោះទេ ត្រូវទុកក្នុងទ្រុង១អាទិត្យ ជាពិសេសទាញីជំទង់ដែលទើបទិញចូល ដើម្បីឲ្យវាស្គាល់បរិយាកាសជុំវិញដែលវារស់នៅ។

- ទាត្រូវបញ្ចេញទៅដើលេងខាងក្រៅពីរដងក្នុងមួយថ្ងៃ នៅពេលព្រឹក និងល្ងាច។ នៅពេលនោះពួកវាអាចដើររកចំណីដោយខ្លួនវា (ចំណីធម្មជាតិនៅតាមស្រែ)
- ចំណីត្រូវផ្តល់ឲ្យទានៅខាងក្នុងទីធ្លាកន្លែងចិញ្ចឹម ឬក្នុងទ្រុង ជៀសវាងបក្សីផ្សេងទៀតចូលមកដណ្តើមចំណី។ ចំណីត្រូវដាក់ឲ្យទៀងពេលដើម្បីជាផ្នាក់ក្នុងការហៅទាអោយត្រឡប់ចូលទ្រុងវិញជារៀងរាល់ថ្ងៃ
- ការដាក់ទាចូលទ្រុងវិញនៅពេលមេឃរាងងងឹត ប្រសិនបើបង្ខំទាឲ្យចូលទ្រុងនៅវេលាថ្ងៃពេកអាចធ្វើឲ្យខុសប្រក្រតីដែលនាំឲ្យទាមិនចូលទ្រុងតែម្តងក៏មានដែរ។
- មិនត្រូវផ្តល់ទឹកអោយទាផឹកភ្លាមនោះទេនៅពេលវាទើបត្រឡប់មកពីដើរឆ្ងាយ តែត្រូវផ្តល់ឲ្យវានៅក្នុងទ្រុងនាពេលយប់។

### ១.៧.៥.៣. ការគ្រប់គ្រងទាពង

មានលក្ខខណ្ឌមួយចំនួនដែលត្រូវអនុវត្តក្នុងការគ្រប់គ្រងទាពង ចំពោះកសិករប្រកបរបរចិញ្ចឹមទានៅតាមជនបទ។ ការអនុវត្តន៍ត្រឹមត្រូវធ្វើឲ្យទទួលផលច្រើនទាំងការផលិតស៊ុត និងសុខភាពរបស់ទា។ ខាងក្រោមនេះជាអ្វីដែលកសិករគួរធ្វើ និងប្រុងប្រយ័ត្នះ

- លែងទាពងអោយចេញពីកន្លែងពង ឬទ្រុងនៅកំឡុងម៉ោង ៧និង៣០នាទីព្រឹក ដោយសារមុនពេលព្រឹកនេះ ទាបានពងរួចរាល់ស្ទើរតែទាំងអស់។
- ទាឆាប់ទទួលបាននូវទម្លាប់ថ្មីៗដែលផ្លាស់ប្តូរនៅក្នុងជីវិតរបស់វា ដូច្នេះកសិករត្រូវអនុវត្តការងារទៀតទាត់ និងជាប្រចាំ។ ទានឹងមិនពងបានត្រឹមត្រូវនោះទេ ប្រសិនធ្វើឲ្យវាមិនសប្បាយចិត្ត ដោយសារការផ្លាស់ប្តូរពេលវេលាក្នុងការលែងវាចេញក្រៅទ្រុង ឬក៏បញ្ចូលក្នុងទ្រុងវិញ
- គួរតែរក្សាស្ថានភាព ឬបរិយាកាសនៅជុំវិញបរិវេណ និងទីធ្លាទ្រុងទាឲ្យមានសភាពធម្មតាជាប្រចាំដូចរាល់ថ្ងៃ។ ការធ្វើឲ្យទាផ្អើលដោយសារឆ្កែ ឆ្មា និងអ្វីចំឡែកមកក្បែរទ្រុងទាធ្វើឲ្យទាផ្អាកពងហើយការអាក់ពងនេះអាចមានរយៈពេលវែងដល់២ខែ។

**ចំណាំះ**

- ត្រូវចងចាំថាការថយចុះក្នុងការផលិតស៊ុត ប៉ះពាល់ដល់ចំណូលកសិករ ហើយប្រសិនបើវាកើតឡើងដោយចៃដន្យ មិនងាយនឹងធ្វើឲ្យត្រឡប់មកដូចដើមទេ
- អនុវត្តការងារឲ្យទៀងទាត់ជាមួយទាពងដូចជាការពិនិត្យទូទៅ និងការគ្រប់គ្រងត្រឹមត្រូវធ្វើឲ្យកសិករទទួលជោគជ័យក្នុងការចិញ្ចឹមទាពង។

### ១.៧.៥.៤. ការការពារទាពីជម្ងឺ

គួរចងចាំថា កសិករមិនអាចបង្កាត់ទា និងចិញ្ចឹមទាឲ្យមានសុខភាពល្អប្រសិនបើគេមិនចាប់ផ្តើមជាមួយទាដែលមានសុខភាពល្អ។ ការព្យាបាលជំងឺ ជាទូទៅមានការលំបាក និងមានតម្លៃថ្លៃ ដូច្នេះជាការចាំបាច់ត្រូវធ្វើការការពារជម្ងឺកុំឲ្យកើតមាន។ គោលការណ៍ខាងក្រោមនេះអាចជួយឲ្យការចិញ្ចឹមឃ្លាតឆ្ងាយពីជម្ងឺនានា។

- ជានិច្ចកាលផ្តល់ចំណីដែលស្រស់ថ្មី មិនរលួយស្អុយ និងមានជីវជាតិគ្រប់គ្រាន់
- សំអាតស្នូកចំណី កន្លែងផឹកទឹក និងទ្រុងទាប្រចាំថ្ងៃ ត្រូវប្រាកដថាលាមកទាមិននៅសេសសល់ដែលអាចបង្ករជាមេរោគដល់ទា
- មិនត្រូវឲ្យទាស្ថិតនៅក្រោមពន្លឺថ្ងៃខ្លាំង និងភ្លៀង (ជាពិសេសកូនទា)
- ទ្រុងទាត្រូវសម្អាត និងមានខ្យល់ចេញចូលល្អ រក្សាបរិយាកាសល្អជានិច្ច

- ចាក់ថ្នាំការពារជម្ងឺទាសំខាន់ៗឲ្យទាន់ពេលវេលា និងឲ្យបានត្រឹមត្រូវតាមអ្វីដែលបានកំណត់
- យកទាឈឺចេញពីហ្វូង បង្ការការឆ្លងរាលដាលទៅកាន់ទាផ្សេងទៀត។

**ចំណាំ៖** ជាការល្អគួរស្វែងរកការផ្តល់សេវាកម្មការចាក់ថ្នាំការពារដល់ទាដើម្បីការពារជាមុន

### ១.៧.៥.៥. ការចាក់ថ្នាំការពារជម្ងឺ

ជម្ងឺទាមានច្រើនតែអាសន្នរោគ និងប៉េស្តទា ហើយតែងតែកើតមានឡើងនៅលើប្រទេសកម្ពុជាក្នុងពេលដែលទាមានអាយុប្រហែល ៦អាទិត្យ ឬនៅពេលដែលកូនទាចាប់ផ្តើមមានរោមពេញទ្រូង។ នៅពេលនោះវាត្រូវចាក់ថ្នាំការពារជំងឺអាសន្នរោគ និងប៉េស្តទា។

#### ក. ជំងឺអាសន្នរោគទា

ជំងឺអាសន្នរោគទា ជាជំងឺដូចគ្នាដែលបង្កឡើងទៅលើមាន់ និងបក្សីដ៏ទៃទៀត។ រោគសញ្ញានៃជំងឺមាន៖

- មានសភាពទន់ខ្សោយ មិនមានកម្លាំងក្នុងការដើរហើររកចំណី
- ឡើងកំដៅខុសធម្មតា
- មានលក្ខណៈហើមសន្លាក់ជើង
- ឈឺភ្នែក ឬហើមភ្នែក មានហូរទឹកភ្នែក និងឡើងពណ៌ក្រហម
- រាករូស និង
- ជួនកាលហើមក្បាល។

ការស្លាប់អាចកើតឡើងមួយរំពេច ដោយមិនបង្កឲ្យឃើញរោគសញ្ញាច្បាស់លាស់ ឬក៏ឃើញទាឈឺច្រើនថ្ងៃឡើយ។ ប្រសិនបើវះកាត់ទាឈឺមួយក្បាលដែលងាប់រួចនោះ ហើយពិនិត្យឃើញមានសភាព ថ្លើមរីកធំពណ៌ស្លេកស្លាំង និងមានពណ៌អុជប្រផះជាច្រើនទៀតនោះ កសិករត្រូវតែបង្កើនការប្រុងប្រយ័ត្នកាន់តែខ្លាំងលើសុខភាពទាផ្សេងទៀតដែលនៅរស់។ ចូរធ្វើការចាក់ថ្នាំវ៉ាក់សាំងការពារទាប្រឆាំងនឹងជម្ងឺនេះ។ ចំពោះទាដែលមិនបានចាក់វ៉ាក់សាំងការពារ ដើម្បីប្រឆាំងការផ្ទុះឡើងនៃជម្ងឺ អាចប្រើថ្នាំក្រុមពពួកស៊ុលហ្វាដើម្បីព្យាបាល។ កសិករចិញ្ចឹមទាត្រូវប្រើប្រាស់ថ្នាំនេះដោយអនុវត្តតាមការណែនាំខាងក្រោមសម្រាប់ព្យាបាលទាដូចខាងក្រោម៖

- បង្ខាំងទាឲ្យនៅក្នុងទ្រុង
- មិនត្រូវឲ្យទាផឹកទឹកក្នុងរយៈពេល ២-៣ម៉ោង ដើម្បីធ្វើឲ្យវាស្រេចទឹកខ្លាំង

- បន្ទាប់មកទើបដាក់ទឹកលាយថ្នាំឲ្យវាផឹក និង
- ធ្វើតាមរបៀបនេះរយៈពេល ៣-៥ថ្ងៃ។

វិធីដែលមានប្រសិទ្ធិភាពគឺត្រូវចាក់ថ្នាំការពារតាមអាយុរបស់ទា។ កូនទាត្រូវចាក់ថ្នាំការពារជម្ងឺនេះ តាមអាយុដូចខាងក្រោមៈ

- ចាក់លើកទីមួយនៅពេលទាមានអាយុ ១-១ខែកន្លះ គឺនៅពេលទាមានរោមពេញខ្លួនដោយចាក់ត្រង់ក្រោមស្បែក
- បន្ទាប់ពីការចាក់លើកទីមួយ ១៥ថ្ងៃក្រោយត្រូវចាក់ជាលើកទី ពីរ និង
- ក្រោយមកទៀត ទាត្រូវចាក់ក្នុងមួយឆ្នាំម្តង

រូបភាពទី៥៖ វ៉ាក់សាំងការពារអាសន្នរោគ




### ខ. ជំងឺប៉េស្តទា

រោគសញ្ញានៃជំងឺនេះ ប្រហាក់ប្រហែលនឹងជំងឺអាសន្នរោគទាដែរ ហើយតែងតែច្រឡំ ប៉ុន្តែមានរោគសញ្ញាមួយចំនួន ខុសគ្នា ដែលកសិករអាចរកឃើញបាន៖

- ទាទន់ខ្សោយដោយគ្មានឃើញហើមសន្លាក់ ឬឡើងកម្តៅ
- មានចេញទឹកភ្នែកជាប់ ហើយរោមជុំវិញភ្នែកមានជាប់ពពឹកភ្នែក
- មានហៀរសំបោរ និងរាគរូស។

ទាងាប់ក្នុងរយៈពេល ៣ថ្ងៃក្រោយពេលចាប់ផ្ដើមឈឺ។ ប្រសិនបើវះមើលមិនឃើញមានសញ្ញានៃជម្ងឺនោះទេ ត្រូវយកបេះដូងទៅពិនិត្យបើឃើញមានឈាមជាំតូចៗនៅលើសាច់ដុំបេះដូង ហើយចំណែងកោះវិញមើលទៅរាងជាំខ្មៅ ទាទាំងនោះហើយទាដែលមានជម្ងឺប៉េស្តទា។

ប្រការត្រូវចងចាំ៖

- ជម្ងឺនេះគ្មានថ្នាំសម្រាប់ព្យាបាលទេ
- ប្រសិនបើទិញទាមកពីក្រៅ ទុកវាយ៉ាងហោចណាស់ ៣អាទិត្យ និងពិនិត្យតាមដានរោគសញ្ញានៃជំងឺជាមុនសិន មុននឹងបញ្ចូលវាទៅក្នុងហ្វូងជាមួយទាហ្វូងដែលមានស្រាប់នៅផ្ទះ ឬកសិដ្ឋាន។

ការចាក់វ៉ាក់សាំងការពារត្រូវប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវតាមកាលកំណត់ អាយុកាល ពេលវេលា បរិមាណ និងចំនួនដងនៃការចាក់។ ខាងក្រោមនេះជាតារាងណែនាំខ្លះៗដើម្បីធ្វើការចាក់វ៉ាក់សាំងសម្រាប់ទា។

រូបភាពទី៦៖ វ៉ាក់សាំងការពារប៉េស្តទា




តារាងទី២៖ កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺទា

| ល.រ | ឈ្មោះវ៉ាក់សាំង | អាយុទា | វិធីប្រើ | កម្រិតក្នុង១ក្បាល | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ប៉េស្តទា | ៣ថ្ងៃ | ចាក់សាច់ដុំទ្រូង | ០.៣សេសេ | លើកទី១ |
| ២ | អាសន្នរោគទា | ១ខែ | ចាក់សាច់ដុំទ្រូង | ០.៣សេសេ | លើកទី១ |
| ៣ | ប៉េស្តទា | ៤៥ថ្ងៃ | ចាក់សាច់ដុំទ្រូង | ១សេសេ | លើកទី២ |
| ៤ | រលាកថ្លើម | ២ខែ | ចាក់សាច់ដុំទ្រូង | ១សេសេ | |
| ៥ | អាសន្នរោគទា | ៤ខែ | ចាក់សាច់ដុំទ្រូង | ១សេសេ | លើកទី២ |

## ១.៨. ស្ថិតិផលិតកម្មសត្វនៅកម្ពុជា[22]

ផលិតកម្មសត្វមានការរីកចម្រើនគួរជាទីពេញចិត្ត ជាពិសេសការកើនឡើងនៃកសិដ្ឋានចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានប្រមាណ ១៩% ធៀបនឹងផលិតកម្មសត្វសរុបក្នុងឆ្នាំ ២០១៧ និងអនុវិស័យនេះក៏បានចូលរួមលើកកម្ពស់សន្តិសុខស្បៀង ទ្រទ្រង់ជីវភាពរបស់កសិករក្រីក្រ និងជាប្រភពក្នុងការផ្តល់ប្រាក់ចំណូល អាហារូបត្ថម្ភ ប្រភពថាមពលកកើតឡើងវិញ និងជីសរីរាង្គ។

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារ និងពាណិជ្ជកម្មនៅកម្ពុជាបានកំពុងតែមានការវិវឌ្ឍន៍គួរឲ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើននេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹម ការជ្រើសរើស និងការបង្កាត់ពូជសត្វ ការឲ្យចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ជារួមផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល ៥ឆ្នាំ ( ២០១០ ដល់ ២០១៤ ) ជាការកត់សម្គាល់ឃើញមានការកើនឡើងច្រើនដែលមានចំនួនសរុប ២៦,៩២១,៣៨៣ក្បាលក្នុងឆ្នាំ២០១០ និង ៣១,៤១៨,០៤១ក្បាលក្នុងឆ្នាំ២០១៤។ ការកើនឡើងនៅតែបន្តដោយសម្អាងលើស្ថិតិ ៥ឆ្នាំចុងក្រោយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលដាក់ឲ្យអនុវត្តដោយរាជរដ្ឋាភិបាលអាណត្តិទី៥នៃរដ្ឋសភា( ២០១៣ ដល់ ២០១៨ )មានអាត្រាកំណើនគួរឲ្យកត់សម្គាល់ គឺបានកើនពី ៣៧,៩៤៨,៨៧៨ក្បាលនៅឆ្នាំ ២០១៤ ដល់ ៤៤,៣៧៥,៣៩៥ក្បាលនៅឆ្នាំ២០១៨។ ទិន្នន័យទាំងពីរនេះគឺយើងទទួលបានពីប្រភពផ្សេងគ្នា បើទោះបីជាមានតួលេខខុសគ្នាបន្តិចបន្តួច ប៉ុន្តែក៏ឃើញថាស្ថិតក្នុងលទ្ធផលតែមួយ គឺការកើនឡើង។

[22] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, (០៤ តុលា ២០១៩)

ក្រាភិកទី១៖ ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម ) ឆ្នាំ២០១៤ ដល់ ២០១៨




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រាភិកទី២៖ ផលិតកម្មសត្វសរុបឆ្នាំ ២០១០ ដល់ ២០១៤




បើយើងគិតលើបែបផែននៃការចិញ្ចឹម កំណើននៃការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មមានប្រមាណ ៥៨% បើប្រៀបធៀបពីឆ្នាំ២០១៤ និងឆ្នាំ២០១៨ ខណៈដែលការចិញ្ចឹមជាលក្ខណៈគ្រួសារមានកំណើនប្រមាណ

ត្រឹមតែ ៨,៦%ប៉ុណ្ណោះ។ បើទោះជាយ៉ាងណាក៏ដោយ ការកើនឡើងបែបនេះជាសញ្ញាណនៃការចាប់ផ្ដើមរបស់គ្រួសារកសិករក្នុងការចិញ្ចឹមសត្វដែលជាផ្នែកចូលរួមដើម្បីលើកស្ទួយវិស័យចិញ្ចឹមសត្វនេះផងដែរ។

តារាងទី៣៖ ស្ថិតិសត្វតាមបែបផែនផលិតកម្មពីឆ្នាំ ២០១៤ ដល់២០១៨

| បែបផែន ផលិតកម្មសត្វ | ស្ថិតិសត្វ៥ឆ្នាំចុងក្រោយ (២០១៤-២០១៨) | | | | | ប្រៀបធៀបឆ្នាំ ២០១៤/២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | |
| លក្ខណៈគ្រួសារ | ៣១.៦១៣.៨៧៦ | ៣២.៤៨៧.៤៩៩ | ៣៤.២២៣.០០៧ | ៣៤.៤៧៧.៨៥៩ | ៣៤.៣៣៩.៨១០ | ៨,៦% |
| លក្ខណៈពាណិជ្ជកម្ម | ៦.៣៣៥.០០២ | ៨.២៦៥.៩០៥ | ៧.៩៦០.៣៨៧ | ៨.៣៥៦.៣០៩ | ១០.០៣៥.៥៨៥ | ៥៨% |
| សរុប | ៣៧.៩៤៨.៨៧៨ | ៤០.៧៥៣.៤០៤ | ៤២.១៨៣.៣៩៤ | ៤២.៨៣៤.១៦៨ | ៤៤.៣៧៥.៣៩៥ | ១៧% |

ការចិញ្ចឹមសត្វស្លាបសរុប ( ពិសេសមាន់ និងទា ) មានការកើនឡើងខ្លាំងរហូតដល់ជាង២០,៨% បើធៀបពីឆ្នាំ២០១៤ និងឆ្នាំ២០១៨។ ការចិញ្ចឹមជាលក្ខណៈគ្រួសារ និងកសិដ្ឋានក្នុងកំឡុង៥ឆ្នាំ ( ឆ្នាំ២០១០ ដល់២០១៨ ) បានកើនជាង ៣,១៥៨លានក្បាលនៅឆ្នាំ២០១៤ និងជិត ៣,៤៣៤លានក្បាលនាឆ្នាំ២០១៨។ នេះសរបញ្ជាក់ឲ្យឃើញថាមានកំណើនការវិនិយោគក្នុងការចិញ្ចឹមសត្វស្លាប ពិសេសមាន់ ទា ក្នុងគោលដៅពាណិជ្ជកម្មរបស់កសិករ។

# ជំពូកទី២

# ស្ថានភាពទូទៅនៃការចិញ្ចឹមទារបស់ លោក ហ៊ឺ បូរ៉ា

## ២.១. ទីតាំងភូមិសាស្ត្រកសិដ្ឋាន

បើយើងចេញដំណើរពីទីក្រុងភ្នំពេញ ទៅកសិដ្ឋានយើងត្រូវចំណាយពេលប្រហែលជា មួយម៉ោង និងសាមសិបនាទី ដែលស្មើនឹង ៦០ គីឡូម៉ែត្រ។ ដោយត្រូវឆ្លងកាត់តាមផ្លូវជាតិ ៦A បន្ទាប់មកឆ្លងកាត់ស្ពានព្រែកតាម៉ាក់ តាមស្រុកខ្សាច់កណ្តាល ទើបមកដល់ស្រុកស្រីសន្ធរ ដែលជាទីតាំងកសិដ្ឋាន។ កសិដ្ឋានត្រូវបានសាងសង់ឡើងនៅលើដីវាលប្រមាណជា ៣ហិចតា ដោយកសិដ្ឋានមានចំងាយឆ្ងាយពីផ្ទះអ្នកភូមិដើម្បីកុំឲ្យមានការរំខានដល់ប្រជាជនក្នុងភូមិ។ ទ្រុងទា គឺជាកន្លែងមួយដែលមានក្លិនមិនល្អ ( ស្អុយ ) ហេតុដូច្នេះហើយទើបលោកពូ បូរ៉ា បានសម្រេចសាងសង់ទ្រុងសម្រាប់ដាក់ទារបស់គាត់ នៅដាច់ឆ្ងាយពីតំបន់ដែលមានផ្ទះប្រជាជនរស់នៅ ប្រមាណជា ៣គ.ម បែបនេះដើម្បីកុំអោយប៉ះពាល់ដល់ការរស់នៅប្រជាជនក្នុងភូមិ។ ចំណែកឯភូមិសាស្ត្រនៃកសិដ្ឋានវិញ គឺស្ថិតនៅ៖

- ខាងជើងជាប់ ភូមិ ព្រែកពោធិ៍ ឃុំ ព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពុងចាម
- ខាងត្បូងជាប់ ឃុំ ទងត្រឡាច ស្រុក ស្រីសន្ធរ ខេត្ត កំពងចាម
- ខាងកើតជាប់ ភូមិ ជើងដឹក ឃុំ ប្រាំយ៉ាម ស្រុកស្រីសន្ធរ ខេត្តកំពងចាម
- និងខាងលិចជាប់ ភូមិ ព្រែកតាឡេះ ឃុំ ព្រែកតាឡេះ ស្រុក ស្រីសន្ធរ ខេត្តកំពងចាម។

## ២.២. អំពីម្ចាស់កសិដ្ឋាន

លោក ហ៊ឺ បូរ៉ា គឺជាគ្រូបង្រៀនមួយរូបរស់នៅក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ សព្វថ្ងៃគាត់មានអាយុ ៤១ ឆ្នាំ និងប្រពន្ធរបស់គាត់ឈ្មោះ រ៉ា ស្រីម៉ៅ រស់នៅភូមិព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពងចាម ។ គាត់មានកូន ៣ នាក់ដែលកំពុងសិក្សាថ្នាក់ បឋមសិក្សា និង អនុវិទ្យាល័យ។ លោកពូជាមេគ្រួសារម្នាក់ដែលទទួលបន្ទុកក្នុងការរកចំណូលចូលផ្ទះដើម្បីផ្គត់ផ្គង់គ្រួសារ។ គាត់មានជីវភាពសមរម្យល្មមដែលអាចចិញ្ចឹមគ្រួសារបាន ដោយលោកពូអាចផ្តល់ឲ្យកូនៗរបស់លោកពូនូវការសិក្សាដូចជាប្រជាជនដទៃទៀតដែរ។ ប្រភពចំណូលរបស់គាត់ គឺបានមកពីអាជីពជាគ្រូបង្រៀននៅសាលាបឋមសិក្សានាឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និងការបើកកសិដ្ឋានចិញ្ចឹមទាដែលអាចឲ្យគាត់ទទួលបានចំណូលប្រចាំថ្ងៃ។ លោកពូបានចាប់ផ្តើមចិញ្ចឹមទាដំបូងនៅក្នុងឆ្នាំ២០១២ ស្ថិតនៅភូមិទ្រាសរ ឃុំខ្នារសរ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

## ២.៣. គោលបំណងនៃការចិញ្ចឹមទា

ការចិញ្ចឹមទាយកពងលក់ គឺជាគោលបំណងធំដែលលោកពូ ហ៊ី ប៉ូរ៉ា រំពឹងនឹងទទួលបានពី កសិដ្ឋានរបស់គាត់ដើម្បីរកចំណូលបន្ថែមសម្រាប់គ្រួសារ។ មិនតែប៉ុណ្ណោះគាត់មានគោលបំណង ចង់បង្កើតមុខរបរថ្មីមួយដល់បងប្អូនរស់នៅក្នុងតំបន់នោះ ដែលមិនធ្លាប់មាននរណាម្នាក់ បានសាកល្បងចិញ្ចឹមពីមុនមកនោះទេ។ គាត់បានចិញ្ចឹមសាកល្បងនៅក្នុងឆ្នាំ ២០១២ ជាមួយបរិមាណតិចតួចបំផុត ដោយសារគាត់មិនទាន់មានបទពិសោធន៍ និងមិនទាន់បានសិក្សាអំពីការចិញ្ចឹមទាយកពងនេះច្បាស់នៅឡើយ។ ម្យ៉ាងវិញទៀត ដូចដែលបានរៀបរាប់ខាងលើ លោកពូមានកូនចំនួន៣នាក់ ដែលកំពុងសិក្សាផងទៀតនោះ ដូច្នេះលោកពូសង្ឃឹមថាការចិញ្ចឹមទានេះអាចជួយគាត់ដើម្បីរកចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់ការសិក្សារបស់កូនរបស់គាត់ នៅពេលដែលពួកគេមានតម្រូវការកាន់តែច្រើន។ លើសពីនេះ គាត់យល់ថាការងារចិញ្ចឹមទានេះអាចធ្វើជាលក្ខណៈគ្រួសារបាន អាចឲ្យមានការចូលរួមពីប្រពន្ធ និងកូនៗរបស់គាត់ ដោយមិនពឹងផ្អែកទាំងស្រុងទៅលើការជួលកម្មករ ព្រោះវាមិនមែនជាការងារធ្ងន់ដែលត្រូវការប្រើប្រាស់កម្លាំងខ្លាំង ថ្វីត្បិតតែការងារមមាញឹកបន្តិចក៏ពិតមែន។

## ២.៤. ប្រវត្តិនៃការចាប់ផ្តើមចិញ្ចឹមទា

នៅក្នុងឆ្នាំ២០១២ លោក ហ៊ី ប៉ូរ៉ា បានចូលរួមសិក្ខាសិលាមួយ ដែលបានរៀបចំឡើងដោយអង្គការសេដាក់ ឬ CEDAC ស្តីពីការចិញ្ចឹមទា និងអភិវឌ្ឍន៍សហគមន៍ ចំនួន ២ សប្តាហ៍ ។ បន្ទាប់ពីបានរៀនចប់វគ្គបណ្តុះបណ្តាលនោះរួចមកធ្វើឲ្យគាត់មានគំនិតចង់ចិញ្ចឹមទា ជាការសាកល្បងក្នុងការរកមុខរបរបន្ថែម ព្រោះគាត់មានដីខ្លួនឯងស្រាប់, មានថវិការគ្រប់គ្រាន់, ការចំណាយតិច និងប្រើរយៈពេលខ្លីក្នុងការទទួលផល និងទទួលបានប្រាក់ចំណេញច្រើនដោយការយកពង និងសាច់សម្រាប់លក់។ ឆ្លងកាត់ការពិចារណា និងពិគ្រោះយោបល់ផ្សេងៗ លោក ហ៊ី ប៉ូរ៉ា ក៏បានសម្រេចចិត្តដាក់ទុន (ការបើកសិដ្ឋានចិញ្ចឹមទា) ជាមួយនឹងទំនុកចិត្ត និងដើមទុនមួយចំនួន។ គាត់បានចាប់ផ្តើមការចិញ្ចឹមទាដំបូងជាមួយនឹងទាចំនួន ៣៧០ ក្បាល និងចំណាយដើមទុនប្រមាណជា ២០,០០០,០០០ រៀល ហើយរហូតដល់បច្ចុប្បន្នគាត់មានទាប្រហែលជាជាង ១០,០០០ ក្បាល ជាមួយការចំណាយសរុប ប្រមាណជិត ៣៤៧,៤០០,០០០ រៀល ដែលស្មើនឹង ៨៦,៨៥០ ដុល្លារ។

## ២.៥. សក្តានុពល

លោកពូ បូរ៉ា មានឱកាសច្រើនដើម្បីទទួលបានជោគជ័យជាមួយនឹងមុខរបរចិញ្ចឹមទានេះ ដោយសារតែគាត់មានធនធានមួយចំនួនដែលមានសក្តានុពល និងអំណោយផលដល់មុខរបរមួយនេះ។ ធនធានទាំងនោះមានដូចជា៖

- ដីស្រែផ្ទាល់ខ្លួនដែលឆ្ងាយពីអ្នកស្រុក មិនមានការបង្កការរំខានដល់ប្រជាជនក្នុងភូមិ និងបង្កើតបរិយាកាសមួយដែលល្អសម្រាប់ទា
- ជាតំបន់ដែលមានអាកាសធាតុដែលទាអាចរស់នៅបាន និងលូតលាស់
- ទីតាំងដីស្ថិតនៅស្រែវាល អាចប្រលែងទាឲ្យស៊ីចំណីខ្លះៗនៅតាមវាល
- មានថវិការគ្រប់គ្រាន់ក្នុងការចំណាយលើដំណើរការនៃការចិញ្ចឹម
- មានកម្លាំងគ្រប់គ្រាន់ក្នុងការមើលថែរក្សាទា។

## ២.៦. ដំណើរការនៃការរៀបចំកសិដ្ឋាន

### ២.៦.១. បរិស្ថានជុំវិញ

កសិដ្ឋានត្រូវមានអនាម័យជានិច្ច ទាំងទ្រុងដេក និងទ្រុងលេង។ ការធ្វើបែបនេះ គឺដើម្បីអោយមានបរិយាកាសគ្រប់គ្រាន់សម្រាប់ទា និងធានាបានថាទាមិនមានការយាយីពីមេរោគផ្សេងៗ។ ការធ្វើកសិដ្ឋាននៅទីវាលមានបរិយាកាសពេញលេញជាសក្តានុពលមួយសម្រាប់ទាក្នុងការរត់លេងក្នុងវាលស្រែ និងអាចចាប់សត្វល្អិតស៊ីទៀតផង។ ទាំងនេះជាមូលហេតុដែលលោក បូរ៉ា ធ្វើកសិដ្ឋានរបស់លោកនៅចម្ងាយប្រមាណ ៣ គីឡូម៉ែត្រពីភូមិ (ឆ្ងាយពីផ្ទះអ្នកស្រុក) ដើម្បីបង្កើតបរិយាកាសថ្មីសម្រាប់ទា។

### ២.៦.២ ការជ្រើសរើសពូជទា

ការជ្រើសរើសពូជត្រូវបានធ្វើឡើងយ៉ាងល្អិតល្អន់។ លោកពូ បូរ៉ា យល់ថាការជ្រើសរើសពូជជារឿងសំខាន់ដែលត្រូវគិតគូរ។ ក្នុងការចិញ្ចឹមត្រូវប្រាកដថាពូជទាដែលយកមកចិញ្ចឹមសមស្របទៅនឹងគោលបំណងនៃការចិញ្ចឹម ឧទាហរណ៍ថាបើមានគោលបំណងចិញ្ចឹមយកពងត្រូវជ្រើសពូជប្រភេទណា និងចិញ្ចឹមយកសាច់ត្រូវជ្រើសពូជប្រភេទណា។ ប្រជាកសិករនៅតាមជនបទ ពួកគាត់គិតគូរយ៉ាងខ្លាំងមុននឹងសម្រេចចិត្តវិនិយោគលើមុខរបរអ្វីមួយ ព្រោះថាពួកគាត់មិនមានដើមទុនច្រើនសម្រាប់ខាតបង់ទេ។

- ចំពោះពូជក្នុងស្រុក៖ ងាយចិញ្ចឹមជាលក្ខណៈគ្រួសារ ធន់នឹងជម្ងឺ ងាយស្រួលបន្សាំនឹងអាកាសធាតុ តែមានការលូតលាស់យឺត ។

- ចំពោះពូជនាំចូល៖ ត្រូវការការថែទាំខ្ពស់ មានភាពសាំនឹងជម្ងឺនឹងអាកាសធាតុតិចតួចតែមានមាឌធំ ការលូតលាស់លឿន និងទទួលបានផលចំណេញខ្ពស់បើគោរពតាមបច្ចេកទេសត្រឹមត្រូវ ។

ពូជទាដែលលោកពូ ប៉ូរ៉ា ចិញ្ចឹមនោះ គឺពូជទាកាគី ព្រោះវាផ្តល់ពងបានច្រើន សម្រាប់ការចិញ្ចឹមយកពងដូចគាត់។ មួយវិញទៀតគាត់ចង់បានទាដែលមានលក្ខណៈដូចខាងក្រោម៖

- ពូជផលិតស៊ុតច្រើន ទំហំស៊ុតធំ សំបកក្រាស
- ស្គាល់ប្រវត្តិ៖ ប្រភពទាមកពីកន្លែងដែលមិនធ្លាប់មានការឆ្លងរាលដាលនៃជម្ងឺ ជាពិសេសជម្ងឺផ្តាយ ជម្ងឺអាសន្នរោគ
- ត្រូវមានភ្នែកភ្លឺថ្លា ដំណើររៀសរវៃ
- មានទម្ងន់ធ្ងន់
- មានសុខភាពល្អ សាំនឹងអាកាសធាតុចំពោះតំបន់ដែលត្រូវយកទៅចិញ្ចឹម។

### ២.៦.៣. ដំណើរការរៀបចំទ្រុង

ដើម្បីអោយធានាបានក្នុងការការពារទាកុំអោយមានជម្ងឺមកបៀតបៀន ការធ្វើរោងក៏ជាកត្តាមួយយ៉ាងចាំបាច់ផងដែរ ព្រោះថាបើរោងដែលយើងបានសាងសង់ មិនមានពន្លឺមកគ្រប់គ្រាន់ មិនមានអនាម័យធ្វើឲ្យមានមេរោគដែលអាចឲ្យទារបស់យើងងាប់បាន និងបណ្តាលអោយទាឈឺគ្រប់ពេលវេលា។ ក្នុងការរៀបចំទ្រុងគឺលោកពូ ប៉ូរ៉ា បានរៀបចំធ្វើតាមបទពិសោធន៍របស់គាត់ផ្ទាល់ផង រួមផ្សំពីការណែនាំពីបណ្តាលមិត្តភក្តិរបស់គាត់ផង ព្រោះថាក្នុងការចិញ្ចឹមទានៅក្នុងស្រុកយើងមិនទាន់មានស្តង់ដាណាមួយដែលល្អនៅឡើយទេ បើតាមសម្តីរបស់លោកពូផ្ទាល់។ លោកពូ ប៉ូរ៉ា ជ្រើសរើសដីរបស់គាត់មួយកន្លែង ដែលស្ថិតនៅឆ្ងាយពីភូមិប្រមាណ ៣ គីឡូម៉ែត្រ ដែលមានទំហំ ៣ហិតាដី ជាមួយស្រះទឹកប្រហែល ៧៥០ ម៉ែត្រការ៉េ ហើយគាត់បានសាងសងទ្រង់ទារបស់គាត់បែរឲ្យចំព្រះអាទិត្យ ដោយប្រើស៊ីម៉ងធ្វើជាបង្គោល, សង្ក័សីសម្រាប់ប្រក់ដំបូល និងក្រាលអង្កាមពីក្រោមរោងដើម្បីមិនអោយមានសំណើម រួមជាមួយសំណាញ់សម្រាប់ហ៊ុំព័ទ្ធជុំវិញរោងទានោះ។ ទ្រុងទាត្រូវបានធ្វើជា ៥ទ្រុង គឺសម្រាប់ដាក់កូនទាមួយ សម្រាប់ដាក់ទាពេញវ័យមួយ និងសម្រាប់ដាក់ទាដែលកំពុងពេញពង (ពងបានច្រើន) ពីរ និងសម្រាបដាក់ទាចាស់រៀបអស់ពង ឬយូឆ្នាំ (ជិតលក់ចេញ) មួយ។ ទ្រង់ទា ត្រូវមានភាពធំទូលាយ និងមានភាពស្ងួតដើម្បីអោយកុំអោយទារត់ជាន់គ្នា អាចស្រូបយកខ្យល់អាកាសបាន ហើយធ្វើបែបនេះងាយស្រួលក្នុងការអោយវាពង។ដូចដែលបានរៀបរាប់

ខ្លះរួចមកហើយ ទ្រុងត្រូវមានកម្ពស់យ៉ាងហោចណាស់២ ម៉ែត្រ ទៅ២,៥ ម៉ែត្រ។ ក្នុងការសាងសងរោងទានោះ គាត់បានចំណាយទឹកប្រាក់ប្រមាណជិត ៤០,០០០ ដុល្លារ ស្មើនឹង ១៦០,០០០,០០០ រៀល ។

### ២.៦.៤ ប្រព័ន្ធទឹក

ប្រព័ន្ធទឹក ជាកត្តាមួយយ៉ាងសំខាន់ ដែលមិនអាចខ្វះបាន ក្នុងការផ្តល់ជាប្រភពទឹកសម្រាប់ទា។ យើងបានសង្កេតឃើញថា ផ្ទៃខាងក្នុងនៃរោងទាំង ៥ របស់គាត់ ដែលរោងនីមួយៗ យើងឃើញមានប្រព័ន្ធទឹក ងាយស្រួលក្នុងការអោយទា ផឹក គឺគាត់បានយកបំពង់ទុយោជ័រ តប្រទាក់ក្រឡាគ្នាជាខ្សែង ដែលតចេញពីអាងស្តុកទឹកធំរបស់វា។ មិនត្រឹមតែងាយស្រួលបើកឲ្យទាផឹកនោះទេ ការធ្វើបែបនេះក៏ធ្វើអោយគាត់ងាយស្រួលក្នុងការលាងសម្អាត ឬប្តូរទឹកចេញផងដែរ។

រូបភាពទី៧៖ ប្រព័ន្ធទឹកសម្រាប់ទាផឹក



### ២.៦.៥. ស្រះទឹកសម្រាប់ទាលេង

ក្រៅពីប្រព័ន្ធទឹក សម្រាប់ទាផឹកនោះហើយ ដោយសត្វទា គឺជាសត្វដែលចូលចិត្តលេងទឹក គាត់បានជីកស្រះមួយយ៉ាងធំ ដែលមានទទឹងប្រហែល ១០ម៉ែត្រ និងបណ្តោយប្រមាណជាង ៣០ ម៉ែត្រសម្រាប់ទាចុះលេង និងមួយវិញទៀតសម្រាប់យកពេលសម្អាតទ្រុង ប៉ុន្តែការលេងរបស់ទាត្រូវមានកម្រិតមិនអោយលើសពី ៥ ម៉ោងនោះទេ។

## ២.៧. សកម្មភាពក្នុងការចិញ្ចឹមទា

លោកពូ ប៉ូវ៉ា បានបញ្ជាក់ថារបរចិញ្ចឹមទាជាមុខរបរមួយដែលមានភាពមមារញឹកច្រើន ដែលទាមទារឲ្យកសិករមានភាពអំណត់ អត់ធ្មត់ និងឧស្សាហ៍ព្យាយាម អត់ធន់នឹងក្លិនអាក្រក់ ហើយមិនអាចទុកចោលបាននោះទេ។ ប៉ុន្តែការចិញ្ចឹមទាបានធ្វើឲ្យជីវភាពគ្រួសាររបស់គាត់ មានការរីកចម្រើនជាលំដាប់ ដោយកម្រៃដែលគាត់ទទួលបានពីការចិញ្ចឹមទា អាចផ្តល់អោយសេដ្ឋកិច្ចគ្រួសាររបស់គាត់មានលំនឹង និងផ្គត់ផ្គង់តម្រូវការគ្រួសាររបស់គាត់ទាំងមូលបានគ្រប់គ្រាន់។ ចំពោះការចិញ្ចឹមទាយកពង តម្រូវឲ្យគាត់ធ្វើនូវសកម្មភាពចាំបាច់និងជាប្រចាំមួយចំនួនៈ

### ២.៧.១. សកម្មភាពថែទាំ

យើងឃើញថាទាជាសត្វមួយប្រភេទងាយស្រួលក្នុងការចិញ្ចឹម និងទទួលបានប្រាក់កម្រៃជាប្រចាំថ្ងៃតាមរយៈការលក់ពងរបស់វាដូចដែលបានរៀបរាប់ខាងលើ ប៉ុន្តែនៅពេលយើងមិនបានដឹងពីវិធីសាស្ត្រនៃការគ្រប់គ្រង និងការពារពីមហន្តរាយផ្សេងៗ វានឹងធ្វើអោយខាតបង់បន្តិចម្តងៗដោយមិនដឹងខ្លួន ។ ខាងក្រោមនេះជាវិធីសាស្ត្រងាយៗមួយចំនួននៅក្នុងការគ្រប់គ្រងទា ៖

- ការតាមដានជាប្រចាំនូវលាមកទា ដើម្បីអោយប្រាកដថាទារបស់យើងមានសុខភាពល្អ។ បើទាមានលាមកធម្មតា នោះបង្ហាញថាទាមានសុខភាពល្អ តែបើលាមកទារាវនោះមានន័យថាទារបស់យើងនឹងមានការក្តៅក្នុង ដូច្នេះត្រូវប្រើថ្នាំជាជំនួយព្យាបាលវាជាបន្ទាន់ ហើយបើទាដុះអត់ចេញ រហូតលានអន្សាគូត (ចេញកន្ទោមពងមកក្រៅ) នោះបង្ហាញថាទារបស់អ្នកមានបញ្ហាជាមួយចំណីហើយ ដូច្នេះត្រូវពិនិត្យមើល ឬដូរចំណីថ្មីសម្រាប់ទារបស់អ្នក ។
- ការពារមិនអោយត្រូវភ្លៀងធំ ទាដែលយើងចិញ្ចឹមជាធម្មតាតែងតែមុជទឹកក្នុងស្រះ ឬលេងទឹកនៅតាមប្រឡាយផ្សេងៗជាការធម្មតា ប៉ុន្តែមិនអោយត្រូវភ្លៀងនោះទេ ព្រោះនៅពេលទាលេង ឬត្រូវទឹកភ្លៀង នោះនឹងធ្លាប់ ឬជ្រាបចូលទៅដល់រោមខាងក្នុងរបស់ទាដែលបណ្តាលអោយវាជ្រុះរោម ។ នៅពេលទាជ្រុះរោម វានឹងមិនមានពងរហូតវាដុះរោមជិតវិញ ។
- កុំអោយមនុស្សប្លែកមុខចូលច្រើនអោយសោះ ជាទូទៅគេតែងតែនាំគ្នានិយាយតៗ គ្នាថានៅពេលមានមនុស្សប្លែកមុខចូលទៅច្រើននិងធ្វើអោយទាអៀន ធ្វើអោយវាអត់ពង។ តែបើការសិក្សារបស់អ្នកជំនាញបានអោយដឹងថា ការដែលមានមនុស្សប្លែកចូលទៅក្នុងទ្រង់ទា ធ្វើអោយបាក់តេរីនៅជាប់នឹងខ្លួនគេ ឆ្លងទៅទានៅទីនោះធ្វើអោយកើតជម្ងឺផ្សេងៗ ។
- អនាម័យៈ

- សម្អាតទ្រុងជាប្រចាំ យកលាមក និងសម្អាតកាកសំណល់ចំណីអាហារឲ្យបានស្អាតហើយ យកទៅដុតចោល ឬកប់ចោល
- សម្អាតមជ្ឈដ្ឋានជុំវិញ ដូចជា ស្មៅ ព្រៃ ភក់ជ្រាំជាដើម
- ត្រូវសម្អាតធុងដាក់ទឹកអោយទាផឹក ត្រូវប្រាកដថាទឹកដែលទាផឹកមិនស្អុយ
- ត្រូវសម្អាតធុងដាក់ចំណីទា ជាប្រចាំផងដែរ។

➢ ការថែទាំមេពង

- ត្រូវរៀបចំកន្លែងឲ្យទាពងនៅតាមគំលាតរបង ឬជញ្ជាំងនៃរោងសម្រាប់ដេកពេលយប់
- កន្លែងទាពងត្រូវមានអនាម័យជាប្រចាំ (ការក្រាលចំបើង ក៏ជាមធ្យាបាយមួយល្អ សម្រាប់ អោយមានភាពស្ងួត )
- កន្លែងដែលទាពងត្រូវមានភាពស្ងប់ស្ងាត់
- ត្រូវប្រមូលពងទានៅរៀងរាល់ព្រឹក។

### ២.៧.២. សកម្មភាពសម្អាតទ្រុង

ក្នុងការសម្អាតទ្រុងទា ឬរោងទា ជាទូទៅគាត់មិនអាចកំណត់ថ្ងៃដែលត្រូវសម្អាតបានទេ គឺអាស្រ័យលើការប្រែប្រួលអាកាសធាតុ បើសិនគ្មានភ្លៀងជាទូទៅ ១ អាទិត្យ ទៅ ២ អាទិត្យ គាត់សម្អាតម្តង តែបើសិនមានភ្លៀងគឺត្រូវធ្វើក្នុងមួយថ្ងៃម្តង ។ មុខពេលគាត់ចូលទៅសម្អាតទ្រុង គឺគាត់បើកអោយទារបស់គាត់ចូលទៅលេងនៅក្នុងស្រះដើម្បីកុំអោយទារបស់គាត់និងផ្អើល។ សម្រាប់ស្នាចដាក់ទឹកវិញ គឺគាត់សម្អាតរៀងរាល់ថ្ងៃជាប្រចាំ។

### ២.៧.៣. ចំណីទា

#### ក. ប្រដាប់ចំណី

ប្រដាប់ចំណី ធ្វើឡើងពី កានដាក់សាំង ឬប្រេង (កាន៣០លីត្រ) ដោយយកកាននោះមកកាត់ផ្ទៃម្ខាងនៃកាន ប៉ុន្តែគាត់មិនបានកាត់ទាំងនោះទេ គាត់ទុកចន្លោះកណ្តាល គឺកាត់តែកែមសងខាងតែប៉ុណ្ណោះ។ ការធ្វើបែបនេះ ដើម្បីកុំឲ្យទា ចូលក្នុងកានបាន គឺគ្រាន់តែស៊ីចំណីបានតែមួយមុខគត់ ។ កាលណាឲ្យទាចូលក្នុងកានបាន វានិងជុសអាចម៍ ដាក់ក្នុងកាននោះ អាចធ្វើឲ្យឈឺបាន ។ ក្នុងមួយទ្រុង ជាទូទៅគេដាក់កានសម្រាប់ដាក់ចំណីឲ្យទាស៊ី ចន្លោះទី ៤ ទៅ ៥ កាន ដោយដាក់នៅកន្លែងផ្សេងៗគ្នានៅក្នុងទ្រុង

ហើយគេដាក់ចំណីនៅក្នុងនោះ ឲ្យទា ២៤ ម៉ោងក្នុងមួយថ្ងៃ មានន័យថាដាក់ឲ្យទាស៊ីរហូត ប៉ុន្តែគាត់មិនដែលដាក់ឲ្យពេញកានទេ គឺគាត់ដាក់ត្រឹមតែពាក់កណ្តាលនៃកាននោះប៉ុណ្ណោះ ព្រោះការធ្វើបែបនេះ ដើម្បីការពារកុំឲ្យទាចឹកស៊ីចេញមកក្រៅកាន (ខាតចំណី) ។ គាត់បានបន្តទៀតថា ការដាក់ចំណីអោយទាស៊ី ស្តាប់ទៅវាដូចជាមានភាពងាយស្រួលណាស់ ប៉ុន្តែបើយើង មិនបានមើលការខុសត្រូវវាឲ្យបានត្រឹមត្រូវ វាអាចបណ្តាលអោយទារបស់យើងឈឺ និងខាត់បង់ថវិការបាន។

**ខ. ការឲ្យចំណីទា**

**❖ ទាពង**

ជាទូទៅ ក្នុងទាចំនួន ១០,០០០ក្បាល ត្រូវការឲ្យចំណីប្រចាំថ្ងៃអស់ប្រមាណជា ៤០ ប៉េ ស្មើរនឹង ១,២០០ គីឡូក្រាម។ ដោយលោក បូរ៉ា ចង់ឲ្យទារបស់គាត់អាចស៊ីបានរាល់ពេលដែលវាឃ្លាន គឺគាត់ធ្វើការចាក់ចំណីនៅក្នុងប្រដាប់សម្រាប់ដាក់ចំណីទុកអោយទាស៊ី ពេញមួយថ្ងៃ ។ គាត់បានបន្តទៀតថាការធ្វើបែបនេះ ធ្វើអោយទាបានស៊ីឆ្អែតគ្រប់គ្នា ដែលមិនបណ្តាលអោយទា ខ្សោយកម្លាំង ដូច្នេះវាអាចពងបានច្រើន នឹងមានទន្និផលគួរជាទីពេញចិត្ត។

**❖ ទាចន្លោះពី ១ខែ ទៅ ៥ ខែ**

នៅក្នុងវ័យនេះ គឺយើងអាចអោយចំណីវាដូច ទាពងដទៃដែរ តែគ្មានការធ្វើបែបនេះទេ ព្រោះវាត្រូវចំណាយថវិការច្រើន ហើយយើងមិនបានទទួលចំណូលមកវិញឡើយ ព្រោះទានៅតូច និងមិនទាន់មានពងនៅឡើយទេ ។ ដូច្នេះយើងត្រូវរកអ្វីមួយជំនួស ដើម្បីជួយកាត់បន្ថយចំណាយ ក្នុងករណីនេះ គឺលោកអោយវាស៊ីចំណីសុទ្ធ ហើយពេលព្រឹក និងរសៀលលោកពូបានដេញទា អោយស៊ីស្រូវ ឬសត្វល្អិតនៅតាមវាលស្រែជាដើម ។

# ជំពូកទី៣
# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១. បញ្ហាប្រឈម

នៅក្នុងដំណើរការនៃការចិញ្ចឹមទារបស់លោកពូ បូរ៉ា គាត់បានលើកឡើងនូវបញ្ហាប្រឈមដែលគាត់តែងតែជួបប្រទះកន្លងមករួមមាន៖

### ៣.១.១. បញ្ហាជម្ងឺ

លោកពូ បានលើកឡើងបន្ថែមទៀតជារឿយៗ ការចិញ្ចឹមទាគោករបស់គាត់ តែងប៉ះជម្ងឺដូចជា ជម្ងឺប៉េស្តទា, ជម្ងឺអាសន្នរោគ និងជម្ងឺរលាកកន្ទោមពង។ ជម្ងឺប៉េស្តទា និងជម្ងឺអាសន្នរោគមិនសូវជាកើតមានញឹកញ៉ាប់នោះទេ ព្រោះគាត់បានចាក់វ៉ាក់សាំងវារួចរាល់ហើយ។ ជម្ងឺដែលឧស្សាហ៍កើតជាងគេ គឺជម្ងឺរលាកកន្ទោមពង ដែលធ្វើអោយទាពងមិនកើតទៀតទេ ហើយបណ្តាលអោយស្លាប់ក៏មាន។

### ៣.១.២. បញ្ហាអគ្គិសនី

ដោយសារកសិដ្ឋានរបស់លោកពូ ធ្វើនៅឆ្ងាយពីតំបន់ដែលមានមនុស្សកុះករ (ឆ្ងាយពីភូមិ) ធ្វើអោយគាត់មិនអាចប្រើប្រាស់ភ្លើងអគ្គិសនីរបស់រដ្ឋបាន ដូច្នេះគាត់ត្រូវប្រើភ្លើងអគ្គិសនីដែលប្រើដោយម៉ាស៊ីន សម្រាប់ទាញម៉ូទ័រផលិតអគ្គិសនី ដែលបណ្តាលអោយគាត់ត្រូវចំណាយថវិការច្រើន បើធៀបនឹងការប្រើប្រាស់អគ្គិសនីរបស់រដ្ឋ ។

### ៣.១.៣. បញ្ហាអាកាសធាតុ

តាមរយៈសម្តីរបស់លោកពូ បូរ៉ា បានបញ្ជាក់ថា សព្វថ្ងៃនេះអាកាសធាតុនៅប្រទេសកម្ពុជាយើងមានការប្រែប្រួលឥតឈប់ឈរ ពីមួយថ្ងៃទៅមួយថ្ងៃ ជួនកាលក្តៅ ជួនកាលត្រជាក់ ជួនកាលភ្លៀង.... អាកាសធាតុផ្លាស់ប្តូរបែបនេះបង្កអោយមានផលវិបាកខ្លាំងណាស់ដល់ការរស់នៅ មិនថាតែយើងជាមនុស្សនោះទេ ចំពោះការធ្វើស្រែចំការ និងជាពិសេសគឺ ការចិញ្ចឹមសត្វនេះតែម្តង ។ ម្យ៉ាងទៀត ដូចយើងដឹងច្បាស់ហើយថា សត្វទាគឺជាសត្វមួយប្រភេទដែលងាយនឹងទទួលរងនូវសំពាធពីបំលាស់ប្តូរបរិយាកាសនេះ ដែលជាហេតុបង្កអោយទាកើតមានជម្ងឺ និង អាចឈានដល់ងាប់។ ទោះជាមានការថែទាំយ៉ាងយកចិត្តទុកដាក់ខ្លាំងយ៉ាងណាក៏ដោយ ក៏បញ្ហាអាកាសធាតុនេះនូវតែជាបញ្ហាស្មុគស្មាញដដែលសម្រាប់អ្នកចិញ្ចឹមទា។ គឺនៅពេលក្តៅខ្លាំងធ្វើឲ្យទា សំកុក មិនស៊ីចំណី រហូតក្លាយជាជម្ងឺ និងនៅពេលភ្លៀងខ្លាំង ធ្វើឲ្យទា ទទឹកស្លាប រហូតដល់គ្រុនស្លាប់ ឬក៏ជ្រុះរោម បណ្តាលអោយគ្មានពង ។

**៣.១.៤. បញ្ហាទីផ្សារ**

ចំពោះបញ្ហាទីផ្សារ គឺជាបញ្ហាដ៏ធំមួយសម្រាប់គាត់ដែរ ព្រោះតម្លៃនៅលើទីផ្សារគ្មានស្ថេរភាព តម្លៃអាចឡើងចុះគ្រប់ពេលវេលា។ នៅពេលតម្លៃចុះខ្លាំងរហូតដល់ ៣២០៛ និងតម្លៃឡើងខ្លាំងគឺអស់ត្រឹម៤៨០៛ ។ ហើយខណៈពេលថ្លៃចុះត្រឹម ៣២០៛ គឺមិនអាចអោយគាត់ទទួលបានផលចំណេញនោះទេ ព្រោះទាជាមធ្យម ១ ក្បាលទា ចំណាយអស់ ៣០០៛ ទៅ ៣៥០៛ ទៅហើយ។

**៣.១.៥. ការបង្វិលលុយ**

ការខ្វះខាត នូវប្រភពដើមទុនសម្រាប់ធ្វើការវិនិយោគលើការចិញ្ចឹមទា ជាហេតុតម្រូវអោយគាត់ត្រូវធ្វើការរិះរកមធ្យោបាយដើម្បីបានទុនបន្ថែមទៀត សម្រាប់បង្គ្រប់តម្រូវការទុនរបស់គាត់។ ប្រសិនបើការបង្វិលទុនដែលគាត់មានទាំងអស់ ដោយផ្តោតទៅលើតែរបរចិញ្ចឹមទាតែមួយនោះ គឺអាចធ្វើអោយខ្វះខាតថវិការផ្គត់ផ្គង់ជីវភាពគ្រួសារ និងទុនសម្រាប់ធ្វើការវិនិយោគលើរបរផ្សេងៗទៀត ។

**៣.២. ដំណោះស្រាយ**

ដើម្បីដោះស្រាយនូវរាល់បណ្តាបញ្ហាមួយចំនួនខាងលើលោក ប៉ូវ៉ា បានរកនូវមធ្យោបាយដើម្បីដោះស្រាយ ខាងក្រោមនេះជាដំណោះស្រាយជាក់ស្តែងដែលលោកពូ បានព្យាយាមធ្វើការដោះស្រាយស្រាវជ្រាវទៅលើបញ្ហាទាំងអស់នោះ៖

**៣.២.១. បញ្ហាជម្ងឺ**

ជាក់ស្តែងដើម្បីធ្វើការដោះស្រាយនូវបញ្ហាជម្ងឺខាងលើដូចជា ជម្ងឺប៉េស្តទា និងជម្ងឺអាសន្នរោគ គឺត្រូវធ្វើការគ្រប់គ្រងដោយយកចិត្តទុកដាក់ខ្ពស់ និងត្រូវធ្វើការចាក់វ៉ាកសាំងការពារសត្វទា ទៅតាមអាយុកាល និងការកំណត់របស់វ៉ាក់សាំង ព្រមទាំងមានការចាក់រំលឹកជាលើកទីមួយ និងលើកទីពីរ ។

ទោះបីជាមានការចាក់វ៉ាកសាំងការពារក៏ដោយក្តីក្នុងករណីសង្ស័យថាទា មានជម្ងឺភ្លាម លោកពូ ប៉ូវ៉ា ធ្វើការទំនាក់ទំនងជាមួយបសុពេទ្យ (ពេទ្យសត្វ) ឬអ្នកជំនាញរបស់ក្រុមហ៊ុន ឬពេទ្យសត្វក្នុងស្រុក ជាជំហានទីមួយបំផុតដែលត្រូវធ្វើ នឹងអោយបានជាបន្ទាន់ ។ ពេលពិនិត្យដឹងថាទាណាមួយឈឺហើយនោះ លោកពូចាប់ផ្តើមធ្វើការបំបែបទានោះដាក់អោយនៅដាច់ដោយឡែក ឆ្ងាយពីទាដទៃទៀតដើម្បីធ្វើការព្យាបាលឲ្យបានភ្លាមៗ។ ការធ្វើបែបនេះដើម្បីកាត់បន្ថយនូវការឆ្លងរាតត្បាតជម្ងឺ ពីទាដែលឈឺទៅកាន់ទាដទៃទៀតដែលមិនទាន់បានឆ្លង នៅក្នុងកសិដ្ឋានទាំងមូលបាន ។

ចំពោះទារលោកកន្ទ្រាមគួជ ដែលមិនអាចព្យាបាលបាន និងមិនមានប៉ះពាល់ដល់សុខភាពមនុស្ស នោះ គាត់បានលក់ទានោះទៅកាន់កុងស៊ី (ឈ្មួញកណ្តាល) ក្នុងតម្លៃក្រោមទីផ្សារ។ ចំណែកទា ដែលឈឺដោយជម្ងឺដែលមិនអាចព្យាបាលបានរហូតដល់ស្លាប់ គាត់គ្មានវិធីអ្វីក្រៅពីកប់ចោលនោះទេ ។

**៣.២.២. បញ្ហាបំណុល**

ជាការពិតណាស់ក្នុងការរកស៊ី ការជំពាក់បំណុលរមែងកើតឡើងជាប្រចាំទៅហើយសម្រាប់អ្នករកស៊ី។ វិធីដោះស្រាយមិនអោយមានបំណុលតែម្តងប្រហែលជាគ្មាន តែអ្វីដែលអាចដោះស្រាយបាននោះ គឺស្វែងរកនូវប្រភពអ្នកដែលអាចអោយខ្ចីបាន នឹងមាននូវហានិភ័យទាប។ ជាទូទៅប្រជាកសិករខ្មែរមិនសូវមានជំនឿ ឬមានគំនិតគិតទៅខ្ចីបុលពីធនាគារឡើយ ព្រោះដោយហេតុថាគាត់គ្មាននូវវត្ថុបញ្ចាំ ឬពេលខ្លះគាត់គិតថាបែបបទនៃការខ្ចីប្រាក់ពីធនាគារមានភាពស្មុគស្មាញផងដែរ។ ទាំងនេះជាហេតុធ្វើអោយពួកគាត់និយមចងការប្រាក់ពីឈ្មួញនៅក្រោមអត្រាការប្រាក់ខ្ពស់។ នៅប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ ដោយមិនទាន់មានធនាគារកសិកម្មដូចប្រទេសដ៏ទៃ តែប្រទេសយើងសព្វថ្ងៃមានស្ថាប័នមីក្រូហិរញ្ញវត្ថុដែលអនុញ្ញាតអោយមាននូវការខ្ចីដូចប្រទេសដ៏ទៃផងដែរ ដែលមានលក្ខខណ្ឌក៏មិនសូវស្មុគស្មាញប៉ុន្មាននោះទេ ។ តែប្រជាកសិករខ្មែរនៅតែមិនទាន់មានការពេញនិយមនូវកម្ចីពីធនាគារ ឬមីក្រូហិរញ្ញវត្ថុនៅឡើយទេ។ ដូចនេះប្រសិនបើលោកពូហ៊ឺ បូរ៉ា ឬប្រជាកសិករទាំងអស់ងាកមកពិចារណានូវកម្ចីបែបនេះប្រហែលជាវាអាចផ្តល់នូវភាពងាយស្រួលក្នុងការសម្រួលនូវការបង្វិលប្រាក់ប្រើប្រាស់ក្នុងចង្វាក់ផលិតកម្មរបស់ខ្លួនបានកាន់តែប្រសើរឡើងជាក់ជាមិនខាន។

**៣.២.៣. បញ្ហាទីផ្សារ**

ដោយផ្អែកតាមស្ថានភាពសេដ្ឋកិច្ច និងតម្រូវការបរិមាណពងទានៅប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ននេះ សរអោយឃើញថាកម្ពុជាមិនទាន់មានលំនឹងទីផ្សារចំពោះថ្លៃពងទានោះទេ ដែលជាបញ្ហាសម្រាប់លោកពូ ដើម្បីដោះស្រាយបញ្ហានេះ លោកពូ មានតែព្យាយាមរកម៉ូយបោះដុំ នឹងរាយ នៅតាមតំបន់ ឬរាជធានីភ្នំពេញ ។ មួយវិញទៀតចំពោះបញ្ហាតម្លៃ មានតែមានការអន្តរាគមន៍ពីសំណាក់រាជរដ្ឋាភិបាល ដើម្បីធានាសុវត្ថិភាពតម្លៃពងទា សម្រាប់ប្រជាកសិករ។ ជាពិសេសបិទការនាំចូលពងទា ពីវៀតណាម មកកាន់ប្រទេសកម្ពុជា ។

#### ៣.២.៤. បញ្ហាអាកាសធាតុ

វិធីសាស្ត្រក្នុងការការពារ និងថែទាំសុខភាពរបស់ទាចំពោះបញ្ហាអាកាសធាតុ គឺលោកពូ ធ្វើយ៉ាងណា ត្រូវជួយសម្រួលឲ្យបរិយាកាសនៅក្នុងទ្រុងមានភាពសមរម្យទៅតាមតម្រូវការរបស់សត្វដែលអាចឲ្យទារស់នៅបាន ការងារទាំងនោះរួមមាន៖

- ការបើកអោយទៅលេងទឹកក្នុងស្រះក្នុងរយៈពេលមួយសមរម្យ គឺដើម្បីកាត់បន្ថយកម្តៅរបស់ទា
- ត្រូវបង្កើនការផ្តល់ទឹកឲ្យបានច្រើនជាងមុន ដើម្បីកាត់បន្ថយ បញ្ហាដង្ហក់
- ធ្វើទ្រុងអោយមានខ្យល់ចេញចូលគ្រប់គ្រាន់
- ការប្រើថ្នាំ អេឡិចត្រូលីត្រ (Electrolyte) ក្នុងទឹកសម្រាប់ការពារ និងព្យាបាលភាពអេឡិចត្រូលីត្រដែលបណ្តាលមកពីកង្វះទឹក ដែលមកពីក្តៅខ្លាំង ។
- ត្រូវធ្វើទ្រុងឲ្យត្រូវនឹងបរិមាណទា ដើម្បីប្រាកដថាមិនត្រូវភ្លៀងនៅភ្លៀងធ្លាក់ ។

#### ៣.២.៥. បញ្ហាអគ្គិសនី

ចំពោះបញ្ហានេះ វាពិតជាពិបាកណាស់សម្រាប់លោកពូ ក្នុងការដោះស្រាយ ព្រោះលោកពូ មិនដឹងមានមធ្យោបាយអ្វីដើម្បីអាចប្រើប្រាស់អគ្គិសនីរដ្ឋបាននោះទេ ដូច្នេះលោកពូ មានតែបង្ខំចិត្តប្រើប្រាស់អគ្គិសនីដែលប្រើដោយកម្លាំងម៉ាស៊ីនតទៅទៀត ។

### ៣.៣. ប្រវត្តិនៃចំណូល និងចំណាយចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៩

ដូចដែលបានរៀបនៅក្នុងប្រវត្តិនៃការចិញ្ចឹមទាគោក ខាងលើរួចមកហើយដែលគាត់បានចាប់ផ្តើមការចិញ្ចឹមទាដំបូងជាមួយនឹងទាចំនួន ៣៧០ ក្បាល និងចំណាយដើមទុនប្រមាណជា ២០,០០០,០០០ រៀល ហើយរហូតដល់បច្ចុប្បន្នគាត់មានទាប្រហែលជាជាង ១០,០០០ ក្បាល ជាមួយការចំណាយសរុប ប្រមាណជិត ៣៤៧,៤០០,០០០ រៀល ដែលស្មើនឹង ៨៦,៨៥០ ដុល្លារ។ ហើយនៅក្នុងចំណុចនេះ យើងខ្ញុំនឹងលើកយកប្រវត្តិនៃការចំណាយ និងចំនូលចាប់ពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ ២០១៩ ។ នៅក្នុងឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៤ គាត់បានបន្ថែមថា ការចំណាយ និងចំណូលមិនសូវមានភាពខុសគ្នានិងឆ្នាំ២០១២ ប៉ុន្មានទេ ព្រោះបរិមាណទាដែលគាត់បានចិញ្ចឹមគឺមានចំនួនស្មើគ្នា ដែលនៅក្នុងរយៈពេល ៣ឆ្នាំនោះ គឺជាការចិញ្ចឹមសាកល្បង និងការសិក្សាបន្ថែមឲ្យបានច្បាស់លាស់ មុននិងគាត់ដាក់ទុនចំណាយលើការចិញ្ចឹមទានេះ ។ ដោយបន្ទាប់ពី ៣ឆ្នាំរួចមកគាត់ បានកត់សំគាល់ថា ការចិញ្ចឹមទានេះ មិនសូវមានហានិភ័យ និងទទួលបានផលចំណេញជាទីគាប់ចិត្ត ទើបគាត់សម្រេចចិត្តចាប់យកវិស័យនេះតែម្តង ។

តារាងទី៤៖ ចំណូល និងចំណាយចន្លោះឆ្នាំ ២០១៥ - ២០១៩ (គិតជារៀល)

| ឆ្នាំ | ចំនួនទា | បុគ្គលិក | ចំណាយ (រ) | ចំណូល(រ) | ចំណេញ(រ) |
|---|---|---|---|---|---|
| ២០១៥ | ៣,៥០០ ក្បាល | ២ នាក់ | ២៩៣,៨២៥,000 | ៣០៦,៦០០,000 | ១២៧,៧៥០,000 |
| ២០១៦ | ៤,000 ក្បាល | ២ នាក់ | ៣៣៥,៨០០,000 | ៤៨១,៨០០,000 | ១៤៦,000,000 |
| ២០១៧ | ៨,000 ក្បាល | ៣ នាក់ | ៦៧១,៦០០,000 | ៩៦៣,៦០០,000 | ២៩២,000,000 |
| ២០១៨ | ១០,000 ក្បាល | ៤ នាក់ | ៨៣៩,៥០០,000 | ១,២០៤,៥០០,000 | ៣៦៥,000,000 |
| ២០១៩ | ១០,000 ក្បាល | ៤ នាក់ | ៨៣៩,៥០០,000 | ១,២០៤,៥០០,000 | ៣៦៥,000,000 |

## ៣.៤. ការចំណាយនៅលើការចិញ្ចឹម

របរចិញ្ចឹមទាយកពងនេះ គឺជារបរមួយដែលតម្រូវអោយប្រជាកសិករចំណាយនូវប្រាក់កាសជាមុន ។ សម្រាប់ចំនុចនេះលោកពូ បូរ៉ា ក៏បានប្រាប់ពីការចំណាយមានច្រើនដំណាក់កាល តាំងពីការចាប់ផ្តើមទិញកូនទាមកចិញ្ចឹមរហូតដល់ទាធ្លាក់ពង សម្រាប់លក់នៅលើទីផ្សារ ។ ការចំណាយទាំងអស់នោះរួមមាន៖

### ៣.៤.១. ការចំណាយលើការធ្វើរោង ឬទ្រុងទា

ការចំណាយលើការធ្វើរោង គឺចង់បង្ហាញអំពីដំណើរការនៃការធ្វើរោងទាំងប្រាំ ដែលក្នុងនោះសម្រាប់ដាក់កូនទាមួយ, សម្រាប់ដាក់ទារាបពងមួយ, សម្រាប់ដាក់ទាកំពុងពេញពងពីរ និងសម្រាប់ដាក់ទាជិតអស់ពងមួយ ដែលរួមមានការចាក់ដី ការជីកស្រះ ការសង់ដំបូល ការតភ្ជាប់ប្រព័ន្ធទឹកក្នុងទ្រុងនិងក្រៅទ្រុង ជាដើម ។ ប៉ុន្តែការចំណាយនេះ ជាការចំណាយតែម្តងប៉ុណ្ណោះ ហើយអាចប្រើប្រាស់បានរយៈពេលវែង ដែលរោងនីមួយៗមានប្រវែងទទឹង ១៥ម និង បណ្តោយ ៤០ម។ ចំណាយទាំងអស់នោះសរុបមានចំនួនជិត ១០,000 ដុល្លារ សម្រាប់រោងនីមួយៗ ត្រូវបានសាងសង់ឡើងពីស៊ីម៉ងត៍ ប្រក់ដោយស័ង្កសី និងហ៊ុំព័ទ្ធដោយសំណាញ់ ឈើ និងឫស្សី ។ តម្លៃនេះ(១០,000ដុល្លារ) បូករួមទាំងចំណាយលើការចាក់ដី, តទុយោទឹកនិង សម្ភារៈសម្រាប់ដាក់ចំណីអោយទា ។ ការចំណាយលើការជីកស្រះអស់ប្រមាណ ២000 ដុល្លារ មានប្រវែងទទឹង ១៥ម និងបណ្តោយ ៥០ម ។

តារាងទី៥៖ ការចំណាយលើការសាងសង់រោងចិញ្ចឹមទា និងការជីកស្រះ

| ឈ្មោះ | ចំនួន | ទំហំ | រោងមួយ | សរុប |
|---|---|---|---|---|
| រោង | ៥ | ទទឹង ១៥ ម និងបណ្តោយ ៤០ម | ៨ ពាន់ដុល្លា | ៤ ម៉ឺនដុល្លារ |
| ស្រះ | ១ | ទទឹង ១៥ ម និងបណ្តោយ ៥០ម | ២០០០ ដុល្លា | ២០០០ ដុល្លារ |
| សរុប | | | | ៤២,០០០ដុល្លារ |

### ៣.៤.២. ចំណាយសម្រាប់ការទិញទា

ការចំណាយសម្រាប់ការទិញទា ជាការចំណាយដុលបន្ទាប់ពី ការចំណាយក្នុងការធ្វើទ្រុង ដែលនេះគឺជាចំណាយដំបូង លើការចិញ្ចឹមទាក្នុងមួយលើកៗ។ ជាទូទៅក្នុងទាពងមួយក្បាលមានតម្លៃ ១៨,០០០ រៀល ។ លោកពូ ប៉ូរ៉ា បានទិញទាពងសរុបជាង ៤០០០ ក្បាល នៅដើមឆ្នាំ ២០១៩ និង ៦០០០ ក្បាលទៀតនៅក្នុងកំឡុងខែ កញ្ញា ឆ្នាំ២០១៩។

តារាងទី៦៖ ចំនួនទាដែលលោកពូបានទិញនៅឆ្នាំ២០១៩

| ឆ្នាំ | ឈ្មោះ | ចំនួន | ថ្លៃក្នុង ១ក្បាលទា (រ) | ថ្លៃសរុប (រ) |
|---|---|---|---|---|
| ២០១៧ | ទាពង | ៤០០០ ក្បាល | ១៨,០០០ | ៧២,០០០,០០០ |
| ២០១៨ | ទាពង | ៦០០០ ក្បាល | ១៨,០០០ | ១០៨,០០០,០០០ |
| សរុប | | | | ១៨០ លានរៀល |

### ៣.៤.៣. ការចំណាយទៅលើចំណី

ការផ្តល់ចំណីត្រូវបានចែងចែកចេញជាពីរ គឺចំណីកូនទា និងចំណីទាពង ។ ពាក្យថាកូនទា គិតចាប់តាំងពីកើតរហូតមកត្រឹម ៤ខែ ។ ពាក្យថាទាពង គិតចាប់ទាអាយុ ៤ ខែ រហូតដល់ស្លាប់ ឬលក់ចេញ ។ ឈ្មោះចំណីទា DUCK STARTER 3114 សម្រាប់កូន ១ ប៉េ/៣០ kg ស្មើនឹង ៦៨,០០០ រៀល និងឈ្មោះចំណីទា DUCK STARTER 3114 សម្រាប់មេពង ១ ប៉េ/៣០ kg ស្មើនឹង ៤៨,០០០ រៀល ។

តារាងទី៧៖ ការចំណាយលើចំណីសម្រាប់ទា ១០០០០ក្បាល

| ឈ្មោះចំណី | ចំនួន | តម្លៃក្នុង ១ ប៉េ | សរុប |
|---|---|---|---|
| DUCK STARTER 3114 | ៤០ ប៉េ | ៤៨០០០ រៀល | ១,៩២០,០០០ រៀល |

### ៣.៤.៤. ចំណីគិតជាក្រាមសម្រាប់ទាមួយក្បាលក្នុងមួយថ្ងៃ

នៅត្រង់ចំនុចនេះ យើងនិងសិក្សាអំពីការចំនួនចំណីដែលទាមានស៊ីក្នុងមួយថ្ងៃគិតជាក្រាម ។ ហើយដើម្បីសិក្សាពីចំនួនក្រាមដែលទាបានស៊ីសរុបក្នុងមួយថ្ងៃ យកមកចែកជាមួយចំនួនទាដែលបានស៊ីចំណីសរុប ។

តាង៖ - **De** (g) = ជាចំនួនក្រាមដែលទាបានស៊ីក្នុងមួយថ្ងៃ

-**TF:** ចំណាយសរុបក្នុងការទិញចំណីទាក្នុងមួយថ្ងៃ

- **DT:** ចំនួនទាសរុប

**ដែល TF =** ៤០ ប៉េ = ១,២០០,000 ក្រាម = និង **DT =** ១0,000 ក្បាល

នាំឲ្យ: De = ១,២០០,000 ក្រាម / ១0,000 ក្បាល = ១២០ ក្រាម/១ ថ្ងៃ ។

តាមការបកស្រាយខាងលើ បង្ហាញអោយឃើញថា ជាមធ្យមក្នុងមួយថ្ងៃទាក្នុងមួយក្បាលស៊ីចំណីអស់ ១២០ ក្រាម ។

### ៣.៤.៥. ការចំណាយលើការថែទាំ

ការថែទាំ ក៏ជាខ្ទង់ចំណាយធំមួយដែរសម្រាប់លោកពូ បូរ៉ា ដែលការចំណាយទាំងនោះ មានដូចជា ការចំណាយទៅលើថ្នាំសង្កូវនានា ការចំណាយលើប្រាក់ឈ្នួលបុគ្គលិក ៤ នាក់ (ក្នុងម្នាក់ទទួលបាន ៦០០,000 រៀល/ខែ) ការចំណាយលើម្ហូបអាហារបុគ្គលិក និងការចំណាយប្រើប្រាស់ម៉ាស៊ីនសម្រាប់ការបូមទឹក និងភ្លើងអគ្គិសនី ។ ការចំណាយទាំងនេះជាការចំណាយដែលមានសារៈសំខាន់ ព្រោះថាវាជាការចាំបាច់ណាស់ សម្រាប់ដំណើរការចិញ្ចឹមទាប្រចាំថ្ងៃរបស់លោកពូ ។

តារាងទី៨៖ ការចំណាយលើការថែទាំ

| ចំណាយទៅលើ | ចំនួន | តម្លៃ (៛) | សរុបក្នុង ១ ថ្ងៃ (៛) | ក្នុង ១ ខែ (៛) |
|---|---|---|---|---|
| បុគ្គលិក ឬកម្មករ | ៤ នាក់ | ២០,000 | ៨០,000 | ២,៤០០,000 |
| ម្ហូបសម្រាប់កម្មករ | ៤ នាក់ | | ៦៥,000 | ១,៩៥០,000 |
| ប្រេងម៉ាស៊ូត | ៣ លីត្រ | ២៥០០ | ៧,៥០០ | ២២៥,000 |
| សរុប | | | | ៤,៥៧៥,000 |

### ៣.៤.៦. ការចំណាយបន្ទាប់បន្សំ

ការចំណាយចុងក្រោយនេះ គឺជាការចំណាយដែលលោក បូរ៉ា មិនបានគិតឲ្យហ្មត់ចត់ទេ ព្រោះថាវាមាន មានចំនួនតិចតួចណាស់ ដែលយើងអាចហៅបានថា ជាការចំណាយបែបប្រយោល ឬចំណាយអត់ខ្ទង់របស់ លោកពូផ្ទាល់ដែលគាត់មិនបានដឹង និងមិនបានគិតដល់។ រាល់លើកលោកពូគិតជាមធ្យមថា គាត់ត្រូវ ចំណាយ លើការចំណាយបន្ទាប់បន្សំនេះអស់ប្រហែល ១០០ ដុល្លារក្នុងមួយខែ ដូចជាការចំណាយលើកាត ទូរស័ព្ទ និងទិញសម្ភារៈផ្សេងៗនៅក្នុងកសិដ្ឋាន ។

## ៣.៥. ការទូទាត់ចំណាយសរុបក្នុងមួយថ្ងៃ

អាស្រ័យដោយមានការចំណាយច្រើនប្រភេទក្នុងការចិញ្ចឹម ជាទូទៅប្រជាកសិករខ្មែរមិនសូវគិតគូរដល់ ការវិភាគលើការចំណេញ ឬខាតអោយបានស៊ីជម្រៅនោះទេ ។ ដូច្នេះ យើងខ្ញុំនឹងសិក្សាបន្ថែម ក៏ដូចជាធ្វើការ សិក្សាអោយជាក់ច្បាស់អំពី កម្រិតនៃការចំណេញ ឬខាត អោយកាន់តែលំអិត ដោយចំណាយនោះរួមមាន ការចំណាយលើការទិញទា ការចំណាយលើការទិញចំណីទា ការចំណាយលើការថែទាំ ការចំណាយផ្សេងៗ និងបូករួមទាំង រំលស់ទៅលើការសាងសងរោង និងស្រះ ។

**រូបមន្ត៖** គណនាចំណាយសរុបក្នុងមួយថ្ងៃ

TC = TP + TF + TT + TO + Depreciation

- TC: ចំណាយសរុបក្នុងមួយថ្ងៃ
- TP: ចំណាយសរុបក្នុងការទិញទាគិតជាថ្ងៃ៖ ដោយទាគាត់មាន ១០០០០ក្បាល ទិញមកក្នុងតម្លៃ ១៨,០០០៛ ហើយមួយឆ្នាំក្រោយលក់ទៅវិញក្នុងតម្លៃ ១១,០០០៛ ដូច្នេះ នាំឲ្យ ((១៨០០០ - ១១,០០០ ) × ១០,០០០៛) ÷ ៣៦៥ = ១៩២,០០០៛
- TF: ចំណាយសរុបក្នុងការទិញចំណីទាក្នុងមួយថ្ងៃ៖ ដូចដែលបានបកស្រាយខាងលើរួចម្តងហើយ ក្នុង មួយថ្ងៃទារបស់គាត់ស៊ីអស់ ៤០ ប៉េ ដែលតម្លៃ ១ ប៉េ ស្មើនឹង ៤៨,០០០ រៀល។

នាំឲ្យ TF = ៤០ប៉េ × ៤៨,០០០ រៀល = ១,៩២០,០០០ រៀល

- TT: ចំណាយសរុបលើការថែទាំក្នុងមួយថ្ងៃ៖ សំដៅលើការចំណាយលើ ថ្លៃប្រាក់ខែបុគ្គលិក ថ្លៃម្ហូប អាហារ និងថ្លៃប្រេងម៉ាស៊ូតសម្រាប់ចាក់ម៉ាស៊ីន ក្នុងការថែទាំទាប្រចាំថ្ងៃ។

នាំឲ្យ TT = ៨០,០០០ + ៦៥,០០០ + ៧,៥០០ = ១៥២,៥០០រៀល/១ថ្ងៃ ។

- **TO:** ចំណាយផ្សេងៗទៀតក្នុងមួយថ្ងៃ៖ ជាការចំណាយបែបប្រយោល ឬចំណាយអត់ខ្ទង់ ដូចជាការចំណាយ កាតទូរស័ព្ទ ជាដើម ដែលចំណាយនោះស្មើនឹង ១៣,៤០០ រៀល/១ថ្ងៃ ។
- **Depreciation:** រំលស់ទៅលើការសាងសង់រោង និងស្រះអស់ជាង ៤២,០០០ ដុល្លារ ស្មើរនឹង ១៦៨,០០០,០០០ រៀល យើងរំពឹងថានឹងអាចប្រើប្រាស់បានរយៈ ៧ ឆ្នាំ នាំឲ្យក្នុងមួយចំណាយអស់ (១៦៨,០០០,០០០ ÷ (៣៦៥ × ៧)) ស្មើរនឹង ៦៦,៨០០ រៀល/ថ្ងៃ ។

**យើងបាន៖** TC = ១៩២,០០០៛ + ១,៩២០,០០០ រៀល + ១៥២,៥០០រៀល + ១៣,៤០០ រៀល + ៦៦,៨០០ រៀល = ២,៣៤៤,៧០០ រៀល ។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ជាមធ្យមគាត់ចំណាយលើការចិញ្ចឹមទាប្រមាណជា ២,៣៤៤,៧០០រៀល។

ក្រាភិកទី៣៖ ចំណាយលើការចិញ្ចឹមទាក្នុងមួយថ្ងៃ




## ៣.៦. ប្រភពចំណូលពីការចិញ្ចឹមទា

### ៣.៦.១. ចំណូលពីការលក់អាចម៍ទា

ថ្វីត្បិតអាចម៍ទា មានតម្លៃថោក លក់មិនបានថ្លៃ ប៉ុន្តែបើយើងគិតពីបរិមាណអាចម៍ទាវាមានចំនួនច្រើន ដែលអាចទទួលបានប្រាក់ចំណូលមួយផ្នែកទៀតដែរ ។ ជាទូទៅ គាត់តែសម្អាតទ្រុងទារបស់គាត់មួយអាទិត្យ សម្រាប់អាកាសធាតុធម្មតា (គ្មានភ្លៀងធ្លាក់) និង ២ ទៅ ៣ ថ្ងៃសម្អាតម្តង ឬធ្វើការសសម្អាតជារៀងរាល់ថ្ងៃ

នៅពេលមានភ្លៀងធ្លាក់ ព្រោះវាធ្វើអោយអាចម៍ទាសើម និងមានក្លិនស្អុយខ្លាំង ដែលតម្រូវអោយគាត់សម្អាតអោយបានស្អាត ។ ជាទូទៅការកើបអាចម៍ទាក្នុងមួយខែជាមធ្យមបានប្រមាណជា ៥០០ ប៉េ (ក្នុងមួយប៉េអាចលក់បានតម្លៃ ៣០០០ រៀល) ។

តារាងទី៩៖ ចំណូលពីការលក់អាចម៍ទា

| ចំណូល | ចំនួន | តំលៃរាយ (រៀល) | សរុប (រៀល) |
|---|---|---|---|
| អាចម៍ទា ក្នុងមួយខែ | ៥០០ | ៣០០០ | ១,៥០០,០០០ |

### ៣.៦.២. ចំណូលពីការលក់ពងទា

យើងដឹងហើយថា ការចិញ្ចឹមទានៅកសិដ្ឋានរបស់លោកពូ ប៉ូវ៉ា គឺផ្ដោតសំខាន់ទៅលើការយកពងដើម្បីទទួលបានចំណូល ។ ដូច្នេះនៅពេលទាពងបានចំនួនតិចគាត់នឹងប្រឈមទៅនឹងការខាតបង់ ផ្ទុយមកវិញបើទាពងបានចំនួនច្រើន គាត់នឹងមានឱកាសទទួលបានប្រាក់ចំណេញ។ ប៉ុន្តែចំនួនពងច្រើនតែមួយមុខ មិនទាន់ប្រាកដថា ចំណេញឬខាតអោយប្រាកដនោះទេ គឺវាអាស្រ័យទៅលើតម្លៃនៃការលក់ពងទាផងដែរ ។ លោក ប៉ូវ៉ា បានបន្តរៀបរាប់ទៀតថា បច្ចុប្បន្ននេះ តម្លៃទីផ្សាររបស់ពងទា នៅក្នុងប្រទេសកម្ពុជាយើង គឺមានតម្លៃទីផ្សារល្អគួរសមដែរ អាចអោយគាត់ទទួលបានកម្រៃក្នុងកម្រិតមួយដែលអាចនិយាយបានថាល្អប្រសើរ ដោយក្នុងមួយគ្រាប់ពង តម្លៃ ៤៥០ រៀល ។ ខាងក្រោមនេះយើងខ្ញុំនឹងបង្ហាញអំពីចំណូលដែលទទួលបានពីការលក់ពងទារបស់លោកពូ ប៉ូវ៉ា។

តារាងទី១០៖ ចំណូលពីការលក់ពងទា

| ចំណូល | ចំនួន (មធ្យម) | តម្លៃរាយ | សរុប |
|---|---|---|---|
| ពងទា ក្នុងមួយថ្ងៃ | ៨,៥០០ គ្រាប់ | ៣៨០ | ៣,២៣០,០០០ រៀល |

### ៣.៦.៣. គណនាចំណូលសរុបក្នុងមួយថ្ងៃ

ចំណូលសរុប គឺជាប្រភពចំណូលចំណូលទាំងអស់ដែលទទួលបានពីការចិញ្ចឹមទា ។ ចំណូលទាំងនោះរួមមាន៖ ចំណូលពីការលក់ពងទា និងចំណូលពីការលក់អាចម៍ទា ។

តាង TR = ចំណូលសរុបក្នុងមួយថ្ងៃ

TR (egg) = ចំណូលពីការលក់ពងទា = ៣,២៣០,០០០ រៀល

TR (Ds) = ចំណូលពីការលក់អាចម៍ទា = ៥០,០០០ រៀល

យើងបាន៖ TR = ៣,២៣០,000 រៀល + ៥០,000 រៀល = ៣,២៨០,000 រៀលក្នុងមួយថ្ងៃ ។

ដូច្នេះយើងអាចធ្វើការសន្និដ្ឋានបានថា ជាមធ្យមគាត់ទទួលបានចំណូលពីការចិញ្ចឹមទាគោកនេះប្រមាណ ៣,២៨០,000 រៀលក្នុងមួយថ្ងៃ ។

## ៣.៧. ចំណេញសរុបក្នុងមួយថ្ងៃ

ចំណេញ គឺជាតួលេខចំណេញសរុបចុងក្រោយដែលត្រូវបានទទួលស្គាល់ ក្រោយពីដកជាមួយនឹងចំណាយទាំងអស់នៅក្នុងប្រតិបត្តិការនៃអាជីវកម្ម។ យើងអាចនិយាយអោយងាយស្រួលយល់ថា ចំណេញស្មើនឹង ចំណូល ដកជាមួយ ចំណាយ ។

នាំឲ្យ $T\pi$ = TR – TC = ៣,២៨០,000 រៀល - ២,៣៤៤,៧០០ រៀល

$T\pi$ = ៩៣៥,៣០០ រៀលក្នុងមួយថ្ងៃ

ដូចនេះយើងអាចសន្និដ្ឋានបានថា ក្នុងចំនួនទា ១០,000 ក្បាល លោកពូ ប៉ូវ៉ា អាចរកប្រាក់ចំណូលជាមធ្យមចំនួន ៩៣៥,៣០០ រៀលក្នុងមួយថ្ងៃ ។ ចំនួន ៩៣៥,៣០០ រៀលក្នុងមួយថ្ងៃ បើគិតទៅជា មួយខែស្មើនឹង ៩៣៥,៣០០ រៀល × ៣០ ថ្ងៃ = ២៨,០៥៩,000 រៀលក្នុងមួយខែ ។

## ៣.៨. ទិសដៅនៅថ្ងៃអនាគត

នៅក្នុងឆ្នាំ ២០២០នេះ បន្ទាប់ពីបានទទួលជោគជ័យក្នុងវិស័យកសិកម្ម គឺការចិញ្ចឹមទា លោកពូលោកបានរៀបរាប់ពីគម្រោងទៅថ្ងៃអនាគតគាត់ថា គាត់នឹងនូវបន្តចិញ្ចឹមទានេះបន្តទៅមុខទៀត ប៉ុន្តែនៅកម្រិតចំនួន ១០,000 ក្បាលដដែល គឺគាត់មិនមានគម្រោងចញ្ចឹមឲ្យច្រើនជាងនេះទៀតទេ ដោយគាត់ថាចំនួនត្រឹមប៉ុណ្ណឹងវាស្ថិតនៅកម្រិតមួយដែលគាត់អាចគ្រប់គ្រងបាន។ ប៉ុន្តែនៅក្នុងឆ្នាំ២០២១ លោកពូ ប៉ូវ៉ាមានគម្រោងចង់បង្កើតមុខរបរមួយបន្ថែមទៀត គឺការចិញ្ចឹមត្រី ដោយការជីកស្រះចំនួន២ ថែមទៀតក្នុងការចិញ្ចឹមនេះ។ មូលហេតុដែលបណ្តាលឲ្យលោកពូ ធ្វើការចិញ្ចឹមនេះដោយសារមានផលប្រយោជន៍ដូចជា៖

- បង្កើតជាមុខរបរមួយថ្មីបន្ថែមទៀតសម្រាប់គាត់
- បង្កើតជាមុខរបរមួយថ្មីសម្រាប់ប្រជាជននៅទីនោះ
- ជាផលិតកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក
- កាត់បន្ថយការចំណាយថវិការទិញត្រីពីផ្សារ
- តម្រូវការសាច់ត្រីបានទាន់ពេលវេលា និងជាម្ហូបប្រចាំថ្ងៃ
- ផ្តល់ប្រូតេអ៊ីន និងសារជាតុចិញ្ចឹមល្អដល់សុខភាពមនុស្ស

- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- កាត់បន្ថយការនេសាទត្រីធម្មជាតិ
- បង្កើនផលត្រីធម្មជាតិក្នុងតំបន់
- កាត់បន្ថយការចំណាកស្រុក ការងារនៅឆ្ងាយផ្ទះ
- បង្កើនការងារក្នុងស្រុក
- ជាចំណងចំណូលចិត្តរបស់គាត់ផ្ទាល់
- និងការកាត់បន្ថយភាពក្រីក្រ។

ហើយប្រភេទត្រីដែលគាត់គម្រោងនឹងយកមកធ្វើការចិញ្ចឹមៈ

- ប្រភេទត្រីដាក់ចិញ្ចឹម
  - ប្រភេទត្រីងាយស្រួលចិញ្ចឹម ងាយរកពូជមកចិញ្ចឹម ធន់នឹងជំងឺ ស៊ីចំណីធម្មជាតិ និងចំណីបន្ថែម ដែលអាចរកបាន មានតម្លៃក្នុងទីផ្សារ និងមានការនិយមបរិភោគពីសំណាក់ប្រជាជន
  - ត្រីឆ្ពិន ត្រីទីឡាព្យា កាបមញ្ញ កាមឥណ្ឌា កាបស កន្ធរ
- ការពិនិត្យ និងជ្រើសរើសកូនត្រីមកចិញ្ចឹម
  - លក្ខណៈកូនត្រីពូជល្អ ៖ សកម្មភាពហែលទឹករហ័សរហួន
  - ពេលឃើញមនុស្ស ឬ សត្រូវ កូនត្រីមានសកម្មភាពហែលគេចខ្លួនយ៉ាងលឿនចុះទៅទឹកជ្រៅ
  - ករណីហែលផ្ដុំក្បាលគ្នានៅត្រង់ចំនុចកណ្ដាលស្រះមុនពេលថ្ងៃរះ និងក្រោយថ្ងៃរះហែលចុះទៅស្រទាប់ទឹកបាតស្រះ ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

យោងតាមការស្រាវជ្រាវ និងសិក្សាលើលទ្ធផលអាចឲ្យយើងសន្និដ្ឋានបានថាការចិញ្ចឹមទាគោកយកពងជាលក្ខណៈគ្រួសារ ក្នុងទិសដៅលើកម្ពស់ជីវភាពគ្រួសារ ថ្វីត្បិតតែមានការលំបាក និងត្រូវការចិញ្ចឹមដោយការយកចិត្តទុកខ្ពស់ ទៅលើការជ្រើសរើសពូជ ការថែទាំ និងការគ្រប់គ្រង តែវាបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកម្ពស់ជីវភាពគ្រួសាររបស់លោកពូ ហ៊ី បូរ៉ា។ គ្រួសាររបស់លោកពូ ហ៊ី បូរ៉ា ដែលមានសក្តានុពលក្នុងផលិតកម្មទា ដែលអាចទាញយកប្រាក់ចំណូលបានប្រមាណជាង ៩៣៥,៣០០ រៀលក្នុងមួយថ្ងៃស្មើរនឹង ២៨,០៥៦,០០០ រៀលក្នុងមួយខែពីទាចំនួន ១០,០០០ក្បាល។ ការចិញ្ចឹមទារបស់លោកពូ ពីមួយថ្ងៃទៅមួយថ្ងៃ មាននិន្នាការឆ្ពោះទៅរកការធ្វើបែបប្រពលវប្បកម្ម និងប្រើប្រាស់នូវបច្ចេកទេសក្នុងការចិញ្ចឹមទាគោកកាន់តែប្រសើរជាងមុន ។

ជីវភាពក្នុងក្រុមគ្រួសាររបស់លោកពូ ហ៊ី បូរ៉ា មានលក្ខណៈស្តង់ដារនៃការរស់នៅវិវត្តន៍កាន់តែប្រសើរជាងមុន។ គ្រួសាររបស់លោកពូ បូរ៉ា អាចមានលទ្ធភាពពង្រីកអាជីវកម្មរបស់គាត់កាន់តែធំឡើងៗ ថែមទាំងបានទិញដីបន្ថែម ដែលអាចជួយអោយការចិញ្ចឹមទារបស់គាត់កាន់តែមានភាពងាយស្រួល។ ក្រៅពីនេះគ្រួសាររបស់គាត់ ក៏មានលទ្ធភាពអោយកូនៗរបស់បានចូលសិក្សារៀនសូត្រគ្រប់ៗគ្នា មានអាហារហូបចុកគ្រប់គ្រាន់ មានលំនៅស្ថានរស់នៅសមរម្យ ផ្គួបផ្សំជាមួយការប្រើប្រាស់សម្ភារៈទំនើបៗ ដូចជា ម៉ូតូ ទូរស័ព្ទដៃ និងឡានជាដើម។ ទាំងនេះជាសក្ខីភាពដែលបញ្ជាក់អោយឃើញពីការរីកចម្រើននៅក្នុងគ្រួសារលោកពូ ហ៊ី បូរ៉ា តាមរយៈការចិញ្ចឹមទាគោកយកពង ។

ដោយឡែកបើយើងធ្វើការប្រៀបធៀបការយល់ដឹងដែលយើងទទួលបានពីការសិក្សាទ្រឹស្តីទៅនឹងការងារផ្ទាល់ដែលយើងទទួលបានពីការចុះស្រាវជ្រាវ ឃើញថាទ្រឹស្តីមានលក្ខណៈទូទៅច្រើនហើយទូលំទូលាយណាស់ ដែលនាំអោយចំណុចភាគច្រើននៃការអនុវត្តន៍ស្ទើរតែមិនបានស្វែងរកឃើញក្នុងទ្រឹស្តី តែតាមពិត ទ្រឹស្តីនោះបានគ្រប់ដណ្តប់រួចរាល់ហើយ ។ លក្ខណៈបែបនេះធ្វើឲ្យការស្រាវជ្រាវបានជួបនូវការលំបាកយ៉ាងច្រើន ដោយមុខជំនាញខ្លះយើងមិនដែលដឹងទាល់តែសោះ ។ ប៉ុន្តែការយល់ដឹងផ្នែកទ្រឹស្តីជួយសម្រួលឲ្យយើងនូវភាពងាយស្រួល ក្នុងការបត់បែនបានឆាប់រហ័សលើការបំពេញការងារផងដែរ។

## ២. ការផ្តល់អនុសាសន៍

ក្រោយពីបានសិក្សាអង្កេតលើការចិញ្ចឹមសត្វទាគោកយកពងរបស់លោកពូ ហ៊ឺ ប៉ូវ៉ា នៅក្នុងភូមិទ្រាសរ ឃុំខ្នារស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមរួចមក ដោយឃើញពីភាពខ្វះចន្លោះមួយចំនួនក្នុងការចិញ្ចឹមទា យើងខ្ញុំសូមមានមតិយោបល់មួយចំនួន ដើម្បីជម្រុញការងារនេះអោយកាន់តែមានភាពរលូនទៅមុខ និងកាន់តែប្រសើរឡើង ព្រមទាំងជួយសម្រួលដល់ការចិញ្ចឹមៈ

- ចំពោះកសិករដែលមានបញ្ហាក្នុងការបង្វិលប្រាក់ដើម្បីពង្រីកកសិដ្ឋាន ឬដើម្បីដោះស្រាយបញ្ហាថវិកាដែលជួបប្រទះក្នុងដំណើរការនៃការចិញ្ចឹម គួរគប្បីប្រើប្រាស់នូវកម្ចីពីធនាគារ ក្នុងការបង្វិលដោយជៀសវាងការប្រើប្រាស់កម្ចីឯកជនតាមផ្ទះ ឬកម្ចីប្រាក់ពីឈ្មួញកណ្តាល(ចងការ)។
- ព្យាយាមទំនាក់ទំនងស្វែងរកទីផ្សារលក់ពងទាបន្ថែមដើម្បីលក់បានក្នុងតម្លៃដែលខ្ពស់បំផុតតាមដែលអាចរកបាន
- រកវិធីសាស្ត្របន្ថែមដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម ដោយកែប្រែចង្វាក់ផលិតកម្មដែលមានភាពបុរាណនិងប្រើប្រាស់តាមបែបបទបច្ចេកទេសឲ្យអស់ពីលទ្ធភាព
- កសិករចិញ្ចឹមទាទាំងអស់គួរតែបង្កើតជាសមាគមអ្នកចិញ្ចឹមទាដើម្បីលើកទឹកចិត្តដល់ការរក្សាស្ថេរភាពតម្លៃលក់ចេញនិងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក។

# ឯកសារយោង


- ការផ្សព្វផ្សាយអប់រំរបស់ អង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា,« វិធីការពារ វីរុសកូរ៉ូណា/covid 19» (២០ សីហា ២០២០)
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, «ហិរញ្ញប្បទានក្នុងវិស័យកសិកម្ម និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មសម្រាប់កសិកម្មខ្នាតតូច» (ខែកញ្ញា ឆ្នាំ ២០១០)
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,«ការចិញ្ចឹម និងគ្រប់គ្រងទានៅជនបទ» (ឆ្នាំ ២០០៦)
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,«បទពិសោធន៍នៃការចិញ្ចឹមទា របស់កសិករ ង៉ែត ផុន» (ឆ្នាំ ២០១០)
- ចាវ ប៉េងណាំ, អង្គការអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជា, «វីដេអូបច្ចេកទេសរបៀបចិញ្ចឹមទា» (២០១៣)
- ជំរឿនកសិកម្មព្រះរាជាណាចក្រកម្ពុជា,អាចចូលបានៈ ថ្ងៃចូលមើល ១៤ មេសា ឆ្នាំ២០២០ https://www.google.com/search
- មេរៀនសាស្ត្រាចារ្យ ឌុយ ចាន់ឌីណា, (២០១៩) «សេដ្ឋកិច្ចអភិវឌ្ឍ១», slide២៩
- រាជរដ្ឋាភិបាលកម្ពុជា,(ឆ្នាំ ២០១៨), យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និតិកាលទី៥ នៃរដ្ឋសភា»
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាសាស្រ្តាចារ្យណែនាំ បណ្ឌិត ឌុយ ចាន់ឌីណា, តាក់តែងដោយនិស្សិត សួន ស៊ីវហ៊ាន , «ការអភិវឌ្ឍវិស័យចិញ្ចឹមមាន់សាច់នៅក្នុងឃុំដំណាក់អំពិល» (ឆ្នាំ ២០១១)
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, វចនានុក្រមខ្មែរ, ព.ស.២៥១១, គ.ស.១៩៦៧
- សារណាបញ្ចប់ការសិក្សា, កម្មវិធីអភិវឌ្ឍន៍របស់ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ, ២០០២-២០០៦
- សារណាបញ្ចប់ការសិក្សាណែនាំដោយ បណ្ឌិត ឈុន ពហុ, ស្រាវជ្រាវដោយនិស្សិត ទ្បៃ ប៉ូរ៉ាពីន, «ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា» (ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧)
- សាស្រ្តាចារ្យ ឈុន ពហុ, «សេដ្ឋកិច្ចកសិកម្ម», ត្រង់មេរៀន ទ្រឹស្តីមូលដ្ឋានជុំវិញការអភិវឌ្ឍកសិកម្ម
- សេចក្តីថ្លែងការណ៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, ( ២៤ មិថុនា ២០២០)
- សេក្តីថ្លៃការណ៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, ( ២១ កក្កដា ២០២០)
- Amy Fontinelle, Standard of living and Quality of life, (April 11, 2019)
- ASAIN DEVELOPMENT BANK (ADB), "វិស័យកសិកម្ម និងការអភិវឌ្ឍន៍នៅកម្ពុជា" (ខែ កញ្ញា ឆ្នាំ២០០៩)

- Cambridge Dictionary, https://dictionary.cambridge.org/dictionary/english/development
- Geoff Riley, (Agu 1,2018), Rostow's Five Stages of Economic Growth Model, access date (18 April, 2020), from: https://www.tutor2u.net/economics/reference/rostow-five-stages-of-economic-growth-model
- IMF, Global economy will suffer worst year since Depression,( April 14, 2020)
- Jim Woodruff, (February 12, 2019), Factors Affecting Economic Development and Growth, access date (15 April, 2020) from: https://smallbusiness.chron.com/factors-affecting-economic-development-growth
- Michael P. Todaro, Stephen C. Smith. (2007). Economic Development, pp111
- Michelle Seidel, The positive and negative effects of unemployment (October 26, 2018)
- Nosheen Maan, Impact of population growth on national development, (2017)
- So Thoura, Business Cambodia, (December 01, 2019)
- United Nations Development Program, 1991, p 28
- USAID, «កសិកម្ម និងសន្តិសុខស្បៀង» (២៣ សីហា ២០១៩)
- William Easterly, (August 1997), How the Harrod-Domar Growth Model Still Haunts Development Economics, World Bank, access date (25 April, 2020) from: http://documents.worldbank.org/curated/en/494271468739201862/pdf/multi-page.pdf
- Youtube, (November,2019) Dunk Farm in Cambodia, access date (13 April, 2020) from: https://www.youtube.com/watch

# ឧបសម្ព័ន្ធទី១

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

---

## កម្រងសំណួរស្រាវជ្រាវ

**ជាបឋមយើងខ្ញុំ សូមធ្វើការរកិច្ចគោរព និងជម្រាបសួរដល់លោកពូ ម្ចាស់កសិដ្ឋាន ក្នុងឱកាសថ្ងៃនេះ យើងខ្ញុំសូមការអនុញ្ញាត ដើម្បីសួរនូវសំណួរស្រាវជ្រាវ**

កម្រងសំណួរនេះត្រូវបានរៀបរៀងឡើងដោយក្រុមយើងខ្ញុំដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមប្រធានបទ «**ការអភិវឌ្ឍជីវភាពគ្រួសារ តាមរយៈការចិញ្ចឹមសត្វ**» ក្នុងគោលបំណងសិក្សាស្វែងយល់ អំពីរបៀបនៃការចិញ្ចឹម បញ្ហាប្រឈម ដំណោះស្រាយ និងផលចំណេញដែលទទួលបានពីការចិញ្ចឹមទា។ យើងខ្ញុំសន្យាថា នឹងប្រើប្រាស់ព័ត៌មានដែលទទួលបានឲ្យបានត្រឹមត្រូវក្នុងបរិបទនៃការសិក្សា និងរក្សានូវការសំងាត់ជូនលោកពូ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកពូ ក្នុងការចំណាយពេលវេលាដល់មានតម្លៃដើម្បីផ្តល់បទពិសោធន៍ល្អៗដល់ក្រុមយើងខ្ញុំ។

១. ឈ្មោះ............................................... ២. អាយុ.................

៣. ចំនួនទាបច្ចុប្បន្ន.........................................................ក្បាល

៤.ចូលលោកពូរៀបរាប់ពីស្ថានទូទៅនៅកសិដ្ឋាននេះបាទេ? ............................................................

..................................................................................................................................................

..................................................................................................................................................

៤.ចូលលោកពូនិយាយអំពីប្រវត្តិនៃការចិញ្ចឹទា?..........................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

៥.តើមូលហេតុអ្វីដែលបណ្តាយអោយលោកពូមានបំណងក្នុងការចិញ្ចឹទា? ............................................

..................................................................................................................................................

..................................................................................................................................................

៥.ចូលលោកពូលអធិប្បាយពីដំណើការនៃការចិញ្ចឹទា?.............................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៦.តើមានបញ្ហាប្រឈមអ្វីខ្លះដែលលោកពូធ្លាប់ជួបប្រទះកន្លមក? ..........................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៧. ក្នុងបញ្ហាដែលលោកពូជួបប្រទះខាងលើ តើលោកពូដោះស្រាយយ៉ាងដូចម្តេចដែរ?...................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៨. តើលោកពូ ប្រាក់ចំណូលដែលទទួលបានក្នុងមួយថ្ងៃប៉ុន្មាន? តាមរយៈអ្វីខ្លះ?

..........................................................................................................................................

..........................................................................................................................................

៩. តើលោកពូចំណាយអស់ប៉ុន្មានក្នុងមួយថ្ងៃទៅលើការចិញ្ចឹមទានេះ? ចំណាយទៅលើអ្វីខ្លះ?

..........................................................................................................................................

..........................................................................................................................................

១០.ពងទាដែលទទួលបានតើលោកយកទៅលក់នៅទីផ្សាណា?...........................................................

..........................................................................................................................................

១១.តើមានការប្រគួតប្រជែងដែរឬទេ? .........................................................................................

..........................................................................................................................................

១២.តើលោកពូមានគំរោងអ្វីនៅឆ្នាំបន្ទាប់ខាមុខ?.............................................................................

..........................................................................................................................................

.........................................................................................................................................។

សូមអរគុណ!

# ឧបសម្ព័ន្ធទី២



ផ្លូវចូលទៅកាន់កសិដ្ឋាន



បរិវេណខាងក្នុងនៃកសិដ្ឋាន







ទ្រុងទា ឬរោងទា






ទីធ្លាទាលេង និងស៊ីចំណី



ស្រះទឹកសម្រាប់ទាលេង

 

សកម្មភាពទាលេងទឹក



ប្រព័ន្ធទឹកសម្រាប់ទាផឹកនៅក្នុងទ្រុង



សកម្មភាពទាស៊ីចំណី




ចំណីដែលផ្តល់ឲ្យទា




ចំណីទា




ម៉ាស៊ីនបូមទឹក



អាងស្តុកទឹក

# ការប្រមូលទិន្នផល





